WOORI BANK

Woori Financial Group, Korea

របាយការណ៍ ប្រចាំឆ្នាំ

2021

ពង្រីកវិសាលភាពជោគជ័យជាមួយគ្នា

RE
PO
RT

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក គឺជាធនាគារពាណិជ្ជឈានមុខគេមួយនៅកម្ពុជា ដែលបានបម្រើផលិតផលនិងសេវាហិរញ្ញវត្ថុយ៉ាងសម្បូរបែបដល់ប្រជាជនកម្ពុជាអស់រយៈពេលជាង 30 ឆ្នាំមកហើយ។ ធនាគារអ៊ូរី (ខេមបូឌា) ម.ក ជាសមាជិករបស់ធនាគារ អ៊ូរី ដែលជាធនាគារឈានមុខគេមួយនៅប្រទេសកូរ៉េ និងត្រូវបានបង្កើតឡើងតាំងពីឆ្នាំ1899 មកម្ល៉េះ។ គិតត្រឹមថ្ងៃទី31 ខែឧសភា ឆ្នាំ2022 ធនាគារអ៊ូរី (ខេមបូឌា) ម.ក បានពង្រីកសាខាប្រតិបត្តិការរបស់ខ្លួនរហូតដល់138 សាខាទូទាំងប្រទេសកម្ពុជា។

មាតិកា

I. **អំពីស្ថាប័ន**

យើងជានរណា ? 8
សារពីប្រធានក្រុមប្រឹក្សាភិបាល 10
សារពីអគ្គនាយកប្រតិបត្តិ 12
ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ 14
អំពីធនាគារ អ៊ីរ៉ូ 16

II. **អភិបាលកិច្ចសាជីវកម្ម**

រចនាសម្ព័ន្ធរបស់ធនាគារ អ៊ីរ៉ូ (ខេមបូឌា) ម.ក. 20
អំពីក្រុមប្រឹក្សាភិបាល 22
អំពីគណៈគ្រប់គ្រងជាន់ខ្ពស់ 24
ការគ្រប់គ្រងហានិភ័យ 28
ការប្រតិបត្តិតាម 30
សវនករផ្ទៃក្នុង 31

III. **លទ្ធផលសម្រេចបាន**

ធនាគារ អ៊ីរ៉ូ បានក្លាយខ្លួនជា ធនាគារពាណិជ្ជជាផ្លូវការ 34
ការបន្ថែមមុខងារថ្មីលើសេវាកម្មធនាគារចល័ត 36
បើកដំណើរការសាខាថ្មីចំនួន3 37
ផលិតផល និងសេវាកម្មថ្មី 37

VI. **ចំណុចសំខាន់ៗអំពីអាជីវកម្ម**

ទិន្នន័យហិរញ្ញវត្ថុសំខាន់ៗ 40
របាយការណ៍អភិវឌ្ឍន៍ធនធានមនុស្ស 44
ព័ត៌មានសំខាន់ៗ 48
អំពីភាពជោគជ័យរបស់អតិថិជន 50
ផលិតផល និងសេវាកម្ម 53
របាយការណ៍ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម 66
បណ្តាញសាខា និងតំបន់ប្រតិបត្តការ 68

V. **របាយការណ៍ហិរញ្ញវត្ថុ**

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ 72
របាយការណ៍ចំណូលលម្អិត 73
របាយការណ៍បម្រែបម្រួលមូលធន 74
របាយការណ៍លំហូរសាច់ប្រាក់ 75
របាយការណ៍របស់សវនករឯករាជ្យ 76
របាយការណ៍របស់ក្រុមប្រឹក្សាភិបាល 80

CAM
BO
DIA

30 Years

Experiences in
Serving Financial Services

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក មានបទពិសោធន៍
លើសេវាហិរញ្ញវត្ថុ នៅកម្ពុជាជិត30 ឆ្នាំ និងបាន
ពង្រីកបណ្តាញប្រតិបត្តិការដល់138សាខាទូទាំង
ប្រទេស។

អំពីស្ថាប័ន

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានបម្រើសេវាហិរញ្ញវត្ថុជាង30ឆ្នាំ ទូទាំងប្រទេស។ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក គឺជាធនាគារពាណិជ្ជ ដែលឈានមុខគេក្នុងប្រទេសកម្ពុជា ហើយក៏ជាសមាជិកគ្រួសាររបស់ធនាគារពាណិជ្ជ អ៊ូរី ដែលជាធនាគារឈានមុខគេមួយនៅប្រទេសកូរ៉េ ត្រូវបានបង្កើតឡើងនៅឆ្នាំ1899។

ធនាគារអ៊ូរី (ខេមបូឌា) ម.ក បានប្តេជ្ញាធ្វើឱ្យជីវិតអតិថិជន កាន់តែប្រសើរ តាមរយៈដំណោះស្រាយហិរញ្ញវត្ថុងាយៗ និងវៃឆ្លាត ដោយភ្ជាប់ជាមួយបច្ចេកវិទ្យាទាន់សម័យ ជាមួយការផ្តល់ជូននូវផលិតផល និងសេវាដែលឆ្លើយតបនឹងតម្រូវការអតិថិជនគោលដៅរបស់យើង។

ខែវិច្ឆិកា ឆ្នាំ2021 ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានទទួល **អាជ្ញាបណ្ណជាផ្លូវការក្នុងនាមជា ធនាគារពាណិជ្ជ** ពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម នៃកម្ពុជា។

យើងកំពុងតែជំរុញឱ្យមានកំណើនលូតលាស់ ជួយបង្កើតការងារ អភិវឌ្ឍន៍សហគមន៍ ជំរុញការបំលាស់ប្តូរសេដ្ឋកិច្ច និងដំណោះស្រាយបញ្ហាប្រឈមមុខធំៗនៅក្នុងសង្គម ខណៈពេលដែលបន្តការគ្រប់គ្រងហានិភ័យ និងការផ្តល់ត្រឡប់សងទៅវិញជូនអតិថិជន និងភាគទុនិករបស់យើង។ យើងជឿជាក់ថា យើងអាចទទួលបានជោគជ័យនៅពេលដែលអតិថិជនម្នាក់ៗ ក្រុមហ៊ុននានា សហគមន៍ និងបុគ្គលិកដែលយើងបានបម្រើសេវាកម្មជូនអាចឈានដល់ទស្សនៈវិស័យជោគជ័យរបស់ពួកគេ។

គិតត្រឹមខែធ្នូ ឆ្នាំ2021 ធនាគារ អ៊ូរី បាន
ពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួនដល់ 138 សាខាទូទាំងប្រទេស។

ធនាគារ អ៊ូរី ផ្តោតសំខាន់លើការផ្តល់បទពិសោធន៍ធនាគារដ៏ល្អប្រសើរ សម្រាប់អតិថិជនរបស់ខ្លួន តាមរយៈសាខាដែលត្រូវបានរចនាឡើង យ៉ាងទំនើប និងប្រកបដោយផាសុកភាពខ្ពស់ជាមួយនឹងបុគ្គលិកជំនាញ ប្រកបដោយស្នាមញញឹម និងរួសរាយរាក់ទាក់។

សារពី
ប្រធានក្រុមប្រឹក្សាភិបាល

លោក យូន ហ៊ុនសង់
ប្រធានក្រុមប្រឹក្សាភិបាល នៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក

យោងទៅលើផែនការស្តារសេដ្ឋកិច្ច យុទ្ធនាការចាក់វ៉ាក់សាំង គោលការណ៍ណែនាំរឹតបន្តឹងពីក្រសួងសុខាភិបាល និងអន្តរាគមន៍សហគមន៍ដើម្បីសម្របខ្លួនទៅនឹង "ប្រក្រតីភាពតាមគន្លងថ្មី" ធនាគារអភិវឌ្ឍន៍អាស៊ីបានព្យាករណ៍ថា កម្ពុជានឹងមានកំណើនផលិតផលក្នុងស្រុកសរុបនឹងកើនឡើង 5.3% ក្នុងឆ្នាំ 2022 និង 6.5% ក្នុងឆ្នាំ 2023 ។

ការរីកចម្រើនជាបន្តបន្ទាប់នៃលទ្ធផលការងាររបស់យើងគឺដោយសារការធ្វើសកម្មភាពយ៉ាងសកម្ម និងបត់បែនការអនុវត្តភ្លាមៗក្នុងក្រុមហ៊ុន ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង ដែលប្រែប្រួលឥតឈប់ឈរ។ ឆ្នាំ 2021នេះ បានផ្លាស់ប្តូរ ទាំងស្រុងនូវទស្សនៈរបស់យើងចំពោះបែបបទនៃដំណើរការអាជីវកម្ម ការបង្កើតទំនាក់ទំនងជាមួយអតិថិជន និងការថែរក្សាសុខភាពផងដែរ។ ជាមួយគ្នានេះដែរ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានចាប់យកឱកាសក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការស្ទួល និងដំណើរការអាជីវកម្មឱ្យឈរនៅចំណុចកំពូលក្នុងទីផ្សារហិរញ្ញវត្ថុ។

របាយការណ៍ពីសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជានាខែធ្នូ ឆ្នាំ 2021 បានបង្ហាញថា សំពៀតឥណទានសរុបបានកើនឡើងដល់ 18,760 លានដុល្លារអាមេរិក ពីគ្រឹះស្ថានហិរញ្ញវត្ថុដែលមានធនាគារ ចំនួន 7 មីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន 5 គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន 65 គ្រឹះស្ថានឥណទានជនបទចំនួន9 និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន7។ ទិន្នន័យនេះ បង្ហាញឱ្យឃើញថា សំពៀតឥណទានសរុបកើនឡើង 24.5% បើធៀបនឹងឆ្នាំ 2020 នៅពេលដែលចំនួនប្រាក់បញ្ញើកើនឡើង 25.2 % ធៀបជាមួយនឹងរយៈពេលដូចគ្នា។

ទោះបីជាស្ថិតក្នុងស្ថានភាពដែលមិនធ្លាប់មានពីមុនមកក៏ដោយ ក៏ក្រុមហ៊ុនរបស់យើងនៅតែបន្តបោះជំហានសំខាន់ៗឆ្ពោះទៅរកការក្លាយជាស្ថាប័នហិរញ្ញវត្ថុកំពូលនៅកម្ពុជា។ គិតត្រឹមខែធ្នូ ឆ្នាំ 2021 ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ទទួលបានប្រាក់ចំណេញសុទ្ធចំនួន 44.8 លានដុល្លារអាមេរិក ប្រាក់ចំណេញសុទ្ធធៀបនឹងទ្រព្យសកម្មស្មើនឹង 4.6% និង ប្រាក់ចំណេញសុទ្ធធៀបនឹងដើមទុនស្មើនឹង17.6%។ សមិទ្ធផលនេះគឺជាលទ្ធផលប្រកបដោយផ្លែផ្កានៃកំណើនសំពៀតឥណទាន ដែលមានចំនួន 928 លានដុល្លារអាមេរិក កើនឡើង 48.9% ធៀបនឹងឆ្នាំ 2020 រួមជាមួយនឹងកំណើនប្រាក់បញ្ញើឥតឈប់ឈររបស់យើងដល់ 217 លានដុល្លារអាមេរិក។ សមិទ្ធផលគួរឱ្យកត់សម្គាល់ដែលយើងទទួលបានរហូតមកដល់ពេលនេះ គឺដោយសារតែធនធានមនុស្សដ៏ប៉ិនប្រសប់ និងរឹងមាំរបស់យើង ដែលបានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការនាំមកនូវទិន្នផល និងលទ្ធផលជាវិជ្ជមានជាបន្តបន្ទាប់។

ជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងមុតមាំបែបនេះ យើងអាចសម្រេចបាននូវលទ្ធផលសំខាន់មួយទៀត ដោយទទួលបានអាជ្ញាបណ្ណធនាគារពាណិជ្ជពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម។ ការបំប្លែងទៅជាធនាគារពាណិជ្ជ ធនាគារ អ៊ូរី (ខេមបូឌា) នឹងអាចផ្តល់នូវផលិតផល និងសេវាកម្មកាន់តែច្រើន ធ្វើឱ្យការប្រើប្រាស់ធនាគារកាន់តែមានភាពងាយស្រួលជាងមុន។

ប្រទេសកម្ពុជា ត្រូវបានបានទទួលស្គាល់ថាជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានការរីកចម្រើនលឿនបំផុត ដោយបានចាប់ផ្តើមប្រើប្រាស់នូវប្រព័ន្ធឌីជីថលផ្សេងៗ ដើម្បីកាត់បន្ថយភាពលំបាករបស់អតិថិជន និងកិច្ចការដែលធ្វើដោយដៃ។ ការឆ្ពោះទៅរកការរីកចម្រើនសេដ្ឋកិច្ចនៅឆ្នាំ 2022 ទិសដៅយុទ្ធសាស្ត្ររបស់យើងនឹងផ្តោតលើការផ្តល់បទពិសោធន៍ដ៏ល្អឥតខ្ចោះ នៅលើប្រព័ន្ធធនាគារចល័ត ការទទួលស្គាល់ម៉ាកយីហោយ៉ាងទូលំទូលាយ ការកាន់កាប់ចំណែកទីផ្សារ និងការជ្រើសរើសបុគ្គលិកវ័យក្មេងដែលមានទេពកោសល្យមកចូលរួមបំពេញការងារជាមួយយើង។

ចំនួនទ្រព្យសកម្មសរុប

1,162 លានដុល្លារអាមេរិក

(**កំណើន 50.1%**)

ចំនួនឥណទានសរុប

928 លានដុល្លារអាមេរិក

(**កំណើន 48.9%**)

ចំនួនប្រាក់បញ្ញើសរុប

217 លានដុល្លារអាមេរិក

(**កំណើន 74.7%**)

ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំសូមគោរពយ៉ាងជ្រាលជ្រៅចំពោះនិយ័តករ និងអាជ្ញាធរមូលដ្ឋានសម្រាប់ការគាំទ្រឥតងាករេ និងការខិតខំប្រឹងប្រែងឥតឈប់ឈរក្នុងការជំរុញឧស្សាហកម្ម និងសេដ្ឋកិច្ចក្នុងអំឡុងពេលស្ថានភាពដ៏លំបាកនេះ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះធនាគារ អ៊ូរី នៃប្រទេសកូរ៉េ និងម្ចាស់ភាគហ៊ុនទាំងអស់សម្រាប់ទំនុកចិត្តមកលើយុទ្ធសាស្ត្រ និងទិសដៅអាជីវកម្មរបស់យើង។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកគ្រប់គ្រង និងបុគ្គលិក ធនាគារ អ៊ូរី (ខេមបូឌា) ម.ក របស់យើងដែលលះបង់ការខិតខំប្រឹងប្រែងឥតឈប់ឈរដើម្បីជំរុញឱ្យមានការរីកលូតលាស់នៃក្រុមហ៊ុនរបស់យើង។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជនរបស់យើង ដែលបង្ហាញពីការគាំទ្រជារៀងរហូត។ ខ្ញុំមានការជឿជាក់ និងប្តេជ្ញាចិត្តយ៉ាងខ្លាំងក្នុងការផ្តល់នូវអនុសាសន៍ និងការណែនាំដ៏ល្អបំផុតក្នុងការកសាង ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ឱ្យក្លាយជាស្ថាប័នហិរញ្ញវត្ថុកំពូលនៅកម្ពុជា។

លោក យូន ហ៊ុនសង់

ប្រធានក្រុមប្រឹក្សាភិបាល

សារពី
អគ្គនាយកប្រតិបត្តិ

លោក គីម ហុងជូ
អគ្គនាយកប្រតិបត្តិ នៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក

ការស្ទុះទ្បើងគួរឱ្យកត់សម្គាល់នៃសេដ្ឋកិច្ចពិភពលោកបានបើកឱកាសសម្រាប់ប្រទេសកម្ពុជាយើង ដើម្បីបំពេញនូវតម្រូវការយ៉ាងច្រើននៃឧស្សាហកម្មធំៗដែលវិស័យចម្បងរួមមាន ផ្នែកវាយនភណ្ឌ (សម្លៀកបំពាក់ និងសម្ភារៈធ្វើដំណើរស្បែកជើង និងការផលិតទោចក្រយាន) ក៏ដូចជាកសិកម្ម។ យោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីបានបង្ហាញថា សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានៅក្នុងឆ្នាំ2021 បានកើនទ្បើងដល់ 3.0% បន្ទាប់ពីការធ្លាក់ចុះ 3.1% នៅក្នុងឆ្នាំ 2020។ សមិទ្ធផលនេះបានមកពីការអនុវត្តយ៉ាងសកម្មដើម្បីកាត់បន្ថយឥទ្ធិពលនៃជំងឺកូវីដ19 មកលើផ្នែកពាណិជ្ជកម្ម និងចំណូលរបស់ប្រជាជន។ យុទ្ធនាការចាក់វ៉ាក់សាំងយ៉ាងសស្រាក់សស្រាំនៅទូទាំងប្រទេស បានរៀបចំប្រទេសកម្ពុជាឱ្យទទួលយកនូវភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចនៅឆ្នាំ 2022។

ខ្ញុំពិតជាមានការពេញចិត្ត និងមានកម្លាំងចិត្តជាខ្លាំងដែលបានឃើញថា ធនាគារ អ៊ូរី (ខេមបូឌា) រក្សាបាននូវសមិទ្ធផលដ៏ល្អរបស់យើង និងនៅតែដើរតួយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ 2021 នេះ ដោយខ្លួនបានទទួលការគាំទ្រយ៉ាងពេញទំហឹង ពីភាគីពាក់ព័ន្ធសំខាន់ៗទាំងអស់។ ការសម្រេចបានក្នុងឆ្នាំនេះ រួមមានទាំងការកើនទ្បើងនូវផ្នែកហិរញ្ញវត្ថុ ក៏ដូចជា ការទទួលបានអាជ្ញាបណ្ណជាផ្លូវការជាធនាគារពាណិជ្ជ។

នៅ ក្នុងឆ្នាំ 2021 ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ទទួលបានកំណើនរហូតដល់ 50.1% លើទ្រព្យសកម្មសរុប ដែលឈានដល់ 1,162 លានដុល្លារអាមេរិក។ លើសពីនេះ យើងបានបង្កើនប្រាក់ចំណេញសុទ្ធ របស់យើង ដល់ 44.8 លានដុល្លារអាមេរិកក្នុងឆ្នាំនេះ កើនរហូតដល់ 68.4% ពី 26.6 លានដុល្លារអាមេរិកកាលពីឆ្នាំមុន។ សំពៀតឥណទាន របស់យើងមានការកើនទ្បើង 48.9% ពី 623 លានដុល្លារអាមេរិកកាលពីឆ្នាំមុន ដែលស្មើនឹង 928 លានដុល្លារអាមេរិក។ ប្រាក់បញ្ញើរបស់យើងបានកើនទ្បើងយ៉ាងមានស្ថិរភាពល្អដល់ 217 លានដុល្លារអាមេរិចក្នុងឆ្នាំ 2021 កំណើនប្រមាណ 74.7% ពី 124 លានដុល្លារអាមេរិចក្នុងឆ្នាំ 2020។

ដោយផ្តោតសំខាន់ទៅលើអត្ថប្រយោជន៍អតិថិជនជាចម្បង យើងបានស្នើសុំ និងទទួលបានការអនុម័តជាផ្លូវការពី

ធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម (MOC) ទៅជា ធនាគារពាណិជ្ជដោយប្តូរឈ្មោះពីជាប់ប៊ែលយូប៊ី ហ្វាយនែន ទៅជា ធនាគារ អ៊ូរី (ខេមបូឌា) ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការរបស់យើង។ ជាមួយនឹងអាជ្ញាបណ្ណប្រតិបត្តិការថ្មីនេះ ធនាគារ អ៊ូរី (ខេមបូឌា) នឹងអាចផ្តល់នូវផលិតផល និងសេវាកម្មប្រកបដោយភាពច្នៃប្រឌិតខ្ពស់។ ស្របតាមការរីកចម្រើននេះ ធនាគារ អ៊ូរី (ខេមបូឌា) មានបុគ្គលិកឆ្លើមប្រមាណជាង 3,700 នាក់ ដែលកំពុងបម្រើការយ៉ាងសកម្ម ហើយផ្តោតខ្លាំងទៅលើការអភិវឌ្ឍជំនាញការងារ និងសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ តាមរយៈការផ្តល់ជូនវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពបុគ្គលិកផ្សេងៗ។

អាទិភាពសំខាន់មួយទៀតសម្រាប់ ធនាគារ អ៊ូរី (ខេមបូឌា) គឺការផ្តល់ជូននូវ ផ្នែកហិរញ្ញវត្ថុ និងការពង្រីកវិសាលភាពតំបន់ប្រតិបត្តិការ របស់យើងបន្ថែមទៀតដល់ 138 សាខា ហើយបានក្លាយជាសមាជិកនៃ សេវាផ្ទេរមូលនិធិភ្លាមៗ (RFT) និងប្រព័ន្ធបាគង 2.0។ លើសពីនេះ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានពង្រីកផលិតផល និងសេវាកម្មរបស់ខ្លួន ដោយបន្ថែមសេវាបញ្ជាអចិន្ត្រៃយ៍ ការដាក់ប្រាក់បញ្ញើសប្បុរស ការសន្សំតាមផែនការ ប្រាក់កម្ចីកូនកាត់ពិសេស និងសេវាបើកប្រាក់បៀវត្សរ៍ និងការបន្តអភិវឌ្ឍន៍សេវាធនាគារចល័ត ។

ជាមួយនឹងកំណើនឥតឈប់ឈរនៃអាជីវកម្ម របស់ ធនាគារ អ៊ូរី (ខេមបូឌា) យើងនៅតែផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើសកម្មភាពសង្គម ដោយរួមបញ្ចូលនូវសកម្មភាពសង្គមជាច្រើនក្នុងការធ្វើប្រតិបត្តិការ ដើម្បីគាំទ្រដល់សហគមន៍ និងបរិស្ថាន។ ក្នុងចំណោមសកម្មភាពសង្គមជាច្រើននេះ ធនាគារ អ៊ូរី (ខេមបូឌា) បានបរិច្ចាគថវិកា ដើម្បីសាងសង់មណ្ឌលថែទាំសុខភាពមួយកន្លែងនៅស្រុកសន្ទុក ខេត្តកំពង់ធំ និងបរិច្ចាគទឹកប្រាក់ទៅដល់ពុទ្ធិកវិទ្យាល័យរាជបូណ៌ខេត្តសៀមរាប។ លើសពីនេះ យើងក៏បានចូលរួមចំណែកក្នុងការទិញម៉ាស អាល់កុលសម្លាប់មេរោគ និងកាបូបបរិស្ថានដល់ប្រជាពលរដ្ឋខ្មែរដែលនឹងទៅធ្វើការនៅប្រទេសកូរ៉េ ដោយផ្តល់ជូនតាមរយៈក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្នុងខែកញ្ញា ឆ្នាំ 2021 យើងបានបង្កើត គណនីប្រាក់បញ្ញើសប្បុរសធម៌ដំបូងគេ គឺ គណនីសប្បុរស ដែលផ្តល់ជូនអតិថិជននូវជម្រើសក្នុងការបរិច្ចាគទៅអង្គការសប្បុរសធម៌ដែលពួកគេពេញចិត្ត នៅពេលពួកគេដាក់ប្រាក់ ដោយមានដៃគូសប្បុរសធម៌ចំនួន 5 រួមមាន មូលនិធិគន្ធបុប្ផាកម្ពុជា មូលនិធិកុមារកម្ពុជា មូលនិធិដុនបូស្កូកម្ពុជា មន្ទីរពេទ្យកុមារអង្គរ និង មូលនិធិធម្មឱសថ ។

ការឆ្ពោះទៅរកកំណើន ផលិតផលក្នុងស្រុក (GDP) ដែលរំពឹងទុកថានឹងកើនដល់ 5.3% នៅក្នុងឆ្នាំ 2022 ធនាគារ អ៊ូរី (ខេមបូឌា) បាននឹងកំពុងធ្វើការយ៉ាងខ្ជាប់ខ្ជួន និងរៀបចំយ៉ាងល្អ ដើម្បីបម្រើប្រជាជនកម្ពុជារបស់យើងជាមួយនឹងសេវាកម្ម ដ៏សម្បូរបែប។ ផែនការយុទ្ធសាស្ត្ររបស់យើង យើងបានដាក់ឱ្យប្រើប្រាស់ ឥណទានសាជីវកម្ម ឥណទានសហគ្រាសខ្នាតតូច និង មធ្យម សេវាផ្ទេរប្រាក់ អន្តរជាតិ គណនីពាណិជ្ជករពិសេស KHQR ដែលអាចទទួលយកការទូទាត់នៅបានពីគ្រប់ធនាគារដែលជាសមាជិកបាគង ក្នុងឆមាសទីមួយនៃឆ្នាំ 2022 នេះ។ យើងនឹងបន្តដាក់ឱ្យប្រើប្រាស់ផលិតផល និងសេវាកម្មជាច្រើនទៀត ដែលរួមមានផលិតផលពាណិជ្ជកម្មអន្តរជាតិ ម៉ាស៊ីន ATM/CRMs និង មុខងារទូទាត់តាមអេឡិចត្រូនិកជាច្រើនទៀតនៅក្នុងកម្មវិធី ធនាគារចល័ត (WOORI WON Cambodia) ប័ណ្ណឥណទាន និងសេវាជាច្រើនទៀត។

អ្វីដែលសំខាន់ផងដែរនោះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះនិយ័តកររបស់យើងសម្រាប់ការផ្តល់ដំបូន្មានដ៏មានតម្លៃ និងការគាំទ្រឥតឈប់ឈរ។ ខ្ញុំសូមថ្លែងអំណរគុណដល់ម្ចាស់ភាគហ៊ុន និងក្រុមប្រឹក្សាភិបាលរបស់យើងចំពោះទំនុកចិត្ត និងការជឿជាក់ របស់អ្នកចំពោះទិសដៅអាជីវកម្មរបស់យើង។ សូមអរគុណចំពោះការប្តេជ្ញាចិត្ត និងការលះបង់ដ៏មោះមុតរបស់បុគ្គលិក និងអ្នកគ្រប់គ្រងរបស់យើង។ ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដល់អតិថិជន ដែលតែងតែគាំទ្រ និងជឿជាក់មកលើយើងខ្ញុំ។ ខ្ញុំរង់ចាំស្វាគមន៍ អ្នកទាំងអស់គ្នា ចំពោះការចូលមកដល់នូវសករាជថ្មីនេះគឺ ធនាគារ អ៊ូរី (ខេមបូឌា)។



លោក គីម ហុងជូ

អគ្គនាយកប្រតិបត្តិ នៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក

ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ

1990s

ត្រូវបានបង្កើតឡើងជាសកម្មភាពមួយរបស់ **កម្មវិធីអភិវឌ្ឍន៍តំបន់របស់អង្គការទស្សនៈពិភពលោកកម្ពុជា**

2000

ត្រូវបានដាក់ឈ្មោះថា **កម្មវិធីអភិវឌ្ឍន៍ សហគ្រាសខ្នាតតូច** ដែលជាកម្មវិធីឥណទានមួយរបស់អង្គការទស្សនៈពិភពលោកកម្ពុជា

2003

បានក្លាយជាក្រុមហ៊ុនមួយបានចុះបញ្ជីដោយមានឈ្មោះថាជា **វីសិនហ្វាន់ (ខេមបូឌា) អិលធីឌី** នៅក្រសួងពាណិជ្ជកម្ម

2004

បានទទួលអាជ្ញាបណ្ណពីធនាគារជាតិ នៃកម្ពុជា ដោយមានឈ្មោះថាជា វីសិនហ្វាន់ (ខេមបូឌា) អិលធីឌី

2011

បានទទួលអាជ្ញាបណ្ណប្រកបអាជីវកម្មទទួលប្រាក់បញ្ញើពីធនាគារជាតិនៃកម្ពុជា

2016

- ការសម្ពោធជាផ្លូវការអគារការិយាល័យកណ្តាលថ្មី
- ទទួលបានការទទួលស្គាល់ថាជាស្ថាប័នបានគោរពតាមគោលការណ៍ការពារអតិថិជន យ៉ាងខ្ជាប់ខ្ជួន និង ត្រូវតាមស្តង់ដាអន្តរជាតិពី Smart Campaign

2018

- ផ្លាស់ប្តូរម្ចាស់ភាគហ៊ុន (មិថុនា 2018) ទៅជាធនាគារអ៊ូរី នៃប្រទេសកូរ៉េ ខាងត្បូង
- ប្តូរឈ្មោះទៅជា ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក

2017

- ទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធ ប្រភេទមាស ពីអគ្គនាយកដ្ឋានពន្ធដារ នៃព្រះរាជាណាចក្រកម្ពុជា
- ជាសមាជិកស្ថាបនិកនៃគម្រោងសេវាផ្ទេរមូលនិធិភ្លាមៗ របស់ធនាគារជាតិនៃកម្ពុជា

2019

- បានទទួលការអនុម័តជាគោលការណ៍ពីធនាគារជាតិនៃកម្ពុជា លើសំណើសុំគួបបញ្ចូលគ្នាជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ៊ូរី ហ្វាយនែន ខេមបូឌា ភីអិលស៊ី

2020

- ខែកុម្ភៈ ឆ្នាំ2020 ដំណើរការគួបបញ្ចូលគ្នាដោយជោគជ័យរវាងគ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក និងគ្រឹះស្ថាន អ៊ូរី ហ្វាយនែន (ខេមបូឌា) ភីអិលស៊ី
- ខែធ្នូ ឆ្នាំ2020 បញ្ចូលដើមទុន 100 លានដុល្លារអាមេរិក បន្ថែមពីម្ចាស់ភាគហ៊ុនធនាគារអ៊ូរី

2021

- ខែវិច្ឆិកា ឆ្នាំ2021 ទទួលបានអាជ្ញាបណ្ណថាជាធនាគារពាណិជ្ជពីធនាគារជាតិនៃកម្ពុជា និងខែធ្នូ ឆ្នាំ2021 ទទួលបានសិទ្ធិក្នុងការក្លាយខ្លួនទៅជាធនាគារពាណិជ្ជ ហើយផ្លាស់ប្តូរឈ្មោះទៅជា **ធនាគារអ៊ូរី (ខេមបូឌា) ម.ក**
- គិតត្រឹមខែធ្នូ ឆ្នាំ2021 ធនាគារអ៊ូរី (ខេមបូឌា) មាន៖

ចំនួនទ្រព្យសកម្មសរុប
1,162 លានដុល្លារអាមេរិក
(កំណើន 50.1%)

ចំនួនប្រាក់បញ្ញើសរុប
217 លានដុល្លារអាមេរិក
(កំណើន 74.7%)

ចំនួនឥណទានសរុប
928 លានដុល្លារអាមេរិក
(កំណើន 48.9%)

អំពី
ធនាគារ អ៊ូរី

ធនាគារ អ៊ូរី គឺជាម្ចាស់ភាគហ៊ុនតែមួយគត់របស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ដែលមានទីស្នាក់ការកណ្តាលនៅទីក្រុង សេអ៊ូល ប្រទេសកូរ៉េខាងត្បូង ត្រូវបានបង្កើតឡើងក្នុងឆ្នាំ1899 ជាធនាគារពាណិជ្ជឈានមុខគេមួយ នៅប្រទេសកូរ៉េ ដែលមានបណ្តាញអន្តរជាតិដ៏ធំទូលាយ នៅទូទាំងពិភពលោក ផ្តល់ជូននូវការវិនិយោគលើវិស័យពាណិជ្ជកម្ម និង វិស័យធនាគារយ៉ាងទូលំទូលាយតាមរយៈបណ្តាញប្រតិបត្តិការនៅក្នុងស្រុកចំនួន 747 សាខា និងក្រៅស្រុកចំនួន 451 សាខា នៅក្នុង 23 ប្រទេស។ ក្នុងឆ្នាំ2021នេះ ធនាគារ អ៊ូរី អបអរសាទរខួបទី 122 ដែលខ្លួនបានរកសាងប្រវត្តិសាស្ត្ររបស់ខ្លួននៅលើ ទីផ្សារហិរញ្ញវត្ថុអស់រយៈពេលជាងមួយសតវត្សរ៍មកហើយ។ ធនាគារ អ៊ូរី នឹងបន្តរីកចម្រើននៅសតវត្សបន្តបន្ទាប់ទៀត ដើម្បី ក្លាយជាស្ថាប័ន ហិរញ្ញវត្ថុដែលតែងតែនៅជិតលោកអ្នកបំផុត។

747 សាខា
បណ្ដាញប្រតិបត្តិការនៅក្នុងស្រុក

451 សាខា
បណ្ដាញប្រតិបត្តិការអន្តរជាតិនៅ 23 ប្រទេស

ឆ្នាំ 2021

គឺជាខួបទី 122 របស់ធនាគារ អ៊ូរី

រក្សាបាននូវប្រវត្តិសាស្ត្រកន្លងមកជាងមួយរយឆ្នាំ។ ធនាគារមានបំណងបន្តរីកលូតលាស់សម្រាប់សតវត្សមួយទៀត បន្តទៅមុខទៀត ដើម្បីក្លាយជាម៉ាកយីហោហិរញ្ញវត្ថុដែលតែងតែនៅទីនេះសម្រាប់លោកអ្នក។

អភិបាលកិច្ច សាជីវកម្ម

រចនាសម្ព័ន្ធរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

គិតត្រឹមថ្ងៃទី03 ខែមករា ឆ្នាំ2022


ក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការកម្រិត
ក្រុមប្រឹក្សាភិបាលគ្រប់គ្រងហានិភ័យ
គណៈកម្មាធិការ
សវនកម្មផ្ទៃក្នុង
អគ្គនាយកប្រតិបត្តិ
អគ្គនាយក
ហិរញ្ញវត្ថុ
អគ្គនាយក
ព័ត៌មានវិទ្យា
អគ្គនាយិកា
គ្រប់គ្រងហានិភ័យ
អគ្គនាយកដ្ឋាន
យុទ្ធសាស្ត្រគ្រប់គ្រង
អគ្គនាយកដ្ឋាន
យុទ្ធសាស្ត្រហិរញ្ញវត្ថុ
អគ្គនាយកដ្ឋាន
យុទ្ធសាស្ត្រព័ត៌មានវិទ្យា
មន្ត្រី
ប្រតិបត្តិតាម
សវនកម្ម
ផ្ទៃក្នុង
យុទ្ធសាស្ត្រ
និងរៀបចំផែនការ
កិច្ចការទូទៅ
បណ្តុះបណ្តាល
ធនធានមនុស្ស
ហិរញ្ញវត្ថុ
និងគណនេយ្យ
រតនាគារ
អភិវឌ្ឍន៍ព័ត៌មានវិទ្យា
ប្រតិបត្តិការព័ត៌មានវិទ្យា
គ្រប់គ្រងហានិភ័យ
ត្រួតពិនិត្យក្រោយ
បញ្ចេញប្រាក់កម្ចី

អំពី
ក្រុមប្រឹក្សាភិបាល

លោក យូន ហ៊ុនសង់

ប្រធានក្រុមប្រឹក្សាភិបាល

លោក យូន ទទួលបានបរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យជាតិសេអ៊ូល។ បច្ចុប្បន្នលោកជាសមាជិកនៃវិទ្យាស្ថានកូរ៉េផ្នែកវិញ្ញាបនបត្រគណនេយ្យករសាធារណៈ (KICPA)។

លោកបានចូលបម្រើការងារនៅ ធនាគារ អ៊ូរី ក្នុងខែឧសភា ឆ្នាំ2012។ មុនពេលនោះដែរ លោកបានធ្វើការនៅក្រុមហ៊ុនគណនេយ្យសាធារណៈធំៗ តាំងពីឆ្នាំ2000 មកម្ល៉េះ។ អាជីពរបស់លោកបានចាប់ផ្តើមជាមួយ PwC ដែលជាក្រុមហ៊ុនគណនេយ្យពិភពលោក។ អំឡុងពេលលោកធ្វើការនៅក្រុមហ៊ុនគណនេយ្យ លោកមានបទពិសោធន៍លើមុខជំនាញផ្សេងៗដូចជាសវនកម្ម ប្រឹក្សាយោបល់ និងជាទីប្រឹក្សាលើប្រតិបត្តិការក្រុមហ៊ុនជាមួយនឹងក្រុមហ៊ុនសវនកម្ម Ernst & Young ។ បទពិសោធន៍ទាំងនោះបានជួយលោកឱ្យមានទស្សនៈប្រកបដោយតុល្យភាពពីគ្រប់ផ្នែក ក្នុងការកំណត់បញ្ហាចំបង វិភាគមូលហេតុ និងផលប៉ះពាល់បានយ៉ាងស្ទាត់ជំនាញ។ បច្ចុប្បន្ន លោកជានាយករងគ្រប់គ្រងទូទៅ នៅក្នុងនាយកដ្ឋានយុទ្ធសាស្ត្រធុរកិច្ចសកល នៅធនាគារ អ៊ូរី។

បច្ចុប្បន្ន លោក យូន បាននិងកំពុងបម្រើការជាប្រធានក្រុមប្រឹក្សាភិបាល ក្រោយពីការរួមបញ្ចូលគ្នារវាងគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា និង គ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក ។

លោក គីម ហុង ជូ

ម្ចាស់ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល
និងជាអគ្គនាយកប្រតិបត្តិ

លោក គីម ហុង ជូ បានបញ្ចប់ជំនាញផ្នែកគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យជាតិ សេអ៊ូលនៃប្រទេសកូរ៉េ។ លោកបានចូលរួមបម្រើការងារជាមួយធនាគារ អ៊ូរី និងមាននូវបទពិសោធន៍យ៉ាងច្រើនលើវិស័យធនាគារ និងហិរញ្ញវត្ថុ ជាពិសេសលោកមានឯកទេសពាក់ព័ន្ធនឹងពាណិជ្ជកម្មសកល។ លោកបានធ្វើការនៅនាយកដ្ឋានយុទ្ធសាស្ត្រសកលជាង 8 ឆ្នាំ។ លោកបានចូលរួមចំណែកក្នុងប្រតិបត្តិការទិញលក់ភាគហ៊ុនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម្ល៉ះហ្វាយនែន ក្នុងឆ្នាំ 2014 និងក្រោយមកបានរួមបញ្ចូលគ្នាជាមួយនឹងគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា និង គ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក នៅដើមឆ្នាំ 2020។ បន្ទាប់មក លោកក៏ត្រូវបានតែងតាំងជាអគ្គនាយកហិរញ្ញវត្ថុនៃ គ្រឹះស្ថានដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក។ នៅចុងឆ្នាំ2021 ក្រោយទទួលបានអនុម័តពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម លោកក៏បានក្លាយជាភាគទុនិក របស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ពីមុនឈ្មោះថា ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក)។

នៅដើមឆ្នាំ2022 លោក គីម ហុង ជូ ត្រូវបានតែងតាំងជាអគ្គនាយកប្រតិបត្តិថ្មីនៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

លោកស្រី ហ្វីអូណា វ៉ាយត៍

សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

លោកស្រី វ៉ាយត៍ ដែលមានសញ្ជាតិនូវែលសេឡង់ បានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (រួមទាំងអតីតវីសិនហ្វាន់ ខេមបូឌា) តាំងពីខែមករា ឆ្នាំ2013។ លោកស្រីមានបទពិសោធន៍ 8ឆ្នាំ ទាក់ទងនឹងការរៀបចំបទប្បញ្ញត្តិនៅប្រទេសនូវែលសេឡង់ ដែលមុនការងារនេះផងដែរ លោកស្រីមានបទពិសោធន៍ 23ឆ្នាំលើផ្នែកធនាគារ នៅប្រទេសនូវែលសេឡង់ ដែលបូករួមទាំងបទពិសោធន៍12ឆ្នាំ ទាក់ទងនឹងការងារគ្រប់គ្រងហានិភ័យរូបិយប័ណ្ណអន្តរជាតិ។ លោកស្រី វ៉ាយត៍ បានសិក្សាផ្នែកធុរកិច្ចនិងការគ្រប់គ្រងអន្តរជាតិ នៅសាកលវិទ្យាល័យ Massey ក្នុងឆ្នាំ2007។ លោកស្រី វ៉ាយត៍ បច្ចុប្បន្នធ្វើការជាអ្នកដឹកនាំឯកទេស ផ្នែកប្រព័ន្ធហិរញ្ញវត្ថុបញ្ចូលគ្នា នៅក្នុងអាជ្ញាធរទីផ្សារហិរញ្ញវត្ថុ ក្នុងប្រទេសនូវែលសេឡង់ ហើយមុននេះបន្តិចលោកស្រីធ្លាប់ធ្វើជាបរិធនបាលទាយករយៈពេលមួយអាណត្តិជូនក្រុមប្រឹក្សាភិបាលរបស់អង្គការទស្សនៈពិភពលោកនូវែលសេឡង់។

លោក គី ប៊ុនទ្រាន

សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

លោក គី ប៊ុនទ្រាន បានចូលរួមជាមួយធនាគារ អ៊ូរី (ខេមបូឌា) ម.ក ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ។ លោកទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្ត្រនិងវិទ្យាសាស្ត្រនយោបាយ ព្រមទាំងវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ មុននេះ លោកជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៃគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា ចាប់ពីឆ្នាំ 2018 ដល់ត្រឹមដើមឆ្នាំ 2020។ ក្រៅពីនេះទៀត លោកក៏ជាសមាជិកមួយរូបនៃគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា និងជាសាស្ត្រាចារ្យបង្រៀនក្រៅម៉ោងនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចផងដែរ។

បន្ទាប់ពីការគួបបញ្ចូលគ្នាដោយជោគជ័យរវាងគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា និងគ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក លោក គី ប៊ុនទ្រាន ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

អំពី
គណៈគ្រប់គ្រងជាន់ខ្ពស់

លោក គីម ហុង ជូ

ម្ចាស់ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល
និងជាអគ្គនាយកប្រតិបត្តិ

លោក គីម ហុង ជូ បានបញ្ចប់ជំនាញផ្នែកគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យជាតិ សេអ៊ូលនៃប្រទេសកូរ៉េ។ លោក បានចូលរួមបម្រើការងារជាមួយធនាគារ អ៊ូរី និងមាននូវបទពិសោធន៍យ៉ាងច្រើនលើវិស័យធនាគារ និងហិរញ្ញវត្ថុ ជាពិសេសលោកមានឯកទេសពាក់ព័ន្ធនឹងពាណិជ្ជកម្មសកល។ លោកបានធ្វើការនៅនាយកដ្ឋានយុទ្ធសាស្រ្តសកលជាង 8 ឆ្នាំ។ លោកបានចូលរួមចំណែកក្នុងប្រតិបត្តិការទិញលក់ភាគហ៊ុនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម្ល៉ិះហ្វាយនែន ក្នុងឆ្នាំ 2014 និងក្រោយមកបានរួមបញ្ចូលគ្នាជាមួយនឹងគ្រឹះស្ថានអ៊ូរី ហ្វាយនែន ខេមបូឌា និង គ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក នៅដើមឆ្នាំ 2020។ បន្ទាប់មក លោកក៏ត្រូវបានតែងតាំងជាអគ្គនាយកហិរញ្ញវត្ថុនៃ គ្រឹះស្ថានដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក។ នៅចុងឆ្នាំ2021 ក្រោយទទួលបានអនុម័តពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម លោកក៏បានក្លាយជាភាគទុនិក របស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ពីមុនឈ្មោះថា ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក)។

នៅដើមឆ្នាំ2022 លោក គីម ហុង ជូ ត្រូវបានតែងតាំងជាអគ្គនាយកប្រតិបត្តិថ្មីនៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

លោក យូ ខ្វាងហ៊ី

បេក្ខភាពសមាជិកក្រុមប្រឹក្សាភិបាល
និងជាអគ្គនាយកគាំទ្រប្រតិបត្តិការ

លោក យូ ខ្វាងហ៊ី បានចូលរួមជាមួយធនាគារ អ៊ូរី ម.ក (អតីត ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក) ចាប់តាំងពីឆ្នាំ 2020 ក្រោយការគួបបញ្ចូលគ្នា ក្នុងតួនាទីជានាយកគ្រប់គ្រងយុទ្ធសាស្រ្ត ហើយក្រោយមកជាប្រធានអគ្គនាយកដ្ឋានយុទ្ធសាស្រ្តគ្រប់គ្រង។ បន្ទាប់ពីបានកម្លាយខ្លួនទៅជាធនាគារពាណិជ្ជ លោកត្រូវបានតែងតាំងជា អគ្គនាយកគាំទ្រប្រតិបត្តិការ។

លោកធ្លាប់កាន់តួនាទីជានាយកសវនកម្មផ្ទៃក្នុង ខណៈលោកកំពុងធ្វើការឱ្យ អ៊ូរី ហ្វាយនែន (ខេមបូឌា) ភីអិលស៊ី។ មុននឹងធ្វើការនៅប្រទេសកម្ពុជា លោកមានបទពិសោធន៍ជាច្រើនប្រមាណជិត16ឆ្នាំ ជាមួយនឹងធនាគារ អ៊ូរី របស់កូរ៉េ ហើយបទពិសោធន៍ដ៏លេចធ្លោរបស់លោកមួយផងដែរនោះ គឺនៅក្នុងវិស័យយុទ្ធសាស្រ្តប្រតិបត្តិការ ទាក់ទងនឹងធនាគារសាជីវកម្ម និងធុរកិច្ចខ្នាតតូចនិងមធ្យម។

លោកទទួលបានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Sungkyunkwan ក្នុងប្រទេសកូរ៉េ។

លោក ខាង ម៉ុងណាម

អគ្គនាយកហិរញ្ញវត្ថុ

លោក ខាង ម៉ុងណាម បានចូលរួមជាមួយនឹង ធនាគារ អ៊ូរី ហើយធ្លាប់ទទួលបន្ទុកផ្នែកជាច្រើនដូចជាពាណិជ្ជកម្មអន្តរជាតិ ធុរកិច្ច Fintech យុទ្ធសាស្ត្រឌីជីថល ក៏ដូចជាផ្នែកបណ្តុះបណ្តាលអស់រយៈពេលជិត 19 ឆ្នាំ។ លោកបានចូលរួមជាមួយ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (អតីត ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក) ចាប់តាំងពីខែមិថុនា ឆ្នាំ 2018 ហើយទទួលបន្ទុកជានាយកផ្នែកយុទ្ធសាស្ត្រហិរញ្ញវត្ថុ ដែលក្រោយមកក៏ក្លាយជាប្រធានអគ្គនាយកដ្ឋានយុទ្ធសាស្ត្រហិរញ្ញវត្ថុ ដែលត្រូវរាយការណ៍ទៅអគ្គនាយកហិរញ្ញវត្ថុ។

បន្ទាប់ពីបានកម្លាយខ្លួនទៅជាធនាគារពាណិជ្ជប្រកបដោយភាពជោគជ័យ លោកក៏ត្រូវបានតែងតាំងជាអគ្គនាយកហិរញ្ញវត្ថុ របស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកភាសា នៅសកលវិទ្យាល័យកូរ៉េ នៅក្នុងឆ្នាំ 2003 ហើយលោកក៏ត្រូវបានគេទទួលស្គាល់ថាជាអ្នកឯកទេសផ្នែកប្តូរប្រាក់បរទេស និងជាទីប្រឹក្សាវិនិយោគមូលនិធិផងដែរ។

លោក ហ៊ុន សុភ័ក្ត្រ

អគ្គនាយកប្រតិបត្តិការ ក្រុមធុរកិច្ច 1

លោក ហ៊ុន សុភ័ក្ត្រ គឺជាអគ្គនាយកប្រតិបត្តិការ ក្រុមធុរកិច្ច1 នៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក។ លោកមានបទពិសោធន៍រយៈពេល 18ឆ្នាំ ក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។ បន្ទាប់ពីទទួលបានបទពិសោធន៍11ឆ្នាំ នៅធនាគារ អេស៊ីលីដា ក្នុងតួនាទីជានាយករងឥណទានសាជីវកម្ម លោកបានបង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយដោយជោគជ័យក្រោមឈ្មោះថា ហ្គ្រីន សេនត្រល់ ចាប់តាំងពីខែមេសា ឆ្នាំ2008 ដល់ ខែវិច្ឆិកា ឆ្នាំ 2010។ ហើយគាត់គឺជាស្ថាបនិកនៃគ្រឹះស្ថាន ម្លិះ ហ្វាយនែន ចាប់ពីខែវិច្ឆិកា ឆ្នាំ 2010 និងបានកម្លាយខ្លួនដោយជោគជ័យជា គ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា ដែលជាផ្នែកមួយនៃធនាគារ អ៊ូរី ប្រទេសកូរ៉េ ដែលត្រូវបានស្គាល់ថាជាគ្រឹះស្ថានហិរញ្ញវត្ថុសកល ហើយលោកមានតួនាទីជានាយកគ្រប់គ្រងទូទៅ។

ចាប់តាំងពីមានការគួបបញ្ចូលជាមួយនឹងធនាគារ អ៊ូរី ពីឆ្នាំ2014 លោក ហ៊ុន សុភ័ក្ត្រ ដើរតួនាទីយ៉ាងសំខាន់ជានាយកគ្រប់គ្រងទូទៅ និងដឹកនាំប្រតិបត្តិការអាជីវកម្មទាំងមូលកើនឡើងជាលំដាប់ទាំងបរិមាណ និងគុណភាពនៃឥណទានដែលធ្វើឱ្យគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុលេខ1 ចាប់តាំងពីឆ្នាំ 2018 ផ្អែកលើគុណភាពឥណទាន ទ្រព្យសកម្ម និងប្រាក់ចំណេញ។ លោកទទួលបានបរិញ្ញាបត្រផ្នែកគ្រប់គ្រង និងថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុពីសកលវិទ្យាល័យជាតិគ្រប់គ្រងនៅកម្ពុជា ព្រមទាំងបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដែលទាក់ទងនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ ស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។

លោក ព្រាប ពិសិដ្ឋ

អគ្គនាយកប្រតិបត្តិការ ក្រុមធុរកិច្ច 2

មានស្រុកកំណើតនៅខេត្តកណ្តាល លោក ព្រាប ពិសិដ្ឋ មានបទពិសោធន៍ច្រើនជាងមួយទសវត្សរ៍លើវិស័យអភិវឌ្ឍន៍ បម្រើអតិថិជន ការគ្រប់គ្រងកម្មវិធីឧបត្ថម្ភ ទំនាក់ទំនងសាធារណៈ និងរដ្ឋបាល ព្រមទាំង ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ មុនពេលដែលគាត់ចូលខ្លួនប្រលូកក្នុងវិស័យហិរញ្ញវត្ថុ។ អាជីពរបស់លោកមានជាមួយធនាគារ អ៊ូរី (ខេមបូឌា) ម.ក គឺចាប់ផ្តើមតាំងពីឆ្នាំ 2008។ កាលពីមុនមកលោកបានបម្រើការងារឱ្យអង្គការទស្សនៈពិភពលោកអន្តរជាតិ (កម្ពុជា) និងលេខាធិការដ្ឋានមុខងារសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។

លោក ព្រាប ពិសិដ្ឋ ទទួលបានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យ Anglia Ruskin, Global FTMS Campus នៅប្រទេសសឹង្ហបូរី ។ លោកក៏មានបរិញ្ញាបត្រ ផ្នែកសេដ្ឋកិច្ច ក្នុងការគ្រប់គ្រងសហគ្រាស និងវិញ្ញាបត្ររងនៃវិជ្ជាជីវៈច្បាប់ មកពីសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងប្រទេសកម្ពុជាផងដែរ។

លោកស្រី តុប សុក្រសម្ភារ

អគ្គនាយិកាគ្រប់គ្រងហានិភ័យ

លោកស្រី សម្ភារ បានចូលរួមការងារជាមួយធនាគារ អ៊ូរី (ខេមបូឌា) ម.ក នៅក្នុងឆ្នាំ 2002 ក្នុងតួនាទីជានាយិកាហិរញ្ញវត្ថុ និងកិច្ចការរដ្ឋបាល។ លោកស្រីបានទទួលតំណែងជាអគ្គនាយិកាប្រតិបត្តិការក្នុងឆ្នាំ 2008 ក្រោយមកក៏ផ្លាស់ប្តូរតួនាទីទៅជាអគ្គនាយិកាគ្រប់គ្រងហានិភ័យនៅក្នុងខែមេសា ឆ្នាំ2021។ មុនពេលលោកស្រីបានចូលរួមនឹងធនាគារ អ៊ូរី (ខេមបូឌា) ម.ក លោកស្រីបានបម្រើការងារជាសវនករជាន់ខ្ពស់នៅក្រុមហ៊ុន Ernst & Young និង Price Water House Coopers។ បច្ចុប្បន្នលោកស្រីគឺជាសមាជិកក្រុមប្រឹក្សាភិបាលនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។

លោកស្រីមានបទពិសោធន៍ច្រើនជាង 20 ឆ្នាំលើផ្នែកហិរញ្ញវត្ថុ គណនេយ្យ ការគ្រប់គ្រង យុទ្ធសាស្ត្រ និងផែនការធុរកិច្ច សវនកម្ម រដ្ឋបាល និងប្រាស្រ័យទាក់ទង។

លោកស្រីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ និងថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសកលវិទ្យាល័យជាតិគ្រប់គ្រងនៅប្រទេសកម្ពុជា។ លោកស្រីបានទទួលវិញ្ញាបនបត្រថ្នាក់ជំនាញបច្ចេកទេសជាន់ខ្ពស់ផ្នែកគណនេយ្យ និងរដ្ឋបាលពីមហាវិទ្យាល័យ Noisy Le Grand នៃប្រទេសបារាំង។

លោក សុផល សុផាត

អគ្គនាយកឥណទាន

លោក សុផាត បានចូលបម្រើការងារនៅធនាគារ អ៊ូរី (ខេមបូឌា) ម.ក នៅឆ្នាំ 2018 ក្នុងនាមជាប្រធានផ្នែកវិភាគឥណទាន មុនពេលក្លាយជាអគ្គនាយកឥណទាន នៅខែមីនា ឆ្នាំ2021។ មុនពេលលោកចូលរួមនឹង ធនាគារ អ៊ូរី (ខេមបូឌា) ម.ក លោក សុផាត បានបម្រើការជាអគ្គនាយកប្រតិបត្តិការ និងឥណទាននៅធនាគារឯកទេសខ្មែរ ប្រធានផ្នែកឥណទាន នៅធនាគារជប៉ុនម៉ារ៉ូហាន់ និងជាអ្នកគ្រប់គ្រងផ្នែកឥណទាន នៅធនាគារអេស៊ីលីដាភីអិលស៊ី។

លោកមានបទពិសោធន៍កាងារជាង20ឆ្នាំ ក្នុងវិស័យធនាគារ ដោយបម្រើសេវាកម្មក្នុងផ្នែកផ្សេងៗដូចជាទីផ្សារ ឥណទាន ប្រតិបត្តិការ និងដោះស្រាយបំណុល។

លោកទទួលបានបរិញ្ញាបត្រផ្នែកវិភាគសេដ្ឋកិច្ចពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ចពីសាកលវិទ្យាល័យន័រតុន នៅកម្ពុជា និងសាកលវិទ្យាល័យ Ateneo de Zamboanga នៅប្រទេស ហ្វីលីបពីន។

លោក វ៉ា លួង សូរិន

អគ្គនាយកព័ត៌មានវិទ្យា

លោក សូរិន បានចូលរួមជាមួយធនាគារ អ៊ូរី (ខេមបូឌា) ម.ក ក្នុងឆ្នាំ 2015។ លោក សូរិនជាអ្នកដឹកនាំផ្នែកយុទ្ធសាស្ត្រព័ត៌មានវិទ្យា ជាមួយនឹងបទពិសោធន៍ជាង15ឆ្នាំ លើការគាំទ្រដោយជោគជ័យជាច្រើនខាងបច្ចេកវិទ្យា ការអនុវត្ត និងការរួមចំណែកលើកំណើនធុរកិច្ចតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឱ្យមានប្រយោជន៍ ការកាត់បន្ថយការចំណាយប្រតិបត្តិការ ការបង្កើនគុណតម្លៃនៃអាជីវកម្មនិងម្ចាស់ហ៊ុន។ បទពិសោធន៍ក្នុងសហគ្រាសព័ត៌មានវិទ្យានៃក្រុមហ៊ុនអភិវឌ្ឍន៍ Software Telco, ISP, Tech startup និងវិស័យធនាគារ ព្រមទាំងក្រុមហ៊ុនពហុជាតិដែលមានវប្បធម៌ចម្រុះ។ ជំនាញគោលរបស់លោកសូរិនរួមមាន៖ ការផ្លាស់ប្រែផ្នែកឌីជីថល ការអភិវឌ្ឍ Agile Software និងEnterprise Architecture អភិបាលកិច្ចនៃសហគ្រាសព័ត៌មានវិទ្យា ការគ្រប់គ្រងគម្រោងព័ត៌មានវិទ្យា ប្រតិបត្តិការព័ត៌មានវិទ្យា ការអភិវឌ្ឍន៍ព័ត៌មានវិទ្យា បច្ចេកវិទ្យាសន្តិសុខ ការច្នៃឡើងវិញ និងបង្កើតដំណើរការ អាជីវកម្មតាមបែបស្វ័យប្រវត្តិ និងរៀបចំផែនការថវិកានិងការគ្រប់គ្រងថវិកា។

សូរិនបានចូលរួមនិងទទួលបានការបណ្តុះបណ្តាលយ៉ាងល្អនៅក្នុងវគ្គបណ្តុះបណ្តាលបច្ចេកទេស និងមិនបច្ចេកទេសផ្សេងៗទាំងក្នុងនិងក្រៅស្រុកដូចជាប្រព័ន្ធទូទាត់ប្រាក់ ប្រព័ន្ធគិតប្រាក់និងដាក់អត្រា ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធគ្រប់គ្រងគុណភាពស្តង់ដា ISO 9001: 2000 ផែនការនៃភាពដឹកនាំ ការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម បច្ចេកវិទ្យាសន្តិសុខនិងសវនកម្មព័ត៌មានវិទ្យា ITIL ការបណ្តុះបណ្តាលបច្ចេកទេស T24 ។ លោកសូរិនក៏ត្រូវបានអញ្ជើញឱ្យធ្វើការបង្រៀននៅសាកលវិទ្យាល័យមួយចំនួននៅក្នុងប្រទេសកម្ពុជា។ បន្ថែមលើការតែងតាំងតួនាទីជាអគ្គនាយកព័ត៌មានវិទ្យានាពេលបច្ចុប្បន្ន លោកក៏ទទួលបន្ទុកតួនាទីជាអគ្គនាយកសន្តិសុខព័ត៌មានវិទ្យា តួនាទីជាប្រធានគណៈកម្មាធិការព័ត៌មានវិទ្យា និងគណៈកម្មាធិការយុទ្ធសាស្ត្រព័ត៌មានវិទ្យា និងជាសមាជិកគណៈកម្មាធិការប្រតិបត្តិនៅធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រព័ត៌មានវិទ្យាពីសកលវិទ្យាល័យ KMUT ដែលនៅភាគខាងជើងនៃទីក្រុងបាងកក ក្នុងឆ្នាំ 2009។

ការគ្រប់គ្រង
ហានិភ័យ

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក កំពុងបន្ត និងបង្កើនប្រព័ន្ធគ្រប់គ្រងហានិភ័យ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ និងមុខងារត្រួតពិនិត្យ សន្តិសុខ និងសុវត្ថិភាពទៅលើគ្រប់ផ្នែករបស់ធនាគារ។

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានអនុវត្តប្រព័ន្ធគ្រប់គ្រងហានិភ័យរបស់ខ្លួនដោយផ្អែកលើគោលការណ៍ "ខ្សែការពារបី" ដើម្បីគាំទ្រដល់រចនាសម្ព័ន្ធអភិបាលកិច្ចហានិភ័យ។

រចនាសម្ព័ន្ធអភិបាលកិច្ចរួមមាន គណនេយ្យភាព ទំនួលខុសត្រូវ ឯករាជ្យភាព ការរាយការណ៍ ការទំនាក់ទំនង និងតម្លាភាព ទាំងខាងក្នុង ព្រមទាំងជាមួយភាគីពាក់ព័ន្ធខាងក្រៅរបស់យើង។

វិធីសាស្ត្រគ្រប់គ្រងហានិភ័យរបស់ធនាគាររួមមាន ការកំណត់អត្តសញ្ញាណ ការវាយតម្លៃ ការកាត់បន្ថយ និងត្រួតពិនិត្យហានិភ័យសំខាន់ៗ ដែលត្រូវបានអនុវត្តនៅគ្រប់ផ្នែកទាំងអស់នៃអាជីវកម្មរបស់ធនាគារ។

ទំនួលខុសត្រូវចំពោះការគ្រប់គ្រងហានិភ័យ មាននៅគ្រប់កម្រិតការងារទាំងអស់ របស់ធនាគារ។ បុគ្គលិកគ្រប់រូបមានទំនួលខុសត្រូវលើការគ្រប់គ្រងហានិភ័យទៅតាមផ្នែកនីមួយៗក្នុងការប្រតិបត្តិការងារ។ ពួកគេត្រូវតែយល់ និងគ្រប់គ្រងទៅលើហានិភ័យសំខាន់ៗដែលអាចកើតមាននៅក្នុងអាជីវកម្ម។ វិធីសាស្ត្រនេះត្រូវបានអនុវត្តដើម្បីពង្រឹងប្រសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យប្រតិបត្តិការ ដែលត្រូវពឹងផ្អែកលើទំនួលខុសត្រូវរបស់បុគ្គលិកនីមួយៗ និងការត្រួតពិនិត្យដោយឯករាជ្យ។

វិធានការគ្រប់គ្រងហានិភ័យ

គណៈគ្រប់គ្រងរបស់ធនាគារជឿជាក់ថា កត្តាហានិភ័យអាចត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព និងកាត់បន្ថយ ដើម្បីបន្ថយកម្រិតសក្តានុពលនៃការបាត់បង់ទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ។



1 វិធានការគ្រប់គ្រងហានិភ័យឥណទាន

- អនុវត្តដោយប្រុងប្រយ័ត្ននូវគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ស្តីអំពីសំពៀតឥណទានរៀបចំសារឡើងវិញ ក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-19 ដោយបង្កើតយុទ្ធសាស្ត្រ និងបង្កើតក្រុមការងារឯករាជ្យមួយ ដើម្បីវាយតម្លៃលើសំណើរបស់អតិថិជនដែលរងផលប៉ះពាល់ដោយការរីករាលដាលនៃជំងឺកូវីដ-19 មុននឹងបញ្ជូនទៅកាន់គណៈគ្រប់គ្រង ដើម្បីធ្វើការពិនិត្យ និងការអនុម័ត។
- ធនាគារគ្រប់គ្រងយ៉ាងសកម្មទៅលើហានិភ័យទៅលើផលប័ត្រឥណទាន ដើម្បីធានាបាននូវការធ្វើពិពិធកម្មផលប័ត្រឥណទាន ហើយថែមទាំងត្រួតពិនិត្យយ៉ាងតឹងរ៉ឹង និងធ្វើស្រ្តេសតេស្តទៅលើសំពៀតឥណទានដែលបានរៀបចំសារឡើងវិញផងដែរ។
- ធនាគារមានគោលនយោបាយគ្រប់គ្រងឥណទាន សៀវភៅណែនាំ និងការណែនាំដើម្បីកាត់បន្ថយហានិភ័យឥណទាន។ ជាពិសេស ធនាគារមានក្រុមការងារជំនាញដែលធ្វើការដោយឯករាជ្យក្នុងការវិភាគឥណទាន ព្រមទាំងអនុម័តប្រាក់កម្ចី។ លើសពីនេះទៅទៀត យើងក៏បានដាក់ក្រុមការងារត្រួតពិនិត្យក្រោយបញ្ចេញប្រាក់កម្ចី ដើម្បីពិនិត្យមើលភាពសមស្របនៃប្រាក់កម្ចីក្រោយការអនុម័ត គុណភាពឯកសារ ការកំណត់នូវបញ្ហាឱ្យទាន់ពេលវេលា និងផ្តល់អនុសាសន៍ដល់បុគ្គលិកក្នុងការធ្វើការកែលម្អ។

2 វិធានការគ្រប់គ្រងហានិភ័យសន្ទនីយភាព

- ធនាគាររក្សាបាននូវ ភាពចាំបាច់ និងស្ថិរភាពនៃអនុបាតសន្ទនីយភាពដោយរក្សាបាននូវសំពៀតទ្រព្យសកម្ម
- ធនាគារបានធ្វើស្ត្រេសតេស្តលើស្ថានភាពសន្ទនីយភាពដើម្បីវាយតម្លៃសម្ពតិកម្មរបស់ហានិភ័យតាមសេណារីយ៉ូឆ្ពោះទៅកាន់ការកែសម្រួល និងរៀបចំផែនការសកម្មភាពគ្រប់គ្រងមូលនិធិ និងសន្ទនីយភាពឱ្យបានល្អ។

3 វិធានការគ្រប់គ្រងហានិភ័យប្រតិបត្តិការ

ស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ស្តីអំពីការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-19 ធនាគារបានអនុវត្ត និងដាក់ចេញនូវវិធានការ សេចក្តីណែនាំយ៉ាងប្រុងប្រយ័ត្ន ដើម្បីទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-19 និងធានាបាននូវនិរន្តភាពអាជីវកម្ម ដូចជា៖

- ពង្រឹង និងយកចិត្តទុកដាក់ លើការទប់ស្កាត់ការចម្លងមេរោគកូវីដ-19 ជាយថាហេតុដល់បុគ្គលិក និងអតិថិជនស្របតាមការកំណត់របស់ក្រសួងសុខាភិបាល និងធនាគារជាតិនៃកម្ពុជា។
- រៀបចំ និងអនុញ្ញាតឱ្យបុគ្គលិកពាក់ព័ន្ធធ្វើការពីផ្ទះ អនុវត្តស្របតាមការណែនាំរបស់ក្រសួងសុខាភិបាល និងធនាគារជាតិនៃកម្ពុជា។
- បង្កើតផែនការគ្រាអាសន្ន ដើម្បីធានាបាននូវដំណើរការនៃប្រតិបត្តិការរបស់ធនាគារ ក្នុងករណីដែលការិយាល័យសាខាត្រូវបានបិទដោយសារជំងឺរាតត្បាត មេរោគកូវីដ-19 ដូច្នេះធនាគារនៅតែអាចបន្តប្រតិបត្តិការបានដោយគ្មានឧបសគ្គ។
- ណែនាំសេវាទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់ផ្ទាល់ដល់អតិថិជនដូចជា សេវាបាគង សេវាផ្ទេរមូលនិធិភ្លាមៗ ប្រព័ន្ធអនឡាញ ការទូទាត់វិក្កយបត្រ (សេវាស្វ័យប្រវត្តិ) នៅក្នុងសេវាធនាគារចល័ត ដែលអាចប្រតិបត្តិការពីផ្ទះ គ្រប់ទីកន្លែង និងគ្រប់ពេលវេលា។

លើសពីនេះ ធនាគារ ក៏បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការកំណត់ ការវាយតម្លៃ និងកាត់បន្ថយហានិភ័យប្រតិបត្តិការ ដើម្បីកាត់បន្ថយការខាតបង់ចំបងៗ និងធានាបាននូវភាពរលូននៃប្រតិបត្តិការអាជីវកម្ម។ ហានិភ័យតាមអ៊ីនធឺណែត និងហានិភ័យផ្នែកបច្ចេកវិទ្យាផ្សេងទៀតកំពុងតែកើនឡើងឥតឈប់ឈរ ដូច្នេះធនាគារបានបង្កើតនូវគោលនយោបាយ សៀវភៅណែនាំ គោលការណ៍ណែនាំសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ។ ទាំងសៀវភៅណែនាំ និងគោលការណ៍ណែនាំទាំងនោះត្រូវបានអនុវត្តស្របតាមគោលការណ៍គ្រប់គ្រងហានិភ័យផ្នែកបច្ចេកវិទ្យារបស់ធនាគារជាតិនៃកម្ពុជា។

ការប្រតិបត្តិតាម

មុខងារប្រតិបត្តិតាម គឺជាខ្សែការពារទី 2 ដែលដឹកនាំដោយប្រធាននាយកដ្ឋានមុខងារប្រតិបត្តិតាម និងរាយការណ៍ដោយផ្ទាល់ទៅសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ។ មុខងារប្រតិបត្តិតាមជាកន្លែងដែលមានប្រព័ន្ធគ្រប់គ្រងគ្រប់ជ្រុងជ្រោយដោយមានចាប់ពីគោលការណ៍ សៀវភៅណែនាំ ការណែនាំ របាយការណ៍ និងឧបករណ៍ត្រួតពិនិត្យ និងការធ្វើតេស្ត ដើម្បីគ្រប់គ្រងហានិភ័យទាក់ទងនឹងមុខងារប្រតិបត្តិតាមរបស់ធនាគារ។

តួនាទីសំខាន់ៗ នៃមុខងារប្រតិបត្តិតាមគឺ

1. ផ្តល់ដំបូន្មាន
2. ផ្តល់ការណែនាំ និងការអប់រំ
3. កំណត់ វាស់វែង និងវាយតម្លៃហានិភ័យនៃការប្រតិបត្តិតាម
4. ការត្រួតពិនិត្យ ការធ្វើតេស្ត និងរាយការណ៍
5. ទំនួលខុសត្រូវផ្នែកច្បាប់ និងទំនាក់ទំនង
6. កម្មវិធីប្រតិបត្តិតាម

មុខងារនេះមានការគាំទ្រយ៉ាងខ្លាំងពីគណៈគ្រប់គ្រងក្រុមប្រឹក្សាភិបាល ជាមួយនឹងការណែនាំពិសេសពីធនាគារជាតិនៃកម្ពុជា អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងនិយតករផ្សេងៗទៀត។ លើសពីនេះ ការណែនាំ និងលក្ខខណ្ឌសម្រាប់មុខងារប្រតិបត្តិតាមពីក្រុមហ៊ុនមេក៏ដើរតួយ៉ាងសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពនៃមុខងារនេះផងដែរ។

ឆ្នាំ 2021 គឺជាឆ្នាំដែលមានការផ្លាស់ប្តូរ និងជាឆ្នាំដ៏រំភើបសម្រាប់អ្នករាល់គ្នា!

នាយកដ្ឋានមុខងារប្រតិបត្តិតាមបានគាំទ្រគម្រោងការផ្លាស់ប្តូរនេះដោយជោគជ័យ រួមមានការពិនិត្យឡើងវិញនូវបទប្បញ្ញត្តិផ្ទៃក្នុងរបស់ធនាគារទាំងអស់ដែលមានប្រហែលជាង 200 ការបោះពុម្ពផ្សាយទាំងអស់ និងគម្រោងផ្សេងៗផ្សេងទៀតពាក់ព័ន្ធនឹងផលិតផល និងសេវាកម្មថ្មីៗ ដើម្បីគាំទ្រដល់អាជីវកម្មឱ្យដំណើរការដូចធម្មតា។ ជាចុងក្រោយនាយកដ្ឋានមុខងារប្រតិបត្តិតាមក៏ធ្វើការពាក់ព័ន្ធនឹងរៀបចំផែនការយថាភាពក្នុងអំឡុងពេលការផ្ទុះឡើងនៃមេរោគកូវីដ 19 ផងដែរ ជាពិសេសក្នុងអំឡុងពេលនៃការបិទខ្ទប់។

សវនករផ្ទៃក្នុង

មុខងារសវនកម្មផ្ទៃក្នុងមានឯករាជ្យភាពពេញលេញលើប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារ និងមុខងារត្រួតពិនិត្យអចិន្ត្រៃយ៍ ដែលដឹកនាំដោយប្រធានសវនកម្មផ្ទៃក្នុង "HIA"។ ដើម្បីធានានូវឯករាជ្យភាពរបស់សវនកម្មផ្ទៃក្នុង HIA ត្រូវរាយការណ៍ដោយផ្ទាល់ទៅប្រធានគណៈកម្មាធិការសវនកម្ម ក្រោយមកហៅថា "AC" ហើយ AC នឹង

- អនុម័តផែនការសវនកម្មផ្ទៃក្នុងផ្អែកលើហានិភ័យ និងអនុម័តគម្រោងថវិកា និងធនធានរបស់សវនកម្មផ្ទៃក្នុង
- ទទួលរបាយការណ៍ពី HIA អំពីលទ្ធផលនៃសវនកម្មផ្ទៃក្នុង ដែលទាក់ទងនឹងស្ថានភាពនៃការបំពេញផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ របាយការណ៍ និងបញ្ហាផ្សេងទៀតដែលទាក់ទងនឹងការធ្វើសវនកម្ម
- វាយតម្លៃសមិទ្ធផលការងារប្រចាំឆ្នាំរបស់សវនកម្មផ្ទៃក្នុង
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលសម្រាប់ការសម្រេចចិត្តលើការអនុម័តទាក់ទងនឹងការតែងតាំង និងការដកហូតតំណែង HIA

បេសកកម្មរបស់សវនកម្មផ្ទៃក្នុងគឺដើម្បីលើកកម្ពស់ និងការពារតម្លៃរបស់ ធនាគារ អ៊ីវី (ខេមបូឌា) ម.ក ដោយផ្តល់នូវការធានា ការប្រឹក្សាដោយឯករាជ្យ មិនលំអៀង ដែលផ្អែកលើហានិភ័យ។ សវនកម្មផ្ទៃក្នុងជួយឱ្យ ធនាគារ អ៊ីវី (ខេមបូឌា) ម.ក សម្រេចបាននូវគោលបំណងរបស់ខ្លួន ដោយនាំមកនូវវិធីសាស្រ្តជាប្រព័ន្ធ និងប្រកបដោយវិន័យ ដើម្បីវាយតម្លៃ និងកែលម្អប្រសិទ្ធភាពនៃអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងដំណើរការត្រួតពិនិត្យ។

សវនករផ្ទៃក្នុងបង្កើតវិធីសាស្រ្តសវនកម្មដោយផ្អែកលើហានិភ័យដើម្បីកំណត់អាទិភាពសម្រាប់សកម្មភាពសវនកម្មផ្ទៃក្នុងស្របតាមគោលដៅរបស់ធនាគារ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង ធ្វើសវនកម្មដោយផ្អែកលើផែនការសវនកម្មប្រចាំឆ្នាំផ្អែកលើហានិភ័យ ដែលត្រូវបានអនុម័តដូចខាងក្រោម:

- ធ្វើសវនកម្មផ្ទៃក្នុងរបស់សាខា និងការិយាល័យកណ្តាល
- ធ្វើសវនកម្មផ្ទៃក្នុង ពត៌មានវិទ្យា "IT" ស្របតាមផែនការ
- ធ្វើសវនកម្ម/ការស៊ើបអង្កេតពិសេស

នៅឆ្នាំ 2021 នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានអនុវត្តការធ្វើសវនកម្មចំនួន 240 ដែលក្នុងនោះរួមមានសវនកម្មសាខាចំនួន 87 នាយកដ្ឋានការិយាល័យកណ្តាលចំនួន 17 ការធ្វើសវនកម្មដោយមិនមានការជូនដំណឹងចំនួន 109 ការធ្វើសវនកម្មចាំបាច់ចំនួន 2 និងសវនកម្មស៊ើបអង្កេតពិសេសចំនួន 25 ។

លទ្ធផលនៃសកម្មភាពសវនកម្ម ត្រូវបានរាយការណ៍ជាទៀងរាល់ប្រចាំត្រីមាសទៅកាន់ AC និងជូនដំណឹងលទ្ធផលសវនកម្មក្នុងទម្រង់ជារបាយការណ៍សរសេរជូនអ្នកគ្រប់គ្រង។

ការរកឃើញ និងអនុសាសន៍សវនកម្មទាំងអស់ដែលកើតចេញពីសវនកម្មត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ និងការតាមដានស្ថានភាពនៃការអនុវត្តអនុសាសន៍ជាមួយអ្នកគ្រប់គ្រងជាទៀងរាល់ត្រីមាស។ អ្នកគ្រប់គ្រងតម្រូវឱ្យអនុវត្តអនុសាសន៍សវនកម្ម និងរាយការណ៍ពីស្ថានភាពនៃការអនុវត្តអនុសាសន៍ទៅនាយកដ្ឋានសវនកម្មផ្ទៃក្នុងជាទៀងរាល់ត្រីមាស។

លទ្ធផល សម្រេចបាន

ធនាគារ អ៊ូរី
បានក្លាយខ្លួនជា ធនាគារពាណិជ្ជជាផ្លូវការ

ខែវិច្ឆិកា ឆ្នាំ2021 ភ្នំពេញ – យើងបានប្រែខ្លួនក្លាយទៅជាធនាគារពាណិជ្ជដោយជោគជ័យក្រោមឈ្មោះថ្មីថា ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ដែលនេះជាព្រឹត្តិការណ៍នៃការផ្លាស់ប្តូរដ៏សំខាន់មួយក្នុងអំឡុងពេល 30ឆ្នាំចុងក្រោយនៃប្រវត្តិសាស្ត្ររបស់ស្ថាប័នក្នុងការបម្រើសេវាហិរញ្ញវត្ថុជូនដល់ប្រជាជនកម្ពុជាទូទាំងប្រទេស។

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានទទួលបានអាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើប្រតិបត្តិការធនាគារពាណិជ្ជពេញលេញ។ ជាមួយនឹងមុខមាត់ថ្មីនេះ យើងមានក្តីរំភើបរីករាយ និងទន្ទឹងរង់ចាំក្នុងការផ្តល់ជូននូវសេវា និងផលិតផលធនាគារប្រកបដោយភាពច្នៃប្រឌិតស្របជាមួយនឹងការពង្រីកវិសាលភាពអាជីវកម្មរបស់យើងយ៉ាងទូលំទូលាយនៅក្នុងទីផ្សារហិរញ្ញវត្ថុ និងធនាគារ នៅក្នុងប្រទេសកម្ពុជា។

우리은행
WOORI BAN

ការបន្ថែមមុខងារថ្មីលើសេវាកម្មធនាគារចល័ត

#	មុខងារ
1	បន្ថែមប្រព័ន្ធសុវត្ថិភាព
2	បន្ថែមមុខងារផ្ទេរប្រាក់តាមរយៈ RFT
3	បន្ថែមមុខងារបង្កើតកូដ QR
4	ស្កេនកូដ QR ដើម្បីផ្ទេរ ឬ ទូទាត់
5	បន្ថែមមុខងារស្នើសុំប្រាក់កម្ចី
6	បន្ថែមមុខងារឧបករណ៍គណនា
7	បន្ថែមសេវាទូទាត់វិក្កយបត្រឯកជន
8	បង្កើនល្បឿននៃប្រតិបត្តិការ
9	បន្ថែមមុខងារបើកគណនីមានកាលកំណត់

ដៃគូអាជីវកម្មថ្មី

ដោយស្របតាមទីផ្សារប្រកួតប្រជែង ក៏ដូចជាបំពេញតម្រូវការអតិថិជនដៃគូសហការតាមរយៈឌីជីថលត្រូវបានសហការជាមួយដៃគូដូចខាងក្រោម៖

ល.រ	ដៃគូសហការ	អំពីសេវាកម្មជាមួយដៃគូសហការ
1	Bill24	អតិថិជនអាចទូទាត់វិក្កយបត្រទឹក ភ្លើង សំរាម និងវិក្កយបត្រទូទៅ របស់សេវាឯកជនបានទូទាំងប្រទេស។
2	សាខាអគ្គិសនីកម្ពុជា	អតិថិជនអាចទូទាត់វិក្កយបត្រភ្លើងរដ្ឋ ទៅ 5 ខេត្តបន្ថែមទៀតដូចជា បាត់ដំបង, បន្ទាយមានជ័យ, សៀមរាប, កំពត, កំពង់ស្ពឺ។

បើកដំណើរការសាខាថ្មីចំនួន3

ធនាគារ អ៊ូរី បានបើកសម្ពោធជាផ្លូវការនូវសាខាថ្មីចំនួន 3 បន្ថែមទៀត ជាមួយនឹងរចនាបទដ៏ទាក់ទាញ ដើម្បីផ្តល់នូវបរិយាកាសរីករាយ និងសេវាកម្មហិរញ្ញវត្ថុដែលមានភាពងាយស្រួលជូនដល់អតិថិជនចាស់ និងថ្មីរបស់យើង។ សាខាផ្សារថ្មីទី3 សាខាទួលស្វាយព្រៃទី2 និងសាខាទួលសង្កែ ត្រូវបានរចនាទាំងផ្នែកខាងក្នុង និងខាងក្រៅយ៉ាងស្រស់ស្អាត និងមានភាពទាក់ទាញរួមទាំងបរិក្ខារទំនើបសម្រាប់បម្រើជូនអតិថិជន។ ដោយមានការគាំទ្រយ៉ាងខ្លាំង និងតម្រូវការកាន់តែកើនឡើងរបស់អតិថិជន ធនាគារ អ៊ូរី បន្តពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួន ទាំងនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ទូទាំងប្រទេសកម្ពុជា។

ផលិតផល និងសេវាកម្មថ្មី

គណនីសប្បុរស គឺជាប្រភេទគណនីមានកាលកំណត់មួយទៀត ដែលមានរួមបញ្ចូលកម្មវិធីសប្បុរសធម៌ ឬកម្មវិធីជួយសង្គម។ តាមរយៈផលិតផលថ្មីនេះ អតិថិជនត្រូវបានផ្តល់ជម្រើសអោយធ្វើការជ្រើសរើសប្រភេទអង្គការសប្បុរសធម៌ដើម្បីអាចបរិច្ចាគ។

សេវាបើកប្រាក់បៀវត្សរ៍ គឺជាផលិតផលមួយក្នុងចំណោមផលិតផលជាច្រើនទៀតរបស់ ធនាគារ អ៊ូរី ត្រូវបានរៀបចំឡើងដើម្បីបំពេញតាមតម្រូវការរបស់អតិថិជន ដែលជានិយោជកតាមរយៈប្រព័ន្ធគ្រប់គ្រងច្បាស់លាស់ និងមានភាពងាយស្រួលក្នុងការទូទាត់ដូចជា(ប្រាក់បៀវត្សរ៍ ប្រាក់លើកទឹកចិត្ត និងប្រាក់រង្វាន់ផ្សេងៗ) ដល់បុគ្គលិករបស់ពួកគេ។

ឥណទានកូនកាត់ពិសេស គឺសំដៅទៅលើឥណទានដែលមានរបៀបបង់សងពិសេស ដែល50%នៃឥណទានបញ្ចេញសរុប អាចរក្សាទុកបង់សងនៅចុងវគ្គ និង50% ទៀត ត្រូវបង់សងរំលស់ប្រាក់ដើមប្រចាំខែ។

សេវាបញ្ជាអចិន្ត្រៃយ៍ ជាសេវាដែលអតិថិជនអាចកំណត់កាលវិភាគសម្រាប់ការផ្ទេរប្រាក់ទៅកាន់គ្រួសារ ដៃគូជំនួញ ឬដៃគូទូទាត់ ដោយស្វ័យប្រវត្តិ ជារៀងរាល់ ប្រចាំសប្តាហ៍ ប្រចាំខែ ឬ ប្រចាំត្រីមាស ក្នុងពេលវេលា និងចំនួនទឹកប្រាក់ជាក់លាក់ណាមួយតាមតម្រូវការលោកអ្នក។

IV ចំណុចសំខាន់ៗ អំពីអាជីវកម្ម

ទិន្នន័យ
ហិរញ្ញវត្ថុសំខាន់ៗ

ទិន្នន័យសំខាន់ៗ

	ឆ្នាំ 2021	ឆ្នាំ 2020
ចំនួនអតិថិជនប្រាក់កម្ចីសកម្ម	**177,256**	155,467
ភាគរយ អតិថិជនប្រាក់កម្ចីជាស្ត្រី	**73%**	77%
ភាគរយ អតិថិជនប្រាក់កម្ចីតាមជនបទ	**73%**	74%
ភាគរយ អតិថិជនប្រាក់កម្ចីផ្នែកកសិកម្ម	**40.63%**	42.40%
ចំនួនតំបន់ប្រតិបត្តិការ	**18**	18
ចំនួនស្រុកប្រតិបត្តិការ	**201**	197
ចំនួនបុគ្គលិកសរុប	**3,780**	2,984
ផលប័ត្រឥណទាន	**$927,833,487**	**$623,139,156**
ផលប័ត្រឥណទាន ជាមធ្យមសម្រាប់អ្នកខ្ចីម្នាក់	**$5,234**	$4,008
ផលប័ត្រឥណទាន ជាមធ្យមសម្រាប់មន្ត្រីឥណទានម្នាក់	**$448,879**	$359,573
ផលប័ត្រឥណទាន មានហានិភ័យ > 30 ថ្ងៃ	**0.78%**	0.29%
ប្រាក់បញ្ញើរបស់អតិថិជន	**$217,455,161**	$124,508,666
ចំនួនអ្នកដាក់ប្រាក់បញ្ញើ	**330,607**	263,083
ទ្រព្យសកម្មសរុប	**$1,162,460,491**	**$774,215,427**
មូលនិធិម្ចាស់ហ៊ុនសរុប	**$277,027,042**	**$232,232,647**
ប្រាក់ចំណេញធៀបដើមទុន	**17.59%**	16.86%
ប្រាក់ចំណេញធៀបទ្រព្យសកម្ម	**4.63%**	4.60%

វិធីសាស្ត្រប្រាក់កម្ចី
តាមរយៈចំនួនអតិថិជន

19.45%
កម្ចីក្រុម

80.55%
កម្ចីឯកត្តបុគ្គល

វិធីសាស្ត្រប្រាក់កម្ចី
តាមទំហំផលប័ត្រឥណទាន

98.33%
កម្ចីឯកត្តបុគ្គល

1.67%
កម្ចីក្រុម

និន្នាការកំណើន
ខែធ្នូឆ្នាំ 2021

$928
ផលប័ត្រឥណទាន
(គិតជាលានដុល្លារអាមេរិក)

177,256
ចំនួនអតិថិជនកម្ចី

330,607
ចំនួនអតិថិជន
បញ្ញើសន្សំ

$217
សមតុល្យប្រាក់បញ្ញើ-សន្សំ
(គិតជាលានដុល្លារអាមេរិក)

$1,162
សរុបទ្រព្យសកម្ម
(គិតជាលានដុល្លារអាមេរិក)

ពីខែធ្នូឆ្នាំ 2017 ដល់ខែធ្នូឆ្នាំ 2021 (គិតជាលានដុល្លារអាមេរិក)

សំពៀតឥណទាន

2017	169.73
2018	218.26
2019	335.53
2020	623.14
2021	**927.83**

អតិថិជនកម្ចីសកម្ម

2017	144,881
2018	137,017
2019	133,284
2020	155,467
2021	**177,256**

អតិថិជនបញ្ញើ-សន្សំ

2017	78,451
2018	117,478
2019	193,458
2020	263,083
2021	**330,607**

សមតុល្យប្រាក់បញ្ញើ-សន្សំ

2017	46.39
2018	61.79
2019	66.27
2020	124.51
2021	**217.46**

ចំនួនទ្រព្យសកម្ម

2017	198.96
2018	242.89
2019	379.94
2020	774.22
2021	**1,162.46**

របាយការណ៍បង់ពន្ធ

នៅក្នុងនាមជាធនាគារពាណិជ្ជដែលមានតម្លាភាពមួយយើងខ្ញុំសូមធ្វើការផ្សព្វផ្សាយជូនលោកអ្នកនូវរបាយការណ៍ពន្ធដែលបានបង់ដូចមានបង្ហាញជូននៅតារាងខាងក្រោម៖

គិតជាដុល្លារអាមេរិក	2017	2018	2019	2020	2021
ពន្ធប៉ាតង់	$18,500	$18,500	$18,500	$18,500	$18,500
ពន្ធតែមសារពើពន្ធលើផ្ទាំងផ្សាយពាណិជ្ជកម្ម	$70,042	$81,755	$64,790	$69,185	$115,098
កម្រៃអាជ្ញាបណ្ណបង់ជូនធនាគារជាតិ	$319,774	$305,125	$297,500	$308,750	$382,500
ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ	$3,670	$1,788	$2,278	$2,301	$3,593
អាករលើតម្លៃបន្ថែម	$2,777	$2,325	$2,266	$17,767	$0
ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ	$390,145	$391,678	$500,668	$843,090	$1,252,193
ពន្ធលើប្រាក់ចំណូល	$1,113,913	$728,045	$3,457,620	$6,876,812	$11,756,722
ពន្ធលើប្រាក់បៀវត្ស	$464,239	$937,310	$696,947	$1,029,252	$1,324,151
ពន្ធកាត់ទុកលើនិវាសជនគណនីសន្សំមានកាលកំណត់	$149,201	$194,655	$204,791	$226,698	$428,021
ពន្ធកាត់ទុកលើនិវាសជនគណនីសន្សំគ្មានកាលកំណត់	$8,360	$10,384	$13,954	$19,723	$28,874
ពន្ធកាត់ទុកលើនិវាសជន ថ្លៃឈ្នួល	$183,169	$204,772	$252,800	$330,297	$455,512
ពន្ធកាត់ទុកលើនិវាសជនសេវាកម្មនានា	$124,042	$56,964	$82,451	$68,456	$38,510
ពន្ធកាត់ទុកលើអនិវាសជនសេវាកម្មនានា	$181,208	$275,755	$170,383	$71,872	$236,046
ពន្ធកាត់ទុកលើអនិវាសជន ការប្រាក់	$1,100,021	$895,329	$1,084,350	$1,094,005	$725,590
ពន្ធកាត់ទុកលើអនិវាសជនការបែងចែកភាគលាភ	$-	$1,384,017	$-	$-	$-
សរុប	**$4,129,061**	**$5,488,402**	**$6,849,297**	**$10,976,708**	**$16,765,310**
សរុបបង្គរទុក *	$20,340,938	$25,829,340	$32,678,637	$43,655,345	$60,420,655

* សរុប និងសរុបបង្គរទុក គិតចាប់តាំងពីឆ្នាំ 2003។

របាយការណ៍
អភិវឌ្ឍន៍ធនធានមនុស្ស

ធនធានមនុស្ស គឺជាកម្លាំងចលករដ៏សំខាន់ដែលជម្រុញទៅរកភាពជោគជ័យ។ ដើម្បីជួយបុគ្គលិកឱ្យអភិវឌ្ឍន៍សមត្ថភាពផ្នែកវិជ្ជាជីវៈ និងសមត្ថភាពផ្ទាល់ខ្លួនផង និងជម្រុញឱ្យមានការរីកចម្រើនផ្នែកការងារផង យើងបានចាត់ទុកការបណ្តុះបណ្តាលជាអាទិភាពនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពដល់បុគ្គលិករបស់យើងនៅធនាគារ អ៊ូរី។ ដើម្បីគាំទ្រដល់កំណើនអាជីវកម្ម នាយកដ្ឋានទទួលបន្ទុកផ្នែកជ្រើសរើសបុគ្គលិកបានធ្វើការយ៉ាងយកចិត្តទុកដាក់ដើម្បីទាក់ទាញបេក្ខជនដែលមានជំនាញ និងសក្តានុពលជាអ្នកដឹកនាំ ព្រមទាំងជ្រើសរើសបុគ្គលិកថ្មីបន្ថែមបានចំនួនសរុប 1,009 នាក់ក្នុងឆ្នាំ 2021 នេះ។ គិតត្រឹមខែធ្នូឆ្នាំ 2021 នេះ ធនាគារ អ៊ូរី មានបុគ្គលិកសរុបចំនួន 3,780 នាក់ ក្នុងនោះមានបុគ្គលិកជាស្ត្រីចំនួន 872 នាក់។ តួលេខនេះបង្ហាញពីកំណើនបុគ្គលិកចំនួន 796 នាក់ បើប្រៀបធៀបកាលពីឆ្នាំកន្លងទៅ។

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានកំណត់យកការបណ្តុះបណ្តាលជាធាតុសំខាន់មួយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្ស។ យើងបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិករបស់យើង ដើម្បីឱ្យពួកគាត់មានសមត្ថភាពគ្រប់គ្រាន់សម្រាប់ការងារបច្ចុប្បន្ន និងឆ្លើយតបទៅនឹងតម្រូវការការងារនាពេលអនាគត។ ក្នុងន័យនេះយើង ប្តេជ្ញាក្នុងការបង្កើតនូវបទពិសោធន៍រៀនសូត្រដែលមានភាពទាក់ទាញ ឆ្លើយតបតាមតម្រូវការ និងអាចអនុញ្ញាតឱ្យបុគ្គលិកទាំងអស់ចូលរៀនសូត្របានតាមរយៈកម្មវិធី និងវិធីសាស្ត្របណ្តុះបណ្តាលផ្សេងៗ។

មានបុគ្គលិកសរុបចំនួន

3,780

កើនចំនួន 796 នាក់ បើធៀបនឹងឆ្នាំមុន។

ចំនួនបុគ្គលិកដែលឡើងឋានៈសរុប

305

ផ្តល់វគ្គបណ្តុះបណ្តាលសរុប 616 វគ្គ

តាមរយៈការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះឌីជីថលនីយកម្ម យើងបានបណ្តុះបណ្តាលបុគ្គលិករបស់យើងតាមរយៈកម្មវិធីបណ្តុះបណ្តាលផ្សេងៗ និងផ្តល់ជូននូវវេទិការៀនសូត្រលើប្រព័ន្ធឌីជីថលជាច្រើនដូចជាការរៀនតាមប្រព័ន្ធនិម្មិត និងតាមប្រព័ន្ធអនឡាញ បន្ថែមលើការបណ្តុះបណ្តាលតាមរយៈថ្នាក់រៀន ដើម្បីធានាថាពួកគេបន្តរៀនសូត្រ និងពង្រឹងជំនាញរបស់ពួកគេទៅតាមពេលវេលាដ៏ងាយស្រួល និងសមស្របរៀងៗខ្លួន។

ក្នុងឆ្នាំ 2021 យើងបានផ្តល់នូវវគ្គបណ្តុះបណ្តាលចំនួន 616 វគ្គដល់បុគ្គលិករបស់យើង។ ក្នុងនោះមានចំនួន 559 ជាវគ្គបណ្តុះបណ្តាលដែលរៀបចំឡើងក្នុងស្ថាប័ន 35 ជាវគ្គបណ្តុះបណ្តាលខាងក្រៅស្ថាប័ន និង 22 ជាវគ្គបណ្តុះបណ្តាលតម្រង់ទិសដល់បុគ្គលិកថ្មីៗ ដែលមានអ្នកចូលរួមសរុបចំនួន 80,857 នាក់ (96% តាមរយៈថ្នាក់និម្មិត និងប្រព័ន្ធអនឡាញ ហើយមានតែ 4% ទេតាមរយៈថ្នាក់រៀន)។ ត្រឹមខែមករា ឆ្នាំ 2022 យើងមានគម្រោងបញ្ចប់ការរៀបចំ និងដាក់ឱ្យដំណើរការមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់យើងដែលមានបន្ទប់បណ្តុះបណ្តាល បន្ទប់អនុវត្តជាក់ស្តែង (បន្ទប់ពិសោធន៍) និង បន្ទប់សន្និសីទ ឬ បន្ទប់ប្រជុំ ដែលបំពាក់ដោយឧបករណ៍ និងសម្ភារៈបណ្តុះបណ្តាលជាច្រើនដើម្បីធានាថាបាននូវដំណោះស្រាយរៀនសូត្រ ដែលមានភាពងាយស្រួលបំផុតសម្រាប់បុគ្គលិករបស់យើង។

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានកំណត់យកគោលដៅដ៏ធំមួយទៀតនៅឆ្នាំ 2022 ដើម្បីពង្រីកអាជីវកម្មរបស់ខ្លួននៅលើទីផ្សារធនាគារពាណិជ្ជដ៏ប្រកួតប្រជែងនៅកម្ពុជា។ ការប្តេជ្ញាចិត្តរបស់យើងគឺរក្សាការបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិកជាអាទិភាពរបស់យើង ដើម្បីធានាថាយើងនឹងបន្តបង្កើនសមត្ថភាពបុគ្គលិករបស់យើងឱ្យពូកែក្នុងតួនាទីបច្ចុប្បន្នរបស់ពួកគេ ក៏ដូចជារៀបចំពួកគេឱ្យឆ្លើយតបទៅនឹងតម្រូវការនាពេលអនាគតផងដែរ។

ការចែករំលែកបទពិសោធន៍ពីបុគ្គលិក

ធនាគារ អ៊ូរី បានផ្តល់ឱកាសឱ្យនាងខ្ញុំជាច្រើន ទាំងគ្រួសារ ទាំងការងារ មានឱកាសបានអភិវឌ្ឍន៍ខ្លួនពីតំណែងមួយទៅតំណែងមួយ ព្រមទាំងទទួលបានការគោរពស្រលាញ់ពីមិត្តរួមការងារ និង ថ្នាក់ដឹកនាំ

អ្នកស្រី ជួន ឌីណា
ប្រធានគ្រប់គ្រងជាន់ខ្ពស់ ផ្នែកគាំទ្រកម្មវិធីអាជីវកម្ម

ខ្ញុំបានចាប់ផ្តើមការងារដំបូងនៅទីនេះ ជាអ្នកបញ្ចូលទិន្នន័យ នៅសាខាខេត្តកំពង់ឆ្នាំង តាំងពីខែវិច្ឆិកា ឆ្នាំ 2005 បើគិតទៅវាជាង 16 ឆ្នាំហើយ។ ធ្វើការនៅទីនេះខ្ញុំបានអភិវឌ្ឍន៍ជំនាញការងារ ជាហូហែហើយបានឡើងតំណែងជាបន្តបន្ទាប់។ តួនាទីបន្ទាប់របស់ខ្ញុំគឺ ជំនួយការគណនេយ្យប្រចាំសាខា តែជាងមួយខែក្រោយប៉ុណ្ណោះ ខ្ញុំក៏បានផ្លាស់មកទីស្នាក់ការកណ្តាល នៅរាជធានីភ្នំពេញ។ នៅភ្នំពេញខ្ញុំបានឡើងតំណែងជាច្រើន រហូតមកដល់សព្វថ្ងៃគឺជា អ្នកគ្រប់គ្រងជាន់ខ្ពស់។

"ធនាគារ អ៊ូរី បានផ្តល់ឱកាសឱ្យនាងខ្ញុំជាច្រើន ទាំងគ្រួសារ ទាំងការងារ មានឱកាសបានអភិវឌ្ឍន៍ខ្លួនពីតំណែងមួយទៅតំណែងមួយ ព្រមទាំងទទួលបានការគោរពស្រលាញ់ពីមិត្តរួមការងារ និង ថ្នាក់ដឹកនាំ"

ធ្វើការនៅទីនេះ ថ្ងៃដែលបញ្ចប់គម្រោងថ្មីៗ និងដាក់ឱ្យដំណើរការ បានជោគជ័យ គឺជាថ្ងៃដ៏ល្អបំផុតរបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍កក់ក្តៅជាពិសេសនោះគឺនៅទីនេះបានផ្តល់ឱ្យខ្ញុំមានស្ថិរភាពផ្នែកហិរញ្ញវត្ថុ និង ផ្តល់នូវស្ថិរភាពការងារ។ ធនាគារ អ៊ូរី ប្រៀបដូចជាគ្រួសារទីពីររបស់ខ្ញុំ ជាពិសេសមានការលើកទឹកចិត្តពីក្រុមគ្រួសារ មានការគាំទ្រពីក្រុមការងារ និង អ្នកគ្រប់គ្រង មានប្រាក់បៀវត្សសមរម្យ ដែលអាចគាំទ្រដល់ជីវភាពរស់នៅ នៅទីនេះ។

ខ្ញុំពិតជាមានមោទនភាពចំពោះការរីកចម្រើនរបស់ ធនាគារ អ៊ូរី និងមោទនភាពចំពោះខ្លួនឯងដែលបានរួមចំណែកជាផ្នែកមួយ ជាមួយក្រុមការងារ។ មកទល់ពេលនេះ នាងខ្ញុំបានចូលរួមចំណែកជាច្រើនជាមួយក្រុមការងារ ក្នុងការអភិវឌ្ឍប្រព័ន្ធដូចជា កម្មវិធីធនាគារចល័ត កម្មវិធីផ្តល់ប្រាក់កម្ចី កម្មវិធីប្រមូលឥណទាន របាយការណ៍ Web Portal និងប្រព័ន្ធធនាគារស្នូល ជាដើម។

មកធ្វើការនៅទីនេះ មិនមែនទទួលបានបៀវត្សសមរម្យតែមួយមុខនោះទេ តែយើងមានឱកាសបានសិក្សារៀនសូត្រ និង ទទួលបានបទពិសោធន៍ការងារជាច្រើន ជាមួយនឹងបច្ចេកវិទ្យាថ្មីៗ ដែលទាក់ទងទៅនឹងវិស័យធនាគារ។ ធនាគារ អ៊ូរី ជាធនាគារពាណិជ្ជមួយដែលឈានមុខគេដែលត្រូវបានគ្រប់គ្រងដោយ ធនាគារ អ៊ូរី នៅប្រទេសកូរ៉េ និងជាធនាគារដ៏គួរឱ្យទុកចិត្តដែលមានវត្តមាន 30 ឆ្នាំនៅក្នុងប្រទេសកម្ពុជា។

បរិបទការងារល្អ ទំនាក់ទំនងការងារ អ្នកគ្រប់គ្រងល្អ និងក្រុមការងារល្អ គឺជាកម្លាំងចិត្តដ៏ចម្បងរបស់ខ្ញុំនៅកន្លែងធ្វើការ។ ពួកគាត់មានការទទួលខុសត្រូវខ្ពស់ ធ្វើឱ្យការងារជាក្រុមក៏ដើរទៅមុខរលូនដូចគ្នាដែរ។

មូ ចាន់ថេត
ប្រធានចាត់ការទូទៅ
ប្រធាននាយកដ្ឋានវិភាគ និងអនុម័តឥណទាន

ខ្ញុំបានចាប់ផ្តើម ធនាគារ អ៊ីវី ដំបូងនៅខែកក្កដា ឆ្នាំ2008 ដែលកាលនោះជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅឡើយ។ ចូលមកដំបូងចំពេលមានវិបត្តិសេដ្ឋកិច្ចពិភពលោកល្មម ដូច្នេះត្រូវត្រៀមជាបត្រដូសដោះស្រាយបញ្ហាដែលជាប់គាំងជាច្រើន។ ជាង 13 ឆ្នាំមកនេះខ្ញុំបានប្រឡូកការងារនៅក្នុងផ្នែកជាច្រើន ដោយមានទាំង មន្ត្រីសេវាកម្មអតិថិជន, មន្ត្រីផ្នែកហានិភ័យ និងត្រួតពិនិត្យគុណភាពឥណទាន ប្រធានសាខា ប្រធានសាខាជាន់ខ្ពស់ អនុប្រធានប្រចាំតំបន់ ប្រធានប្រចាំតំបន់ អ្នកគ្រប់គ្រងជាន់ខ្ពស់ ផ្នែកវិភាគឥណទាន និងការអនុម័ត រហូតមកដល់សព្វថ្ងៃជា ប្រធានផ្នែកវិភាគ និងអនុម័តឥណទាន។

ការសម្រេចចិត្តធ្វើការនៅ ធនាគារ អ៊ីវី ពិតជាការសម្រេចចិត្តដ៏ត្រឹមត្រូវ ជាការងារទីពីរនៅក្នុងវិស័យការងាររបស់ខ្ញុំ បន្ទាប់ពីការងារគ្រូបង្រៀន។ មកដល់ទីនេះខ្ញុំបានអភិវឌ្ឍខ្លួន ហើយបានកាន់តំណែងសំខាន់ៗជាច្រើន ហើយដោយសារការងារនេះហើយ ក៏បានជួយជ្រោមជ្រែងជីវភាពគ្រួសារ ឱ្យកាន់តែរីកចម្រើនផងដែរ។ បើនិយាយឱ្យចំទៅគឺជាកន្លែងផ្តល់សេចក្តីសុខមួយចំណែកធំឱ្យខ្ញុំបន្ទាប់ពីគ្រួសារ។

ខ្ញុំមានមោទនភាពទៅលើធនាគារ អ៊ីវី ទៅលើ បណ្តាញអន្តរជាតិ បើប្រៀបធៀបទៅលើបណ្តាញ ធនាគារអ៊ីវី (ខេមបូឌា) មានបណ្តាញ ច្រើនជាងគេក្នុងចំណោមធនាគារពាណិជ្ជនៅកម្ពុជា។ ពិសេសជាងនេះទៅទៀតនោះ គឺការវិវត្តនខ្លួនពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៅជា ធនាគារពាណិជ្ជ។

បរិបទការងារល្អ ទំនាក់ទំនងការងារ អ្នកគ្រប់គ្រងល្អ និងក្រុមការងារល្អ គឺជាកម្លាំងចិត្តដ៏ចម្បងរបស់ខ្ញុំនៅកន្លែងធ្វើការ។ ពួកគាត់មានការទទួលខុសត្រូវខ្ពស់ ធ្វើឱ្យការងារជាក្រុម ក៏ដើរទៅមុខរលូនដូចគ្នាដែរ។

បើចំពោះគ្រួសារវិញ គឺគាត់មានមោទនភាពចំពោះខ្ញុំ ព្រោះយើងជាអ្នកស្រែសុទ្ធសាធតែម្តង ហើយមានឱកាសបានមកធ្វើការនៅក្នុងស្ថាប័ន ដ៏ធំនិងមានស្តង់ដាការងារត្រឹមត្រូវ បានទទួលតំណែង គួរជាទីគាប់ចិត្តទៀត។ ឱកាសដែលបានរៀនបន្ត ក៏ទើបតែចាប់ផ្តើមក្រោយពេលបានធ្វើការនៅទីនេះដែរ។

ធនាគារ អ៊ីវី ចាប់ផ្តើមមានកេរ្តិ៍ឈ្មោះនៅក្នុងទីផ្សារ ជាមួយបរិយាកាសការងារដ៏ល្អប្រសើរ ក៏លើកទឹកចិត្តឱ្យបងប្អូនកូនក្មួយទាំងឡាយដែលចង់មានជំនាញការងារច្បាស់លាស់ អាចសម្រេចចិត្តមកធ្វើការទីកន្លែងការងារនៅទីនេះបាន។



អាចរៀនជំនាញជាច្រើននៅក្នុងស្ថាប័ន បរិយាកាសនៅកន្លែងការងារល្អ ជាពិសេស អ្នកគ្រប់គ្រងម្នាក់ៗពោរពេញទៅដោយសមត្ថភាព និងភាពជាអ្នកដឹកនាំខ្ពស់ ជាកត្តាដែលជម្រុញទឹកចិត្តខ្ញុំ ឱ្យធ្វើការនៅទីនេះបានយូរអង្វែងរហូតដល់សព្វថ្ងៃនេះ

កែវ សេងសោភា
ជំនួយការប្រធាន, ពាណិជ្ជកម្មអន្តរជាតិ

ខ្ញុំបានចូលធ្វើការនៅធនាគារ អ៊ូរី តាំងពីខែមេសាឆ្នាំ 2006 បើគិតទៅជាង16 ឆ្នាំមកហើយ។ កាលនោះខ្ញុំជានិស្សិតឆ្នាំទីមួយ ដែលមិនទាន់យល់ពីការងារ អ្វីបានស៊ីជម្រៅទាក់ទងនឹង វិស័យហិរញ្ញវត្ថុនៅឡើយ ដោយគ្រាន់តែបានយល់ខ្លះៗខាងផ្នែកគណនេយ្យទូទៅ។ ពេលនោះចង់ធ្វើការនៅធនាគារ អ៊ូរី ខ្លាំងណាស់ ដែលកាលនោះគឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយនៅឡើយ។ តំណែងដំបូងរបស់ខ្ញុំគឺជា អ្នកបញ្ចូលទិន្នន័យ (Data Encoder)។

ថ្ងៃដែលខ្ញុំបានឈានចូលធ្វើការនៅ ធនាគារ អ៊ូរី លើកដំបូងគឺជាថ្ងៃដែលល្អបំផុតសម្រាប់ខ្ញុំ។ វាពិតជាមិនអាចភ្លេចបានខណៈពេលដែល យើងជាបុគ្គលិកថ្មីម្នាក់ហើយត្រូវបានទទួលស្វាគមន៍ យ៉ាងកក់ក្តៅពីមិត្តរួមការងារ និងរៀមច្បងថែមទាំងរីករាយនៅក្នុងការ ណែនាំ និងបង្ហាត់ឱ្យយើងចេះពីការងារ តាំងពីសូន្យរហូតដល់មួយរយ។ លើសពីនេះទៅទៀត ការបានចូលរួមការងារសង្គមជាមួយធនាគារ ពិតជាធ្វើឱ្យខ្ញុំកាន់តែពេញចិត្តកន្លែងធ្វើការ កាន់តែខ្លាំង។

ការផ្តល់ឱកាសការងារ គឺជាការបើកទំព័រថ្មីមួយសម្រាប់ជីវិតនៅក្នុងវិស័យការងារក្រោយពីបានទទួលការហ្វឹកហ្វឺនរៀនសូត្រការងារជាច្រើន ធ្វើឱ្យខ្ញុំគិតថា វាជាការសម្រេចចិត្តដ៏ត្រឹមត្រូវ និងសំខាន់មួយនៅក្នុងជីវិត។ ដោយសារការងារនៅ ទីនេះមានភាពសម្បូរបែប ខ្ញុំបានផ្លាស់ប្តូរតួនាទីតាមផ្នែកផ្សេងៗជាច្រើន ដែលរួមមានទាំងផ្នែក មន្ត្រីព័ត៌មានផ្នែកអាជីវកម្ម រហូតមកដល់បច្ចុប្បន្នជា ជំនួយការប្រធាន, ពាណិជ្ជកម្មអន្តរជាតិ ហើយបានក្លាយជាផ្នែកមួយ នៃភាពជោគជ័យរបស់ស្ថាប័ន តាំងពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រហូតក្លាយជាធនាគារ ពាណិជ្ជ ដែលមានការទទួលស្គាល់ទូទាំងពិភពលោក ធ្វើឱ្យខ្ញុំមានមោទនភាពយ៉ាងខ្លាំង។

"អាចរៀនជំនាញជាច្រើននៅក្នុងស្ថាប័ន បរិយាកាសនៅកន្លែងការងារល្អ ជាពិសេស អ្នកគ្រប់គ្រងម្នាក់ៗពោរពេញទៅដោយសមត្ថភាព និងភាពជាអ្នកដឹកនាំខ្ពស់ ជាកត្តាដែលជម្រុញទឹកចិត្តខ្ញុំ ឱ្យធ្វើការនៅទីនេះបានយូរអង្វែងរហូតដល់សព្វថ្ងៃនេះ"

ចំពោះបងប្អូន ជាពិសេសប្អូនៗនិស្សិតដែលចង់ចាប់ផ្តើមការងារនៅក្នុងវិស័យធនាគារ ហើយបើសិនមិនទាន់មានជំនាញការងារ ទីនេះគឺប្រៀបបានដូចជាសាលារៀនបណ្តុះបណ្តាលជំនាញមួយ ជាមួយគុណភាពការងារស្តង់ដា។ សម្រាប់អ្នកដែលមានជំនាញហើយចង់បន្តអាជីពនៅធនាគាអ៊ូរី។ នៅទីនេះមានបរិយាកាសការងារល្អ ការិយាល័យប្រកបដោយស្តង់ដា និងមានសុខុមាលភាព មានក្រុមការងារប្រកបដោយគុណភាព ថែមទាំងរីករាយក្នុង ការផ្លាស់ប្តូរចែករំលែកជំនាញឱ្យគ្នាទៅវិញទៅមក។

ព័ត៌មានសំខាន់ៗ

CSR

សកម្មភាពទំនួលខុសត្រូវសង្គម

ធនាគារ អ៊ូរី បានបរិច្ចាគសម្ភារបរិក្ខារការពារជំងឺកូវីដ-19

ក្នុងខែកញ្ញា និងតុលា ឆ្នាំ 2022 ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានបរិច្ចាគសម្ភារបរិក្ខារការពារជំងឺកូវីដ-19 ដល់ពលករដែលនឹងទៅធ្វើការនៅប្រទេសកូរ៉េ តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សរុបទឹកប្រាក់ចំនួន 6,842 ដុល្លារអាមេរិក សម្រាប់សម្ភារមានដូចជា ម៉ាសចំនួន 6,150 ដបចំនួន 1,230 (150មល) និងកាបូបបរិស្ថានចំនួន 1,230។

ដំឡើងឆ័ត្រធំៗនៅតាមភ្លើងស្តុបនិងតាមដងផ្លូវសំខាន់ៗនៅរាជធានីភ្នំពេញ

ភ្នំពេញ- ធនាគារ អ៊ូរី (ខេមបូឌា) បានដំឡើងឆ័ត្រធំៗនៅតាមភ្លើងស្តុបនិងតាមដងផ្លូវសំខាន់ៗមួយចំនួនក្នុងរាជធានីភ្នំពេញ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍សហគមន៍ និងជួយសម្រួលដល់អ្នកធ្វើដំណើរទៅមក។ អ្នកធ្វើដំណើរទាំងអស់នឹងប្រទះឃើញឆ័ត្ររបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក នៅតាមដងផ្លូវមាត់ទន្លេ និងផ្លូវធំៗមួយចំនួនទៀតក្នុងទីក្រុងភ្នំពេញ ខណៈពេលដែលពួកគេកំពុងរង់ចាំភ្លើងស្តុបដើម្បីឆ្លងផ្លូវ។ ឆ័ត្រធំនេះមានទំហំ 3 គុណ 3ម៉ែត្រ ធ្វើឡើង យ៉ាងរឹងមាំ ដែលអាចផ្តល់ជាម្លប់នារដូវក្តៅ និងជារបាំងទឹកភ្លៀងនារដូវវស្សា។

ឧបត្ថម្ភវិភាគទានដល់ពុទ្ធិកវិទ្យាល័យរាជបូណ៌ ខេត្តសៀមរាប

ខែកុម្ភៈ ឆ្នាំ 2021 ធនាគារ អ៊ូរី បានចូលរួមចំណែកជាសាច់ប្រាក់ចំនួន 3,000 ដុល្លារអាមេរិក ក្នុងការសាងសង់អគារ 4 ជាន់ នៃវិទ្យាល័យរាជបូណ៌ ខេត្តសៀមរាប។

មូលនិធិជួយសង្គ្រោះរបស់បុគ្គលិក ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

បានបង្កើតឡើងតាមរយៈការចូលរួមចំណែកបរិច្ចាកជាប្រចាំខែពីបុគ្គលិករបស់ធនាគារ អ៊ូរី ទាំងអស់ និងក្នុងគោលបំណងជួយបុគ្គលិកវិញ។ មូលនិធិនេះត្រូវបានបង្កើតឡើងនាខែធ្នូ ឆ្នាំ2022 និងត្រូវបានប្រើប្រាស់ដើម្បីជួយដល់បុគ្គលិក រួមទាំងក្រុមគ្រួសារបុគ្គលិក ក៏ដូចជាសហគមន៍មួយចំនួនក្នុងគ្រាលំបាកនានា។

ក្នុងឆ្នាំ2021 មូលនិធិជួយសង្គ្រោះរបស់បុគ្គលិកធនាគារ អ៊ូរី (ខេមបូឌា) ម.ក ត្រូវបានប្រើប្រាស់សរុបចំពោះ 186 ករណី សម្រាប់បុគ្គលិកដែលប្រឈមនឹងការលំបាកជាមួយនឹងថវិការ ចំណាយសរុបចំនួន 45,725ដុល្លារអាមេរិក សម្រាប់ចូលរួមក្នុង ពិធីបុណ្យសព គ្រោះមហន្តរាយ និងរួមទាំងកិច្ចការសង្គមជាច្រើនទៀតផងដែរ។

សកម្មភាពបុគ្គលិកធនាគារ អ៊ូរី

រង្វាន់ និងការទទួលស្គាល់

ដើម្បីអបអរនូវសមិទ្ធផលគួរឱ្យកត់សំគាល់ របស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក លោក គីម ហុងជូ អគ្គនាយកប្រតិបត្តិ នៃធនាគារ អ៊ូរីបានប្រគល់រង្វាន់និងប័ណ្ណសរសើរដល់ប្រធានតំបន់ និងប្រធានសាខាឆ្នើម នៅក្នុងកិច្ចប្រជុំថ្នាក់គ្រប់គ្រងប្រតិបត្តិការ ។

ទិវាសិទ្ធិនារី

នៅថ្ងៃទី 05 ខែមីនាឆ្នាំ 2021 គណៈគ្រប់គ្រង ធនាគារ អ៊ូរី (ខេមបូឌា) ម.ក មានសេចក្តីសោមនស្សរីករាយ ចែករំលែកក្តីស្រឡាញ់ជាមួយផ្កាដ៏ស្រស់ស្អាតដល់បុគ្គលិក និងអតិថិជននារីៗដើម្បី ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អតិថិជនដែលបានប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ ក្នុងឱកាសទិវាសិទ្ធិនារីអន្តរជាតិឆ្នាំ 2021។

អំពីភាពជោគជ័យ
របស់អតិថិជន

ប្រៀបធៀបមកដល់បច្ចុប្បន្ននេះ ជីវភាពគាត់សព្វថ្ងៃឃើញថាធូធារជាងមុន ជាមួយនឹងប្រាក់កម្ចីរបស់ធនាគារ អ៊ូរី ទាំងពីរវគ្គ។ គាត់ថែមទាំងអាចផ្គត់ផ្គង់កូនៗ ឱ្យបានរៀនសូត្រគ្រប់គ្នាទៀតផង។

អតិថិជនឈ្មោះ ភូ ខាំហ្វាន់

អ្នកស្រី ភូ ខាំហ្វាន់ ភេទ ស្រី អាយុ 33 ឆ្នាំ មានមុខរបរជាអ្នកលក់ដូរចាប់ហួយ រស់នៅជាមួយនឹងប្តី និងកូន ពីរនាក់ កូនប្រុសអាយុ 18 ឆ្នាំ រៀនថ្នាក់ទី 11 នឹងកូនស្រីអាយុ 16 ឆ្នាំ រៀនថ្នាក់ទី 9។ លោកស្រីមានទីលំនៅ ស្ថិតនៅភូមិ ភ្នំ សង្កាត់ យក្សឡោម ក្រុង បានលុង ខេត្ត រតនៈគិរី។

លោកស្រីបានទទួលប្រាក់កម្ចីពីធនាគារ អ៊ូរី ពីរវគ្គរួចមកហើយ។ វគ្គទីមួយគាត់យកមកជួសជុលផ្ទះសម្រាប់កន្លែងស្នាក់នៅប្រសើរជាងមុន នឹងវគ្គទីពីរដើម្បីទិញអីវ៉ាន់បន្ថែម។ គាត់ទទួលបានចំណូលច្រើនជាងមុនរហូតដល់ 50%។ គាត់រកប្រាក់ចំណូលបាន 60 ម៉ឺនរៀលក្នុងមួយថ្ងៃបន្ទាប់ពីខ្ចីប្រាក់នៅវគ្គទី 2។

មុនពេលគាត់មិនទាន់បានប្រើប្រាស់ប្រាក់កម្ចីពីធនាគារ អ៊ូរី ជីវភាពរបស់គាត់ គឺលំបាកជាងនេះ ដោយមានបញ្ហាខ្វះដើមទុនក្នុងការរកស៊ី និងមិនទាន់មានផ្ទះសមរម្យសម្រាប់ស្នាក់នៅទេ។ ជាមួយនឹងមុខ របរលក់ចាប់ហួយ គាត់អាចរកចំណូលបានតែ 30ម៉ឺនរៀល ឬចំណេញសុទ្ធ ប្រហែល 6 ម៉ឺនរៀលប៉ុណ្ណោះ ដែលស្ទើរតែមិនគ្រប់គ្រាន់សម្រាប់ជីវភាពនៅប្រចាំថ្ងៃ។ ស្វាមីរបស់អ្នកស្រីធ្វើការជាអ្នក ចម្រៀងតាមកម្មវិធីផ្សេងៗនៅក្នុងតំបន់។

ពីមុនផ្ទះរបស់គាត់តូច និងមិនមានកន្លែងគ្រប់គ្រាន់សម្រាប់ដាក់ឥវ៉ាន់បានច្រើននោះទេ។ បន្ទាប់ពីកែលម្អ និងពង្រីកបន្ថែមផ្ទះរបស់គាត់អាចដាក់ឥវ៉ាន់លក់ដូរបានច្រើនជាងមុន។

ប្រៀបធៀបមកដល់បច្ចុប្បន្ននេះ ជីវភាពគាត់សព្វថ្ងៃឃើញថាធូធារជាងមុន ជាមួយនឹងប្រាក់កម្ចីរបស់ធនាគារ អ៊ូរី ទាំងពីរវគ្គ។ គាត់ថែមទាំងអាចផ្គត់ផ្គង់កូនៗ ឱ្យបានរៀនសូត្រគ្រប់គ្នាទៀតផង។

អ្នកស្រីបន្តថា បើគ្មានកម្ចីពីធនាគារ អ៊ូរី នោះទេ ជីវភាពរបស់គាត់នឹងលំបាកជាងនេះ ដោយសារតែគ្មានដើមទុនគ្រប់គ្រាន់ពង្រីកកន្លែងរបររកស៊ី។

រឿងដែលធ្វើអោយគាត់សប្បាយចិត្ត ហើយមានមោទនភាពចំពោះខ្លួនគាត់ផ្ទាល់គឺ គាត់អាចសម្រេចក្តីបំណងដែលគាត់ចង់បានគឺមានផ្ទះមួយដែលសមរម្យនឹងរស់នៅជាមួយក្រុមគ្រួសាររបស់គាត់ដោយមានក្តីសុខ នឹងមានអាជីវកម្មផ្ទាល់ខ្លួនមួយដែលអាចរកប្រាក់ចំណូលជួយផ្គត់ផ្គង់ក្រុមគ្រួសាររបស់គាត់។ លោកស្រីមានបំណងនឹងស្នើឥណទានបន្ថែមទៀតនៅថ្ងៃអនាគត ដើម្បីបន្តការរកស៊ីលក់ដូរ និងដើម្បីពង្រីកមុខរបររបស់ខ្ញុំ។ ទៅថ្ងៃអនាគតគាត់ពង្រីកមុខរបររបស់គាត់ ឱ្យកាន់តែច្រើនដើម្បីរកប្រាក់ចំណូលបានច្រើនក្នុងការដែលអាចជួយសម្រាលបន្ទុក របស់គាត់ នឹងជួយឱ្យ ជីវភាពរបស់កាន់តែប្រសើរជាងនេះ និងចង់អោយកូនៗរៀនបានខ្ពង់ខ្ពស់ នឹងមានការងារមួយល្អធ្វើ។

លោកឆេងអ៊ាង បានបញ្ជាក់ពីចំណូល ក្រោយពីទទួលបានប្រាក់កម្ចីពី ធនាគារ អ៊ូរី ថានាពេលបច្ចុប្បន្ននេះ ចំណូល របស់ខ្ញុំក្នុងរយៈពេលមួយទៅពីរថ្ងៃ ទទួលបានប្រហែលមួយលានរៀល។ នេះគឺរួមបញ្ចូលទាំង ការជួសជុល លក់គ្រឿងបន្លាស់ និងលក់ទូរស័ព្ទខ្លះផងដែរ។

អតិថិជនឈ្មោះ អាំ ឆេងអ៊ាង

លោក អាំ ឆេងអ៊ាង និងប្រពន្ធឈ្មោះ កែវ ថុនា មានទីលំនៅនៅ ភូមិមឈាយ ឃុំសំព្រោជ ស្រុកស្ទោង ខេត្តកំពង់ធំ។ សព្វថ្ងៃលោកនៅជាមួយ គ្រួសារដែលមានកូនពីរនាក់ កូនទី1ប្រុស ទី2ស្រី ដោយកូនបងរៀនថ្នាក់ទី2 កូនស្រីរៀនថ្នាក់ទី1 ។ លោក ឆេងអ៊ាង មានមុខរបរជាជាងជួសជុល និងជាអ្នកលក់ទូរស័ព្ទ។

លោក អាំ ឆេងអ៊ាង ទទួលប្រាក់កម្ចីពីធនាគារ អ៊ូរី ចំនួន 5,400ដុល្លារអាមេរិក ពីធនាគារ អ៊ូរី ដើម្បីយកមកពង្រីកមុខរបរ ជួសជុល និងលក់ទូរស័ព្ទ។ ក្រៅពីនេះ លោកក៏បាន ទាញយកកម្ចី 2,000 ដុល្លារបន្ថែមពីគណនីពាណិជ្ជករពិសេសមកប្រើប្រាស់ផងដែរ។ ក្រោយពីទទួលបានប្រាក់កម្ចី លោកក៏បានយកធ្វើជាដើមទុន យកទៅទិញឧបករណ៍ជួសជុល គ្រឿងបន្លាស់ និងទូរស័ព្ទបន្ថែម។

កាលពីមិនទាន់បានទទួលប្រាក់កម្ចី ដើមទុន និងលុយបង្វិលរកស៊ី ជីវភាពប្រចាំថ្ងៃមានសភាពខ្វះមុខខ្វះក្រោយ ដោយមិនមានស្តុកទូរស័ព្ទគ្រប់គ្រាន់ ខ្វះខាតគ្រឿងបន្លាស់ និងឧបករណ៍ជួសជុលជាច្រើន ដែលធ្វើឱ្យហាងរបស់គាត់មិនអាចទាក់ទាញអតិថិជនឱ្យចូលមកប្រើប្រាស់សេវាកម្មបានច្រើននោះទេ។

លោកឆេងអ៊ាង បានបញ្ជាក់ពីចំណូល ក្រោយពីទទួលបានប្រាក់កម្ចីពី ធនាគារ អ៊ូរី ថានាពេលបច្ចុប្បន្ននេះ ចំណូលរបស់ខ្ញុំក្នុងរយៈពេល 1ទៅ2ថ្ងៃ ទទួលបានប្រហែល1លានរៀល។ នេះគឺរួមបញ្ចូលទាំង ការជួសជុល លក់គ្រឿងបន្លាស់ និងលក់ទូរស័ព្ទខ្លះផងដែរ។ ភ្ញៀវដែលចូលមកហើយ កម្រនឹងមានអ្នកដែរដើរចេញទៅវិញណាស់។ ព្រោះថា ថាសេវាកម្ម និងគ្រឿងបន្លាស់នៅទីនេះ មានគ្រប់តាមតម្រូវការ អតិថិជនតែម្តង។

នៅថ្ងៃអនាគត លោកឆេងអ៊ាង មានបំណងស្នើឥណទាន ពីធនាគារ អ៊ូរី មួយចំនួនទៀត ដើម្បីពង្រីកមុខរបរប្រចាំថ្ងៃនេះឱ្យកាន់តែប្រសើរបន្ថែមទៀត។

“តាមរយៈប្រាក់កម្ចីរបស់ធនាគារ ទាំងពីរវគ្គបាន ជួយឱ្យគ្រួសារគាត់មានជីវភាពធូធារ និងធានា អនាគតសម្រាប់ការអប់រំរបស់កូនគាត់ ដែលពីមុន គ្រួសារគាត់មានជីវភាពក្រីក្រ មិនមានទុនរកស៊ី គ្រប់គ្រាន់ គ្មានផ្ទះផ្ទាល់ខ្លួន ហើយមិនមានលុយ គ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់អនាគតកូនៗឡើយ”

អតិថិជនឈ្មោះ កៅ ញិម

បងប្រុស កៅ ញិម មានអាយុ 28 ឆ្នាំ និងប្រពន្ធឈ្មោះ ទ្បែម យឿ អាយុ 26 ឆ្នាំ មានទីលំនៅបច្ចុប្បន្នស្ថិតនៅក្នុង ភូមិមោងខាងជើង ឃុំមោង ស្រុកស្រីស្នំ ខេត្តសៀមរាប។ សព្វថ្ងៃបងប្រុសប្រកបមុខរបរ លក់អីវ៉ាន់ចម្រុះ បោះដុំ និង លក់រាយនៅក្នុងភូមិ។ បច្ចុប្បន្នគ្រួសាររបស់គាត់មានកូនចំនួន 2 នាក់គឺ ប្រុសម្នាក់ និងស្រីម្នាក់។ កូនស្រីច្បង អាយុ 9 ឆ្នាំ រៀននៅសាលាបឋមសិក្សា ថ្នាក់ទី3 និងកូនប្រុសពៅ អាយុ 5 ឆ្នាំមិនទាន់គ្រប់អាយុចូលរៀននៅឡើយទេ។

បងប្រុសបានរៀបរាប់ថា កាលពីឆ្នាំ 2019 មុនទទួលបាន ប្រាក់កម្ចីពីធនាគារ អ៊ូរី គាត់ និងគ្រួសារបានប្រកបរបរលក់ដូរ អីវ៉ាន់បន្តិចបន្តួចនៅផ្ទះដែលទទួលបានចំណូលដុលជាមធ្យម ក្នុងមួយថ្ងៃពី 25 ទៅ 30ដុល្លារ និងមានមុខរបរកសិកម្ម ធ្វើស្រែ 2 ហិចតា និងផ្លៀតដើរស៊ីឈ្នួលគេក្នុងភូមិពេលទំនេរទៀតផង។

បងប្រុស កៅ ញិម បានទទួលកម្ចីលើកដំបូងពីធនាគារ អ៊ូរី នៅក្នុងឆ្នាំ 2020 ជាមួយនឹងចំនួនទឹកប្រាក់ 40លានរៀល ក្នុង គោលបំណងពង្រីកតូបលក់អីវ៉ាន់ និងបន្ថែមស្តុកអីវ៉ាន់ ចាប់ហួយចម្រុះដើម្បីលក់បោះដុំ និងលក់រាយ។ នៅចុងវគ្គ ទីមួយនេះបងប្រុសបានចំណូលប្រចាំថ្ងៃកើនឡើងរហូតដល់ 150 ទៅ 200ដុល្លារ ក្នុងមួយថ្ងៃដែលក្នុងនោះប្រាក់ចំណេញ សុទ្ធចន្លោះពី 35 ទៅ 40ដុល្លារក្នុងមួយថ្ងៃ។ ចំណូលនេះបាន ធ្វើអោយជីវភាពគ្រួសាររបស់គាត់មានការប្រសើរឡើងជាង មុនជាលំដាប់ និងបានទិញសម្ភារៈផ្គត់ផ្គង់អាជីវកម្មរបស់គាត់ បន្ថែមដូចជា ឡានដឹកអីវ៉ាន់ ប្រភេទ SANYONG មួយគ្រឿង តម្លៃប្រហែលជាង 7,000ដុល្លារ។

នៅក្នុងឆ្នាំ 2021 ដោយមើលឃើញការរីកចម្រើនជាលំដាប់ នៃមុខរបរលក់ដូររបស់គាត់បងប្រុស កៅ ញិម និងភរិយា បានសម្រេចចិត្តស្នើកម្ចីថ្មីចំនួន 15,000ដុល្លារ បន្ថែម ដើម្បី ពង្រីកមុខរបរ។

នៅក្នុងវគ្គកម្ចីនេះបងប្រុសទទួលបានចំណូលប្រចាំថ្ងៃប្រហែល 400 ទៅ 500ដុល្លារក្នុងមួយថ្ងៃដែលក្នុងនោះសាច់ប្រាក់ ចំណេញញសុទ្ធប្រហែល 60 ដុល្លារក្នុងមួយថ្ងៃដែលធ្វើឱ្យ គ្រួសាររបស់គាត់មានជីវភាពរឹតតែប្រសើរឡើងពីមួយវគ្គទៅ មួយវគ្គ។

គាត់បានបន្តថា“តាមរយៈប្រាក់កម្ចីរបស់ធនាគារ ទាំងពីរវគ្គ បានជួយឱ្យគ្រួសារគាត់មានជីវភាពធូរធារ និងធានាអនាគត សម្រាប់ការអប់រំរបស់កូនគាត់ ដែលពីមុនគ្រួសារគាត់មាន ជីវភាពក្រីក្រ មិនមានទុនរកស៊ីគ្រប់គ្រាន់ គ្មានផ្ទះផ្ទាល់ខ្លួន ហើយមិនមានលុយគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់អនាគតកូនៗ ឡើយ”។

កៅ ញិម និង ភរិយា បានកោតសរសើរចំពោះ ធនាគារ អ៊ូរី ដែលជឿជាក់លើពួកគេ និងផ្តល់ប្រាក់កម្ចី ធ្វើឱ្យគ្រួសាររបស់ ពួកគាត់ប្រសើជាងមុន។ នៅថ្ងៃខាងមុខបងប្រុស និងភរិយា មានគម្រោងពង្រីកមុខរបរលក់ដូរអីវ៉ាន់បោះដុំផ្តាច់មុខ និង ទិញដីដើម្បីពង្រីកតូបបន្ថែមស្តុកអីវ៉ាន់ឱ្យបានច្រើន និងឈាន ទៅបើកសាខាថ្មីបន្ថែមទៀតប្រសិនបើគាត់អាចរកចំណូល បានរឹតតែច្រើនបន្ថែមទៀត។គាត់បានបន្ថែមទៀតថា “គ្រួសារ លោកនឹងប្រើប្រាក់កម្ចីរបស់ធនាគារ អ៊ូរី វគ្គទី 3 ដើម្បីពង្រីក អាជីវកម្មបច្ចុប្បន្ននេះឱ្យកាន់តែធំជាងមុនក្នុងរយៈពេល ប្រហែល1ឆ្នាំខាងមុខទៀតដោយគាត់មានបំណងទិញដីជាប់ ផ្ទះដើម្បីពង្រីកតូប និងថែមស្តុកអីវ៉ាន់សម្រាប់លក់បោះដុំ”។

សម្រាប់អនាគតកូនៗរបស់គាត់បងប្រុស និងភរិយាបាន លើកឡើងបែបនេះថា “ពួកគាត់ចង់ឃើញកូនៗរៀនបានខ្ពស់ កម្រិតបរិញ្ញាបត្រ និងមានការងារធ្វើល្អដូចជាការងារនៅ គ្រឹះស្ថានធនាគារ ឬការងារ វិស័យឯកជននានាដែលមាន ប្រាក់ខែសមរម្យអាចរកចំណូលបានច្រើនដើម្បីជីវភាពរបស់ ពួកគេនាពេលអនាគត។ គាត់សង្ឃឹម និងមានទំនុកចិត្តយ៉ាង មុតមាំជាមួយ ធនាគារ អ៊ូរី គឺជាដៃគូដ៏ល្អប្រសើរសម្រាប់ សម្រេចក្តីស្រម៉ៃកូនជាទីស្រឡាញ់របស់គាត់។

ផលិតផលហិរញ្ញវត្ថុ និងសេវាកម្ម

- ប្រាក់សន្សំ
- ប្រាក់កម្ចី
- សេវាផ្ទេរប្រាក់
- សេវាធនាគារឌីជីថល
- សេវាអេធីអឹម និងប័ណ្ណឥណពន្ធ
- សេវាធនាគារផ្សេងៗទៀត

ប្រាក់សន្សំ

គណនីសង្ឃឹម

គណនីសង្ឃឹម គឺជាប្រភេទគណនីសន្សំស្ម័គ្រចិត្ត ដែលបង្កើតឡើងសម្រាប់សហគ្រិន បុគ្គលិកក្រុមហ៊ុន ស្ត្រីមេផ្ទះ ដែលមានបំណងដាក់ប្រាក់សន្សំរបស់ពួកគេ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយដែលគួឱ្យជឿទុកចិត្ត និងមានសុវត្ថិភាពខ្ពស់។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងបាត
ការដាក់ប្រាក់តម្កល់ដំបូង	20,000 រៀល
	5 ដុល្លារ
	200 ថៃបាត
រយៈពេល	មិនកំណត់

គណនីចម្រើនទ្រព្យ

គណនីចម្រើនទ្រព្យ គឺជាប្រភេទគណនីសន្សំ ដែលទទួលបានអត្រាការប្រាក់ខ្ពស់ និងមានលក្ខណៈជាកិច្ចសន្យាដែលតម្រូវឱ្យរក្សាទុកនូវសមតុល្យគណនី ក្នុងរយៈពេលកំណត់ជាក់លាក់មួយរហូតដល់កាលបរិច្ឆេទកំណត់។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងបាត
ការដាក់ប្រាក់តម្កល់ដំបូង	10,000 រៀល
	25 ដុល្លារ
	1,000 ថៃបាត
រយៈពេល	01 - 36 ខែ

គណនីកូនល្អ

គណនីកូនល្អ គឺជាប្រភេទគណនីសន្សំស្ម័គ្រចិត្ត ដែលបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ឪពុកម្ដាយ ឬសាច់ញាតិ ដែលមានបំណងសន្សំប្រាក់សម្រាប់កូនៗរបស់ពួកគេ ដែលមានអាយុក្រោម ១៨ ឆ្នាំ។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងថៃបាត
ការដាក់ប្រាក់តម្កល់ដំបូង	20,000 រៀល
	5 ដុល្លារ
រយៈពេល	Until his/her eighteen (18) years

គណនីសន្សំតាមផែនការ

គណនីសន្សំតាមផែនការ គឺជាប្រភេទគណនីសន្សំមានលក្ខណៈជាកិច្ចសន្យា ដែលតម្រូវឱ្យមានការដាក់ប្រាក់ចូលក្នុងគណនីនូវចំនួនស្មើៗគ្នាជារៀងរាល់ខែ។ គណនីនេះ ត្រូវបានបង្កើតឡើងសម្រាប់អតិថិជនឯកត្តជនដែលមានចំណូលទៀងទាត់ និងមានបំណងជ្រើសរើសវិធីសាស្ត្រសន្សំបង្គរសម្រាប់ការវិនិយោគ ឬតម្រូវការអនាគត ដូចជា វិនិយោគក្នុងអាជីវកម្ម ទិញសម្ភារៈ ឬ ផែនការចូលនិវត្តន៍ ជាដើម។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងបាត
ការដាក់ប្រាក់តម្កល់ដំបូង	40,000 រៀល
	10 ដុល្លារ
រយៈពេល	03 - 36 ខែ

គណនីសប្បុរស

គណនីសប្បុរស ហៅកាត់ថា SDA គឺជាប្រភេទគណនីមានកាលកំណត់មួយទៀត ដែលមានរួមបញ្ចូលកម្មវិធីសប្បុរសធម៌ ឬកម្មវិធីជួយសង្គម។ តាមរយៈផលិតផលថ្មីនេះ អតិថិជនអាចជ្រើសរើសអង្គការសប្បុរសធម៌ដែលខ្លួនពេញចិត្តដើម្បីបរិច្ចាគ។ នៅថ្ងៃកាលបរិច្ឆេទកំណត់ អតិថិជននឹងទទួលបានការប្រាក់គោល ហើយចំនួនទឹកប្រាក់ដែលត្រូវបរិច្ចាគនឹងត្រូវបានកាត់ចេញពីការប្រាក់ដែលទទួលបាន រួចផ្ទេរទៅគណនីរបស់អង្គការសប្បុរសធម៌ដែលបានជ្រើសរើសដោយបង្ហាញឈ្មោះរបស់អតិថិជន។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងបាត
ការដាក់ប្រាក់តម្កល់ដំបូង	100,000 រៀល
	25 ដុល្លារ
រយៈពេល	03 - 12 ខែ



គណនីសប្បុរស
12.27%
គណនីសង្ឃឹម
14.17%
គណនីកូនល្អ
0.85%
គណនីសន្សំតាមផែនការ
0.23%
សមតុល្យប្រាក់បញ្ញើសន្សំ
គណនីចម្រើនទ្រព្យ
72.48%



គណនីសន្សំតាមផែនការ
0.11%
គណនីចម្រើនទ្រព្យ
6.92%
គណនីកូនល្អ
Best Child
4.61%
គណនីសប្បុរស
0.27%
អតិថិជន
គណនីសង្ឃឹម
88.08%



គណនីសន្សំតាមផែនការ
0.11%
គណនីចម្រើនទ្រព្យ
6.89%
គណនីសប្បុរស
0.37%
គណនីកូនល្អ
4.24%
គណនី
គណនីសង្ឃឹម
88.37%

ប្រាក់កម្ចី

កម្ចីអាជីវកម្ម

កម្ចីអាជីវកម្ម គឺជាកម្ចីដែលត្រូវបានប្រើប្រាស់សម្រាប់ជាទុនបង្វិល ដើមទុនវិនិយោគសម្រាប់អាជីវកម្ម ការទិញទ្រព្យអាជីវកម្ម ការជួញដូរអាជីវកម្ម រួមបញ្ចូលទាំង ការជួញដូរផ្នែកកសិកម្ម និងប្រើប្រាស់ផងដែរ សម្រាប់សកម្មភាពរកប្រាក់ចំណូលដែលទទួលផលចំណូលជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ជារៀងរាល់ 2សប្តាហ៍ ឬ ប្រចាំខែ។

រូបិយប័ណ្ណ	រៀល និង ដុល្លារ
ទំហំកម្ចី	រហូតដល់ 400,000,000 រៀល
	រហូតដល់ 100,000 ដុល្លារ
	រហូតដល់ 400,000បាត
រយៈពេលកម្ចី	03 - 84 ខែ

កម្ចីកសិកម្ម

កម្ចីកសិកម្ម គឺជាកម្ចីដែលត្រូវបានប្រើប្រាស់សម្រាប់ការចំណាយលើវត្ថុធាតុដើម ទ្រព្យសកម្មនៃអាជីវកម្មកសិកម្ម ឬសកម្មភាពរកប្រាក់ចំណូលទាំងឡាយដែលទទួលផលចំណូលតាមរដូវកាល ដូចជា ការដាំដំណាំ ការចិញ្ចឹមសត្វ ។ល។

រូបិយប័ណ្ណ	រៀល និង ដុល្លារ
ទំហំកម្ចី	រហូតដល់ 200,000,000រៀល
	រហូតដល់ 50,000 ដុល្លារ
	រហូតដល់ 400,000 បាត
រយៈពេលកម្ចី	03 - 72 ខែ

កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន

កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន គឺជាកម្ចីដែលត្រូវបានប្រើប្រាស់សម្រាប់ទិញសម្ភារប្រើប្រាស់ផ្ទាល់ខ្លួន ឬទ្រព្យសម្បត្តិគ្រួសារ ក៏ដូចជាផ្តល់ហិរញ្ញប្បទានសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ ក្នុងគោលបំណងធ្វើឱ្យជីវភាពរស់នៅជាមូលដ្ឋានមានភាពល្អប្រសើរ។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងថៃបាត
ទំហំកម្ចី	រហូតដល់ 200,000,000 រៀល
	រហូតដល់ 50,000 ដុល្លារ
	រហូតដល់ 400,000 បាត
រយៈពេលកម្ចី	03 - 72 ខែ

កម្ចីគេហដ្ឋាន

កម្ចីគេហដ្ឋាន គឺជាប្រភេទកម្ចីដែលត្រូវបានប្រើប្រាស់សម្រាប់ទិញ/សាងសង់ផ្ទះថ្មី ឬ កែលម្អផ្ទះដែលមានស្រាប់ ឬ ពង្រីក និងជួសជុលផ្ទះដែលមានស្រាប់។ កម្ចីនេះ ក៏អាចប្រើប្រាស់សម្រាប់ការទិញដីដើម្បីសាងសង់ផ្ទះផងដែរ។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងបាត
ទំហំកម្ចី	រហូតដល់ 400,000,000 រៀល
	រហូតដល់ 100,000 ដុល្លារ
	រហូតដល់ 400,000បាត
រយៈពេលកម្ចី	03 - 84 ខែ

កម្ចីការសិក្សា

កម្ចីការសិក្សា គឺជាប្រាក់កម្ចីផលិតផលសង្គម ដែលត្រូវបានប្រើប្រាស់សម្រាប់ជាជំនួយផ្នែកហិរញ្ញវត្ថុដល់បុគ្គលឬឪពុកម្តាយ/អាណាព្យាបាល ដែលមានបំណងចង់ឱ្យកូនបានរៀនសូត្រនូវកម្មវិធីសិក្សាអប់រំចំណេះដឹងទូទៅ ឬ សម្រាប់បន្តការអប់រំជាន់ខ្ពស់ ឬ សិក្សាជំនាញវិជ្ជាជីវៈ សម្រាប់ប្រកបរបរចិញ្ចឹមជីវិត។

រូបិយប័ណ្ណ	រៀល និងដុល្លារ
ទំហំកម្ចី	រហូតដល់ 20,000,000 រៀល
	រហូតដល់ 5,000 ដុល្លារ
រយៈពេលកម្ចី	កម្រិតសិក្សាអប់រំចំណេះដឹងទូទៅ ៖ 03 - 12 ខែ
	កម្រិតបរិញ្ញាបត្ររង ៖ 03 - 48 ខែ
	កម្រិតបរិញ្ញាបត្រ ៖ 03 - 84 ខែ
	កម្រិតអនុបណ្ឌិត ៖ 03 - 48 ខែ
	វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ៖ 03 - 24ខែ

កម្ចីគ្រាអាសន្ន

កម្ចីគ្រាអាសន្ន ជាប្រភេទកម្ចីផលិតផលសង្គម ដែលត្រូវបានប្រើប្រាស់ដើម្បីធានាបាននូវការឆ្លើយតបទាន់ពេលវេលា ទៅនឹងតម្រូវការហិរញ្ញវត្ថុរបស់អតិថិជន នៅក្នុងពេលមានហេតុការណ៍បន្ទាន់ និង/ឬព្រឹត្តិការណ៍ដែលមិនអាចគិតទុកជាមុន ទាំងគ្រោះធម្មជាតិ ឬ គ្រោះថ្នាក់ផ្ទាល់ខ្លួន។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងបាត
ទំហំកម្ចី	រហូតដល់ 4,000,000 រៀល
	រហូតដល់ 1,000 ដុល្លារ
	រហូតដល់ 40,000បាត
រយៈពេលកម្ចី	03 - 24 ខែ





កម្ចីកូនកាត់ពិសេស

កម្ចីកូនកាត់ពិសេស គឺសំដៅទៅលើកម្ចីដែលមានរបៀបបង់សងពិសេស ដែល50% នៃកម្ចីសរុប អាចរក្សាទុកបង់សងនៅចុងវគ្គ និង50%ទៀត ត្រូវបង់សងរំលស់ប្រាក់ដើមប្រចាំខែ។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងបាត
ទំហំកម្ចី	រហូតដល់ 400,000,000 រៀល រហូតដល់ 100,000 ដុល្លារ រហូតដល់ 400,000 បាត
រយៈពេលកម្ចី	រហូតដល់ 60 ខែ

កម្ចីសហគ្រាសខ្នាតតូច និងមធ្យម

កម្ចីសហគ្រាសខ្នាតតូច និងមធ្យម ត្រូវបានទទួលស្គាល់ថាជាកម្ចីសម្រាប់សហគ្រាសធុនតូច និងមធ្យម។ កម្ចីនេះផ្តល់ជូនសម្រាប់អតិថិជនជារូបវន្តបុគ្គល និងនីតិបុគ្គល / សហគ្រាស។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងបាត
ទំហំកម្ចី	កម្ចីទំហំធំ ដែលសាកសមនឹងគ្រប់ប្រភេទអាជីវកម្មទាំងអស់។
រយៈពេល	រហូតដល់ 120 ខែ។
អត្រាការប្រាក់ប្រចាំឆ្នាំ	អត្រាការប្រាក់ប្រកួតប្រជែង។
របៀបបង់សង	ជម្រើសនៃការបង់សងបត់បែន
ទ្រព្យធានាដែលអាចទទួលយកបាន	• គ្រប់ប្រភេទអចលនវត្ថុទាំងអស់ដែលមានទីតាំងគ្រប់កន្លែងក្នុងរាជធានីភ្នំពេញ និងគ្រប់បណ្តាខេត្ត/ក្រុង។ • គណនីមានកាលកំណត់របស់ធនាគារអ្សីុ។ • ការធានាដោយភាគីទី3។ • ប័ណ្ណធានាពីធនាគារ

កម្ចីសាជីវកម្ម

ជាឥណទានដែលផ្តល់ជូនអតិថិជនដែលជា ម្ចាស់សហគ្រាសធុនតូច ឬ មធ្យម និង ក្រុមហ៊ុនចុះបញ្ជី ដែលមានតម្រូវការហិរញ្ញវត្ថុសម្រាប់ជាដើមទុនបង្វិលក្នុងការគាំទ្រដល់ប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ និង ជាទុនចំណាយលើការទិញ ឬ តំហែទាំទ្រព្យសកម្មរយៈពេលវែងដូចជា អចលនទ្រព្យ គ្រឿងបរិក្ខារ និង ហេដ្ឋារចនាសម្ព័ន្ធជាដើម ដើម្បីបង្កើនប្រសិទ្ធិភាព និងសមត្ថភាពរបស់ក្រុមហ៊ុន។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងបាត
ទំហំកម្ចី	កម្ចីទំហំធំ ដែលសាកសមនឹងគ្រប់ប្រភេទអាជីវកម្មទាំងអស់។
រយៈពេល	រហូតដល់ 120 ខែ។
អត្រាការប្រាក់ប្រចាំឆ្នាំ	អត្រាការប្រាក់ប្រកួតប្រជែង។
របៀបបង់សង	ជម្រើសនៃការបង់សងបត់បែន

សេវាផ្ទេរប្រាក់

សេវាផ្ទេរប្រាក់អន្តរធនាគារ

សេវាផ្ទេរប្រាក់អន្តរធនាគារ គឺជាសេវាផ្ទេរប្រាក់មួយប្រភេទ ដែលធ្វើប្រតិបត្តិការរវាងស្ថាប័នហិរញ្ញវត្ថុ (ធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបញ្ញើ) ដើម្បីផ្តល់នូវភាព ងាយស្រួល និងសេវាកម្មរហ័ស ទៅដល់អតិថិជន ក្នុង គោលបំណងផ្ទេរប្រាក់របស់ពួកគេទៅកាន់គណនីអ្នកទទួល។

ចំនួនទឹកប្រាក់ផ្ទេរ (ជាប្រាក់រៀល)	តម្លៃសេវា (ជាប្រាក់រៀល)
≤ 4 លាន	4,000
> 4 លាន ដល់ 20 លាន	8,000
> 20 លាន ដល់ 40 លាន	12,000

សេវាផ្ទេរប្រាក់ឆ្លងសាខា

សេវាផ្ទេរប្រាក់ឆ្លងសាខា គឺជាប្រភេទសេវាផ្ទេរប្រាក់ដែលអតិថិជនអាចប្រើដើម្បីផ្ទេរប្រាក់ពីសាខាមួយ ទៅសាខាមួយទៀត របស់ ធនាគារ អ៊្សី។ ប្រតិបត្តិការផ្ទេរប្រាក់អាចត្រូវបានធ្វើឡើងតាមរយៈសាច់ប្រាក់ ឬតាមរយៈគណនីបញ្ញើសន្សំ។

ប្រភេទប្រតិបត្តិការ	ពីសាច់ប្រាក់ទៅសាច់ប្រាក់ ឬ ពីគណនីទៅសាច់ប្រាក់			សាច់ប្រាក់ទៅគណនី ឬ ពីគណនីទៅគណនី		
រូបិយប័ណ្ណ	រៀល	ដុល្លារ	ថៃបាត	រៀល	ដុល្លារ	ថៃបាត
អត្រាកម្រៃសេវា		0.10%			0.08%	
កម្រៃសេវាអប្បរមា	4,000	1	40	3,000	1	40

សេវាផ្ទេរប្រាក់អន្តរជាតិ

សេវាផ្ទេរប្រាក់ចូលពីក្រៅប្រទេស

ការទទួលប្រាក់ដែលផ្ទេរចូលមកក្នុងប្រទេសតាមរយៈធនាគារ អ៊ូរី (ខេមបូឌា) ម.ក មានភាពឆាប់រហ័ស សុវត្ថិភាព និងមានភាពងាយស្រួល។ អតិថិជនដែលមានគណនីសន្សំជាមួយ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក អាចទទួលបានទឹកប្រាក់ដែលផ្ទេរចូលមកក្នុងប្រទេស ជាមួយនឹងភាពងាយស្រួលបន្ថែមទៀតដែលអាចឆែកទឹកប្រាក់ដែលផ្ទេរចូល និងសមតុល្យទឹកប្រាក់ក្នុងគណនីតាមរយៈ កម្មវិធីធនាគារចល័តក្នុងទូរស័ព្ទដៃ ដែលផ្តល់ជូនដោយមិនគិតថ្លៃ ។

ប្រភេទព័ត៌មាន	ព័ត៌មានដែលត្រូវបំពេញ
ឈ្មោះអ្នកទទួលផល	បំពេញឈ្មោះដែលមានជាមួយធនាគារ អ៊ូរី
អាសយដ្ឋានអ្នកទទួលផល	បំពេញអាសយដ្ឋានបច្ចុប្បន្ន
លេខគណនីអ្នកទទួលផល	បំពេញលេខគណនី៥ខ្ទង់ដែលមានជាមួយធនាគារ អ៊ូរី
ឈ្មោះធនាគារអ្នកទទួលផល	ធនាគារ អ៊ូរី (ខេមបូឌា) ម.ក
អាសយដ្ឋានធនាគារអ្នកទទួលផល	អគារលេខ 398 មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង1 ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
SWIFT កូដធនាគារអ្នកទទួលផល	HVBKKHPP

កម្រៃសេវាផ្ទេរប្រាក់ចូល	
គ្រប់ទំហំទឹកប្រាក់នៃប្រតិបត្តិការ	0.07% នៃចំនួនទឹកប្រាក់ដែលទទួល ឬ អប្បបរមា USD10

សេវាផ្ទេរប្រាក់ក្រៅប្រទេស

ជាមួយវិសាលភាពនៃបណ្តាញធនាគារដ៏ធំធេងនៅជុំវិញ ពិភពលោករបស់ធនាគា រអ៊ូរី (ខេមបូឌា) ម.ក អតិថិជនអាចផ្ទេរប្រាក់ទៅប្រទេសជាច្រើននៅលើពិភពលោកតាមរយៈប្រព័ន្ធ SWIFT ដែលជាប្រព័ន្ធសុវត្ថិភាពមួយដែលធនាគារលំដាប់ថ្នាក់ពិភពលោកបានប្រើប្រាស់ក្នុងការផ្ទេរប្រាក់ជាលក្ខណៈអន្តរជាតិ។ អតិថិជនអាចផ្ញើប្រាក់អោយក្រុមគ្រួសារ ទូទាត់ថ្លៃទំនិញ និងគោលបំណងផ្សេងទៀត នៅគ្រប់ 138 សាខារបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

រូបិយប័ណ្ណ	USD តែប៉ុណ្ណោះ
ព័ត៌មានរបស់អ្នកទទួល	ឈ្មោះធនាគារ
	ឈ្មោះគណនី
	លេខគណនី
	SWIFT កូដ

សេវាធនាគារឌីជីថល

សេវាធនាគារចល័ត គឺជាការផ្តល់ជូននូវសេវាធនាគារ ឬសេវាហិរញ្ញវត្ថុមួយ ជាមួយនឹងជំនួយទូរគមនាគមន៍ចល័ត ដែលអនុញ្ញាត អោយអតិថិជនធ្វើប្រតិបត្តិការធនាគារដោយខ្លួនឯងតាមរយៈឧបករណ៍ ចល័តរបស់អតិថិជន។

ការបន្ថែមមុខងារថ្មី

ដោយស្របតាមទីផ្សារប្រកួតប្រជែង ក៏ដូចជាបំពេញតម្រូវការអតិថិជន សេវាកម្មធនាគារចល័តត្រូវបានអភិវឌ្ឍន៍ឥតឈប់ឈរ។ មុខងារទាំងនោះមានដូចជា៖

#	មុខងារ	សេចក្តីរៀបរាប់ពីមុខងារ
1	បន្ថែមប្រព័ន្ធសុវត្ថិភាព	ពង្រឹងប្រព័ន្ធការសុវត្ថិភាពរបស់កម្មវិធីធនាគារចល័តសម្រាប់អតិថិជន។
2	បន្ថែមមុខងារផ្ទេរប្រាក់តាមរយៈ សេវាផ្ទេរមូលនិធិភ្លាមៗ	អតិថិជនអាចប្រើប្រាស់កម្មវិធីធនាគារចល័តដើម្បីផ្ទេរប្រាក់ទៅកាន់គណនីរបស់ធនាគារផ្សេង ឬទៅកាន់លេខទូរស័ព្ទរបស់ អ្នកទទួលតាមរយៈប្រព័ន្ធមូលនិធិភ្លាមៗរបស់ធនាគារជាតិ។
3	បន្ថែមមុខងារបង្កើតកូដ QR	អតិថិជនអាចបង្កើតកូដ QR ដើម្បីទទួលប្រាក់ពីអ្នកដទៃបាន។
4	ស្កេនកូដ QR ដើម្បីផ្ទេរ ឬទូទាត់	អតិថិជនអាចស្កេនកូដ QR ដើម្បីផ្ទេរប្រាក់ទៅពីអ្នកដទៃ ឬទូទាត់ទំនិញតាមហាងនានាដែលជាដៃគូរបស់ធនាគារអ៊ូរី ឬបាគង។
5	បន្ថែមមុខងារស្នើសុំប្រាក់កម្ចី	អតិថិជនអាចស្នើសុំកម្ចីតាមរយៈកម្មវិធីធនាគារចល័ត
6	បន្ថែមមុខងារឧបករណ៍គណនា	អតិថិជនអាចគណនា កម្ចី ការប្រាក់បញ្ញើ និង អត្រាប្តូរប្រាក់។
7	បន្ថែមសេវាទូទាត់វិក្កយបត្រឯកជន	អតិថិជនអាចទូទាត់វិក្កយបត្រឯកជន និងវិក្កយបត្រទូទៅបន្ថែមទៀត។
8	អភិវឌ្ឍល្បឿន	ប្រតិបត្តិការលើកម្មវិធីធនាគារចល័តមានល្បឿនកាន់តែលឿន។
8	បន្ថែមមុខងារបើកគណនីមានកាលកំណត់	អតិថិជនអាចបើកគណនីមានកាលកំណត់តាមរយៈកម្មវិធីធនាគារចល័តបាន។

សេវាទូទាត់បាគង

ធនាគារ អ៊ូរី គឺជាសមាជិកក្នុងប្រព័ន្ធបាគង ហើយបច្ចុប្បន្ននេះ ធនាគារ អ៊ូរី បានបញ្ចូលកម្មវិធីបាគងចូលទៅក្នុង WOORI WON Cambodia ដែលអតិថិជនអាចប្រើប្រាស់ គណនីបាគង នៅលើ WOORI WON Cambodia ដោយភាពងាយស្រួល ។

អត្ថប្រយោជន៍នៃការប្រើប្រាស់បាគងនៅលើ WOORI WON Cambodia ការចុះឈ្មោះគណនីបាគងតាមរយៈ WOORI WON Cambodia

- ផ្ទេរ និងទទួលប្រាក់ភ្លាមៗ ប្រកបដោយសុវត្ថិភាព ពីគណនីសន្សំ ធនាគារ អ៊ូរី ទៅកាន់ គណនីរបស់សមាជិកនៃប្រព័ន្ធបាគងដោយឥតគិតថ្លៃសេវារហូតដល់ថ្ងៃ31 ខែធ្នូ ឆ្នាំ2022 លើ WOORI WON Cambodia
- ការដាក់ប្រាក់ចូលគណនីធនាគាររបស់សមាជិកបាគង
- ការទូទាត់តាមរយៈ QR
- បង្កើតQRកូដថ្មី ក្នុងករណីបាត់លេខកូដសម្ងាត់ដើម្បីប្រើប្រាស់គណនីបាគងឡើងវិញ
- ការចូលប្រើគណនីបាគងចាស់ឡើងវិញលើ WOORI WON Cambodia
- ពិនិត្យសមតុល្យគណនី និងប្រវត្តិប្រតិបត្តិការបាគងលើ WOORI WON Cambodia
- ពិនិត្យព័ត៌មានគណនីបាគងរបស់អ្នកលើ WOORI WON Cambodia

ការប្រើប្រាស់សេវាកម្ម តាមរយៈ WOORI WON Cambodia

- ធ្វើប្រតិបត្តិការហិរញ្ញវត្ថុ៖ ផ្ញើ; ទទួល; ការដាក់ប្រាក់; ទូទាត់តាមរយៈ QR
- ប្រតិបត្តិការផ្ទេរប្រាក់ ពីគណនីសន្សំធនាគារ អ៊ូរី ទៅកាន់គណនីចរន្ត ឬ គណនីសន្សំ របស់សមាជិកនៃប្រព័ន្ធបាគង
- ការចុះឈ្មោះគណនីបាគង
- ការស្តារចូលប្រើគណនីបាគងឡើងវិញ
- ការសង្គ្រោះគណនីបាគង
- បង្កើតកូដសង្គ្រោះថ្មី QR
- មើលសមតុល្យគណនីនិងប្រវត្តិប្រតិបត្តិការបាគង
- មើលព័ត៌មានគណនីបាគង

តាមរយៈបញ្ជររបស់ ធនាគារ អ៊ូរី

- ប្រតិបត្តិការដាក់សាច់ប្រាក់
- ប្រតិបត្តិការដកសាច់ប្រាក់
- ប្រតិបត្តិការផ្ទេរ ពីគណនីសន្សំធនាគារ អ៊ូរី ទៅកាន់ គណនីបាគង
- ប្រតិបត្តិការផ្ទេរប្រាក់ ពីគណនីសន្សំធនាគារ អ៊ូរី ទៅកាន់គណនីចរន្ត ឬគណនីសន្សំ របស់សមាជិកនៃប្រព័ន្ធបាគង

សេវាផ្ទេរមូលនិធិភ្លាមៗ

ធនាគារ អ៊ូរី បានក្លាយជាសមាជិកនៃសេវាផ្ទេរមូលនិធិភ្លាមៗ (RFT)។ ឥឡូវនេះអតិថិជនរបស់ ធនាគារ អ៊ូរី ទាំងអស់អាចរីករាយប្រើប្រាស់ជាមួយសេវាកម្មផ្ទេរប្រាក់បន្ថែមថ្មីមួយទៀត ប្រកបដោយភាពងាយស្រួល និងមានសុវត្ថិភាព។

អត្ថប្រយោជន៍ដែលទទួលបាន

- អតិថិជនអាចផ្ទេរប្រាក់ទៅធនាគារផ្សេងៗ (ដែលជាសមាជិករបស់ RFT) ភ្លាមៗ
- អតិថិជនអាចផ្ទេរប្រាក់បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែងដោយប្រើប្រាស់ WOORI WON Cambodia
- វាមានភាពរហ័ស សុវត្ថិភាព និងងាយស្រួលសម្រាប់អតិថិជនក្នុងការផ្ទេរប្រាក់ឆ្លងធនាគារ។

ការប្រើប្រាស់សេវាកម្មតាមរយៈ WOORI WON Cambodia

- ផ្ទេរប្រាក់តាមគណនី
- ផ្ទេរប្រាក់តាមលេខទូរស័ព្ទ

តាមរយៈបញ្ជររបស់ ធនាគារ អ៊ូរី

- ផ្ទេរប្រាក់តាមគណនី
- ការលុបចោលការផ្ទេរប្រាក់តាមគណនី
- ផ្ទេរប្រាក់តាមលេខទូរស័ព្ទ
- ការលុបចោលផ្ទេរប្រាក់តាមលេខទូរស័ព្ទ
- ការទូទាត់សម្រាប់ប្រតិបត្តិការផ្ទេរប្រាក់ពីគណនីទៅលេខទូរស័ព្ទ
- ការសាកសួរអំពីការផ្ទេរប្រាក់

សេវាអេធីអឹម និងប័ណ្ណឥណពន្ធ

សេវាកម្ម អេធីអឹម នឹង ប័ណ្ណឥណពន្ធ បានត្រៀមខ្លួនរួចជាស្រេចដើម្បីបម្រើអតិថិជនជាមួយនឹងភាពងាយស្រួល ភាពបត់បែន និងសុវត្ថិភាពនៅទូទាំងតំបន់ក្នុងប្រទេសកម្ពុជា។ ធនាគារ អ៊ូរី ក៏បានភ្ជាប់ប្រព័ន្ធអេធីអឹម របស់ខ្លួនដោយជោគជ័យទៅនឹងប្រព័ន្ធ Cambodian Shared Switch (CSS) ដែលត្រូវបានរៀបចំ និងគាំទ្រដោយធនាគារជាតិនៃកម្ពុជា។ នេះកំពុងតែផ្តល់នូវភាពបត់បែននឹងភាពងាយស្រួលសម្រាប់អតិថិជនដើម្បីធ្វើប្រតិបត្តិការលើម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ សេវាកម្ម អេធីអឹម នឹង POS របស់ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch តាមតម្រូវការដោយមិនគិតពីពេលវេលា និងទីតាំង។ ធនាគារ អ៊ូរី ត្រៀមខ្លួនជាស្រេចដើម្បីគាំទ្រជាមួយនឹងមុខងារផ្សេងៗរួមទាំងប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុនៅលើម៉ាស៊ីនអេធីអឹម និង POS ដូចខាងក្រោម។

សេវាកម្មម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch (CSS)

#	ប្រត្តិបត្តិការ	សេចក្តីរៀបរាប់ពីប្រត្តិបត្តិការ
1	ការដកប្រាក់	អតិថិជនអាចធ្វើប្រតិបត្តិការដកសាច់ប្រាក់ តាមរយៈម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch
2	ការពិនិត្យសមតុល្យភាព	អតិថិជនអាចធ្វើប្រតិបត្តិការពិនិត្យសមតុល្យភាព តាមរយៈម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch
3	របាយការណ៍សង្ខេប	អតិថិជនអាចធ្វើប្រតិបត្តិការពិនិត្យរបាយការណ៍សង្ខេប តាមរយៈម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch
4	ការប្តូរលេខសម្ងាត់	អតិថិជនអាចធ្វើប្រតិបត្តិការប្តូរលេខសម្ងាត់របស់ប័ណ្ណ តាមរយៈម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch
5	ការផ្ទេរប្រាក់ក្នុងធនាគារតែមួយ	ការធ្វើប្រតិបត្តិការនេះ គឺអនុញ្ញាតសម្រាប់តែអតិថិជនរបស់ ធនាគារ អ៊ូរី តែប៉ុណ្ណោះ
6	ការផ្ទេរប្រាក់អន្តរធនាគារ	អតិថិជនអាចធ្វើប្រតិបត្តិការផ្ទេរប្រាក់អន្តរធនាគារ តាមរយៈម៉ាស៊ីន អេធីអឹម របស់ធនាគារ អ៊ូរី ឬ ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch

តាមរយៈសេវាកម្មរបស់ម៉ាស៊ីន POS ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch (CSS)

#	ប្រត្តិបត្តិការ	សេចក្តីរៀបរាប់ពីប្រត្តិបត្តិការ
1	ការពិនិត្យសមតុល្យ	អតិថិជនរបស់ ធនាគារ អ៊ូរី អាចធ្វើប្រតិបត្តិការពិនិត្យសមតុល្យភាព តាមរយៈម៉ាស៊ីន POS របស់ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch
2	ការទូទាត់	អតិថិជនរបស់ ធនាគារ អ៊ូរី អាចធ្វើប្រតិបត្តិការទូទាត់ការទិញទំនិញ តាមរយៈម៉ាស៊ីន POS របស់ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch
3	ការដកប្រាក់	អតិថិជនរបស់ ធនាគារ អ៊ូរី អាចធ្វើប្រតិបត្តិការដកសាច់ប្រាក់ តាមរយៈម៉ាស៊ីន POS របស់ធនាគារដែលជាសមាជិករបស់ប្រព័ន្ធ Cambodian Shared Switch

សេវាធនាគារផ្សេងៗទៀត

សេវាបើកប្រាក់បៀវត្សរ៍

សេវាបើកប្រាក់បៀវត្សរ៍ គឺជាផលិតផលមួយក្នុងចំណោមផលិតផលជាច្រើនទៀតរបស់ ធនាគារ អ៊ូរី ត្រូវបានរៀបចំឡើងដើម្បីបំពេញតាមតម្រូវការរបស់អតិថិជន ដែលជាជានិយោជក តាមរយៈប្រព័ន្ធគ្រប់គ្រងច្បាស់លាស់ និងមានភាពងាយស្រួលក្នុងការទូទាត់ដូចជា (ប្រាក់បៀវត្សរ៍ ប្រាក់លើកទឹកចិត្ត និងប្រាក់រង្វាន់ផ្សេងៗ) ដល់បុគ្គលិករបស់ពួកគេ។ សេវានេះនឹងត្រូវបានអនុវត្តដោយយោងតាមសំណើរលើសេវាបើកប្រាក់បៀវត្សរ៍ ដែលត្រូវបានផ្តល់ដោយនិយោជក។ សេវានេះ នឹងអនុញ្ញាតឱ្យនិយោជកអាចធ្វើការទូទាត់ប្រាក់បៀវត្សរ៍ឱ្យបុគ្គលិករបស់ពួកគេ ដោយការផ្ទេរប្រាក់ចេញពីគណនីទូទាត់របស់ខ្លួនទៅកាន់គណនីបុគ្គលិកតាមរយៈ ធនាគារ អ៊ូរី ប្រកបដោយភាពងាយស្រួល រហ័ស និងសុវត្ថិភាព។ សេវា នេះក៏នឹងផ្តល់នូវឱកាស និងអត្ថប្រយោជន៍ជាច្រើនផ្សេងទៀតដល់បុគ្គលិករបស់ពួកគេ តាមរយៈការប្រើប្រាស់ផលិតផល និងសេវា ផ្សេងទៀតរបស់ ធនាគារ អ៊ូរី ដូចជាទទួលបានត្រាការប្រាក់ខ្ពស់ពីប្រាក់សន្សំ ទទួលបានសេវាអេធីអឹម សេវាធនាគារចល័តជាដើម.។

រូបិយប័ណ្ណ	រៀល, ដុល្លារ និងថៃបាត
កម្រៃសេវា	1,000 រៀល
	0.25 ដុល្លារ
	7.50 ថៃបាត
រយៈពេល	គណនីមេ និងគណនីកូន តម្រូវមានគណនីសង្សឹម

សេវាបំពេញតុល្យភាព គណនីរបស់ភ្នាក់ងារ

សេវាកម្មបំពេញសមតុល្យគណនីរបស់ភ្នាក់ងារ គឺជាសេវាមួយរបស់ ធនាគារ អ៊ូរី ដែលបង្កើតឡើងដើម្បីជួយសម្រួលដល់ភ្នាក់ងារដែលជាដៃគូរបស់ ធនាគារ អ៊ូរី ដើម្បីចាត់ចែង Wallet ឬគណនីរបស់ពួកគេ។ សេវាកម្មនេះអនុញ្ញាតឱ្យភ្នាក់ងារធ្វើប្រតិបត្តិការដាក់ប្រាក់ចូល និងដកប្រាក់ចេញពី Wallet ឬគណនីតាមរយៈបញ្ជររបស់ ធនាគារ អ៊ូរី ឬមធ្យោបាយផ្សេងទៀតរបស់ ធនាគារ អ៊ូរី ជាមួយនឹងសេវាកម្មយ៉ាងឆាប់រហ័ស សុវត្ថិភាព និងមានភាពងាយស្រួល។

រូបិយប័ណ្ណ	រៀល និងដុល្លារ
វិសាលភាពនៃសេវាកម្ម	1. ការដាក់ប្រាក់ចូល 1.1. ដាក់សាច់ប្រាក់ចូលគណនី Wallet របស់ភ្នាក់ងារ 1.2. ផ្ទេរប្រាក់ពីគណនីសង្សឹម ទៅគណនី Wallet របស់ភ្នាក់ងារ
	2. ការដកប្រាក់ចេញ 2.1. ដកសាច់ប្រាក់ចេញពីគណនី Wallet របស់ភ្នាក់ងារ
កម្រៃសេវា	ត្រូវបានកំណត់ដោយមានការព្រមព្រៀងរវាង ធនាគារ អ៊ូរី និងដៃគូដែលសហការ

របាយការណ៍
ស្ដីពីនិរន្តរភាពបរិស្ថាន និងសង្គម

	2021	2020	2019	2018	2017
សូចនាករលើការអនុវត្តផ្នែកបរិស្ថាន					
សម្ភារ					
ក្រដាស ប្រើគិតជាគីឡូក្រាម /FTE (1)	10.74	18.83	21.27	19.80	23.83
ទម្រង់ប្រាក់កម្ចី ប្រើគិតជាគីឡូក្រាម / FTE	3.18	5.10	5.25	5.77	5.76
ក្រដាសប្រើប្រាស់ក្នុងការិយាល័យ ប្រើគិតជាគីឡូក្រាម /FTE	7.56	13.73	16.03	14.03	18.07
សំណល់					
សំណល់ក្រដាស គិតជាគីឡូក្រាម / FTE	1.13	2.10	2.45	3.12	2.01
ក្រដាសជូតមាត់ ប្រើគិតជាគីឡូក្រាម	2,767.95	2,973.78	2,304.51	2,360.23	1,490.98
ក្រដាសជូតដៃ ប្រើគិតជាគីឡូក្រាម	329.79	1,162.64	938.35	809.20	673.20
ក្រដាសបង្គន់ ប្រើគិតជាគីឡូក្រាម	830.88	846.94	658.11	1,152.26	618.74
ថាមពល					
ចរន្តអគ្គិសនី ប្រើគិតជាគីឡូវ៉ាត់ម៉ោង/FTE	**428.14**	**549.59**	**607.07**	**617.00**	**668.11**
ប្រេងសាំង ប្រើគិតជាលីត្រ /FTE	**244.47**	**264.92**	**259.51**	**222.81**	**394.81**
ប្រេងសាំងសម្រាប់ទោចក្រយានយន្ត ប្រើគិតជាលីត្រ	844,931.15	627,846.08	411,685.15	306,716.76	544,565.35
ប្រេងសាំងសម្រាប់រថយន្ត ប្រើគិតជាលីត្រ	4,863.87	1,063.74	1,717.28	1,648.71	2,248.30
ប្រេងម៉ាស៊ូត ប្រើគិតជាលីត្រ /FTE	**15.12**	**25.21**	**39.64**	**48.23**	**67.01**
ប្រេងម៉ាស៊ូតសម្រាប់ម៉ាស៊ីនភ្លើង ប្រើគិតជាលីត្រ	2,717.90	6,185.40	5,820.91	2,294.04	3,784.92

	2021	2020	2019	2018	2017
ប្រេងម៉ាស៊ូតសម្រាប់រថយន្ត ប្រើគិតជាលីត្រ	49,855.94	53,656.07	57,327.37	64,451	89,026
ប្រេងម៉ាស៊ីន ប្រើគិតជាលីត្រ /FTE	**N/A**	**N/A**	**N/A**	**N/A**	**N/A**
ការបញ្ចេញចោលនូវឧស្ម័នកាបូនិក (សមមូល គិតជាពាន់គីឡូក្រាម)(2)					
ចរន្តអគ្គិសនី	818.51	717.60	531.88	469.66	508.93
ប្រេងសាំង	2,039.50	1,509.41	992.17	740.08	1,312.35
ប្រេងម៉ាស៊ូត	144.58	164.56	173.66	183.55	255.23
ទឹក					
ទឹក ប្រើគិតជាម៉ែត្រគូប /FTE	**6.02**	**10.43**	**12.90**	**14.25**	**24.03**
ទឹក ប្រើគិតជាម៉ែត្រគូប	20,580.32	24,294.76	20,163.30	19413.06	32463.44
ទឹកបរិសុទ្ធ ប្រើគិតជាម៉ែត្រគូប	339.20	465.81	391.43	304.74	818.31
ការធ្វើដំណើរ					
ដោយរថយន្ត គិតជាគីឡូម៉ែត្រ /FTE	160.68	235.27	427.17	545	757
ដោយទោចក្រយានយន្ត គិតជាគីឡូម៉ែត្រ /FTE	9,764.89	10,579.71	9,791.05	9,223.70	9,913.52
សូចនាករលើការអនុវត្តផ្នែកបរិស្ថាន					
ការបម្រើការងារ					
ចំនួនបុគ្គលិក	3,780	2,984	1,682	1,429	1,389
ស្រី	872	632	462	445	466
ប្រុស	2,908	2,352	1,220	984	923
ចំនួនបុគ្គលិក (FTE)	3,476	2,374	1,593	1,384	1,385

(1) FTE (Full Time Equivalent): ចំនួនមធ្យមនៃកម្មករនិយោជិត បម្រើការពេញម៉ោងក្នុងមួយឆ្នាំ។

(2) សមមូលឧស្ម័នកាបូនិកត្រូវបានគណនាយោងតាមគោលការណ៍របស់ Greenhouse Gas Protocol។

បណ្តាញសាខា
និងតំបន់ប្រតិបត្តិការ



តំបន់ប្រតិបត្តិការ

រាជធានី/ខេត្ត 25

បណ្តាញសាខា 138

ការិយាល័យប្រចាំតំបន់ 18



ខណ្ឌច្បារអំពៅ
ខណ្ឌដង្កោ
ខណ្ឌមានជ័យ
ខណ្ឌសែនសុខ
ខណ្ឌទួលគោក
ខណ្ឌដូនពេញ
ខណ្ឌ 7មករា
ខណ្ឌពោធិ៍សែនជ័យ
ខណ្ឌជ្រោយចង្វារ
ខណ្ឌព្រែកព្នៅ
ខណ្ឌឫស្សីកែវ
ខណ្ឌចំការមន

VI របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021		ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្ម				
សាច់ប្រាក់ក្នុងដៃ	**11,469,663**	**46,727,407**	6,954,406	28,130,572
សមតុល្យជាមួយធនាគារជាតិ	**83,355,538**	**339,590,462**	57,185,983	231,317,301
សមតុល្យជាមួយធនាគារផ្សេងៗ	**122,652,452**	**499,686,089**	76,328,347	308,748,164
ឥណទានផ្តល់អតិថិជន	**918,491,190**	**3,741,933,108**	618,702,108	2,502,650,027
វិនិយោគលើមូលបត្រ	**15,353**	**62,548**	15,353	62,103
ទ្រព្យសម្បត្តិ និងបរិក្ខារ	**5,785,138**	**23,568,652**	3,880,691	15,697,395
ទ្រព្យសកម្មអរូបី	**3,753,609**	**15,292,203**	1,846,936	7,470,856
សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម	**9,840,596**	**40,090,588**	5,663,578	22,909,173
ពន្ធពន្យាលើទ្រព្យសកម្ម	**3,674,847**	**14,971,327**	2,233,267	9,033,565
ទ្រព្យសកម្មផ្សេងៗ	**3,422,105**	**13,941,656**	1,404,758	5,682,246
ទ្រព្យសកម្មសរុប	**1,162,460,491**	**4,735,864,040**	**774,215,427**	**3,131,701,402**
មូលធន និងបំណុល				
មូលធន				
ដើមទុន	**175,895,100**	**703,580,400**	175,895,100	703,580,400
ទុនបម្រុងតាមបទប្បញ្ញត្តិ	**4,534,996**	**18,475,574**	3,344,256	13,527,516
ប្រាក់ចំណេញរក្សាទុក	**90,640,446**	**368,725,334**	47,036,791	191,768,996
ទុនបម្រុងបញ្ចូលគ្នា	**5,956,500**	**24,284,651**	5,956,500	24,284,651
លម្អៀងពីការប្តូររូបិយប័ណ្ណ	**-**	**13,542,210**	-	6,219,494
មូលធនសរុប	**277,027,042**	**1,128,608,169**	**232,232,647**	**939,381,057**
បំណុល				
ប្រាក់បញ្ញើរបស់អតិថិជន	**217,455,161**	**885,912,326**	124,508,666	503,637,554
បំណុលពន្ធចរន្ត	**11,664,774**	**47,522,289**	6,508,449	26,326,676
ប្រាក់កម្ចី	**100,308,125**	**408,655,301**	76,238,196	308,383,503
សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ	**539,505,568**	**2,197,945,684**	324,335,204	1,311,935,900
បំណុលភតិសន្យា	**9,764,532**	**39,780,703**	5,684,395	22,993,378
បំណុលផ្សេងៗ	**6,735,289**	**27,439,568**	4,707,870	19,043,334
បំណុលសរុប	**885,433,449**	**3,607,255,871**	541,982,780	2,192,320,345
មូលធន និងបំណុលសរុប	**1,162,460,491**	**4,735,864,040**	**774,215,427**	**3,131,701,402**

របាយការណ៍ចំណូលលម្អិត

	សម្រាប់ការិយបរិច្ឆេទបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021		សម្រាប់ការិយបរិច្ឆេទបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណូលការប្រាក់	**128,706,507**	**523,578,070**	85,201,273	347,365,590
ចំណាយការប្រាក់	**(22,773,077)**	**(92,640,877)**	(18,133,968)	(73,932,188)
ចំណូលការប្រាក់សុទ្ធ	**105,933,430**	**430,937,193**	**67,067,305**	**273,433,402**
ចំណូលសេវា និងកម្រៃជើងសារ	**15,219**	**61,911**	207,822	847,290
ចំណូលផ្សេងៗ	**963,158**	**3,918,127**	1,979,687	8,071,184
ចំណាយបុគ្គលិក	**(29,089,757)**	**(118,337,131)**	(20,561,390)	(83,828,787)
រំលស់ទ្រព្យរូបី និងរំលស់ទ្រព្យអរូបី	**(3,827,607)**	**(15,570,701)**	(3,192,302)	(13,015,015)
ចំណាយប្រតិបត្តិការផ្សេងៗ	**(12,070,787)**	**(49,103,966)**	(8,748,066)	(35,665,865)
ការខាតបង់លើឱនភាពនៃតម្លៃសុទ្ធ លើឧបករណ៍ហិរញ្ញវត្ថុ	**(5,798,219)**	**(23,587,155)**	(3,422,546)	(13,953,720)
ប្រាក់ចំណេញមុនបង់ពន្ធលើ ប្រាក់ចំណូល	**56,125,437**	**228,318,278**	**33,330,510**	**135,888,489**
ចំណាយពន្ធលើប្រាក់ចំណូល	**(11,331,042)**	**(46,094,679)**	(6,774,268)	(27,618,691)
ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ	**44,794,395**	**182,223,599**	**26,556,242**	**108,269,798**
ចំណូលលម្អិតផ្សេងៗ				
លម្អៀងពីការប្តូររូបិយប័ណ្ណ	**-**	**7,322,716**	-	949,580
ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ	**44,794,395**	**189,546,315**	**26,556,242**	**109,219,378**

របាយការណ៍បម្រែបម្រួលមូលធន

	កំណត់សម្គាល់	ដើមទុន	ទុនបម្រុងបទប្បញ្ញត្តិ	ចំណូលរក្សាទុក	ទុនបម្រុងបញ្ចូលគ្នា	លម្អៀងពីការប្តូររូបិយប័ណ្ណ	មូលធនសរុប
		ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
នាថ្ងៃទី01 ខែមករា ឆ្នាំ2021		175,895,100	3,344,256	47,036,791	5,956,500	6,219,494	232,232,647
ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ		-	-	44,794,395	-	-	44,794,395
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	-	-	-	7,322,716	-
ចំណូលលម្អិតសរុប		**-**	**-**	**44,794,395**	**-**	**7,322,716**	**44,794,395**
ការផ្ទេរទៅជាទុនបម្រុងតាមបទប្បញ្ញត្តិ	22	-	1,190,740	(1,190,740)	-	-	-
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021		**175,895,100**	**4,534,996**	**90,640,446**	**5,956,500**	**-**	**277,027,042**
សមមូលជាពាន់រៀល		**703,580,400**	**18,475,574**	**368,725,334**	**24,284,651**	**13,542,210**	**1,128,608,169**
នាថ្ងៃទី01 ខែមករា ឆ្នាំ2020		60,000,000	2,157,785	20,685,116	-	5,269,914	82,842,901
ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ		-	-	26,556,242	-	-	26,556,242
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	-	-	-	949,580	-
ចំណូលលម្អិតសរុប		**-**	**-**	**26,556,242**	**-**	**949,580**	**26,556,242**
ដើមទុនដែលបានបោះផ្សាយសម្រាប់ការរួមបញ្ចូលគ្នា	21	15,895,100	981,904	-	5,956,500	-	22,833,503
ការផ្ទេរទៅជាទុនបម្រុងតាមបទប្បញ្ញត្តិ	22	-	204,567	(204,567)	-	-	-
ចេញផ្សាយភាគហ៊ុនបន្ថែម	21	100,000,000	-	-	-	-	100,000,000
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020		**175,895,100**	**3,344,256**	**47,036,791**	**5,956,500**	**-**	**232,232,647**
សមមូលជាពាន់រៀល		**703,580,400**	**13,527,516**	**191,768,996**	**24,284,651**	**6,219,494**	**939,381,057**

របាយការណ៍លំហូរសាច់ប្រាក់

	សម្រាប់ការិយបរិច្ឆេទបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021		សម្រាប់ការិយបរិច្ឆេទបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ				
ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល	**56,125,437**	**228,318,278**	33,330,510	135,888,489
និយ័តកម្មសម្រាប់៖				
ចំណាយការប្រាក់	**22,773,077**	**92,640,877**	18,133,968	73,932,188
ការខាតបង់លើឱនភាពនៃតម្លៃសុទ្ធលើឧបករណ៍ហិរញ្ញវត្ថុ	**5,798,219**	**23,587,155**	3,422,546	13,953,720
រំលស់លើទ្រព្យរូបី និងរំលស់លើទ្រព្យអរូបី	**3,827,607**	**15,570,701**	3,192,302	13,015,015
ខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ	**1,169**	**4,755**	2,770	11,295
ចំណូលការប្រាក់	**(128,706,507)**	**(523,578,070)**	(85,201,273)	(347,365,590)
លម្អៀងពីការប្តូររូបិយប័ណ្ណ	**(22,218)**	**(90,383)**	(1,333,231)	(5,435,583)
ការជំរះបញ្ជីលើទ្រព្យសកម្មអរូបី	-	-	55	224
ខាតបង់ប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល	**(40,203,216)**	**(163,546,687)**	(28,452,354)	(116,000,247)
បម្រែបម្រួលទុនបង្វិល៖				
សមតុល្យជាមួយធនាគារជាតិ	**(40,028,641)**	**(162,836,512)**	(15,990,065)	(65,191,495)
ឥណទានផ្តល់ដល់អតិថិជន	**(305,498,343)**	**(1,242,767,259)**	(182,411,623)	(743,692,187)
ទ្រព្យសកម្មផ្សេងៗ	**1,559,731**	**6,344,989**	1,482,515	6,044,214
ប្រាក់បញ្ញើសន្សំពីអតិថិជន	**91,118,877**	**370,671,592**	56,160,998	228,968,389
បំណុលផ្សេងៗ	**857,052**	**3,486,488**	889,827	3,627,825
សាច់ប្រាក់បានប្រើក្នុងប្រតិបត្តិការ	**(292,194,540)**	**(1,188,647,389)**	(168,320,702)	(686,243,501)
ការប្រាក់ដែលបានទទួល	**125,129,429**	**509,026,517**	83,438,949	340,180,595
ការប្រាក់បានបង់	**(19,150,331)**	**(77,903,547)**	(15,206,751)	(61,997,924)
ពន្ធលើប្រាក់ចំណូលបានទូទាត់	**(7,616,297)**	**(30,983,096)**	(5,319,498)	(21,687,593)
សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពប្រតិបត្តិការ	**(193,831,739)**	**(788,507,515)**	(105,408,002)	(429,748,423)
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ				
សាច់ប្រាក់បានទទួលពីការរួមបញ្ចូល	-	-	11,102,431	45,264,603
ចំណូលពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ	**386**	**1,570**	78,724	320,958
ទិញទ្រព្យសកម្មអរូបី	**(2,359,152)**	**(9,597,030)**	(425,762)	(1,735,832)
ទិញទ្រព្យសម្បត្តិ និងបរិក្ខារ	**(3,288,697)**	**(13,378,419)**	(1,736,298)	(7,078,887)
ការបន្ថែមទៅប្រាក់បញ្ញើមានកាលកំណត់	**(49,809,350)**	**(202,624,436)**	(54,291,625)	(221,346,955)
សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ	**(55,456,813)**	**(225,598,315)**	(45,272,532)	(184,576,113)
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន				
ចំណូលពីប្រាក់កម្ចី	**95,238,095**	**387,428,570**	116,455,141	474,787,610
ការទូទាត់សងប្រាក់កម្ចី	**(71,168,539)**	**(289,513,617)**	(53,932,925)	(219,884,535)
ចំណូលពីប្រាក់កម្ចីទៅឱ្យភាគីពាក់ព័ន្ធ	**468,700,000**	**1,906,671,600**	52,500,000	214,042,500
ការទូទាត់លើសមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ	**(253,529,633)**	**(1,031,358,547)**	(27,179,127)	(110,809,301)
ការទូទាត់បំណុលភតិសន្យា	**(2,691,487)**	**(10,948,969)**	(1,990,818)	(8,116,565)
ចំណូលពីការបោះផ្សាយភាគហ៊ុនថ្មី	-	-	100,000,000	407,700,000
សាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញប្បទាន	**236,548,436**	**962,279,037**	185,852,271	757,719,709
ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល	**(12,740,116)**	**(51,826,793)**	35,171,737	143,395,173
សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមគ្រា	**58,639,185**	**237,195,502**	23,467,448	95,629,851
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	**1,624,098**	-	(1,829,530)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងគ្រា	**45,899,069**	**186,992,808**	58,639,185	237,195,502

របាយការណ៍
របស់សវនករឯករាជ្យ

ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត

ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង (កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

ជូនចំពោះភាគហ៊ុននិករបស់

ធនាគារ អ៊ីវ (ខេមបូឌា) ម.ក (ពីមុនត្រូវបានគេស្គាល់ជាដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក)

មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ អ៊ីវ (ខេមបូឌា) ម.ក (ពីមុនត្រូវបានគេស្គាល់ជា ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក) (ហៅកាត់ថា"ធនាគារ") ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងរបាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍ លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ព្រមជាមួយសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ ដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់ជាមួយ បង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់ សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs") ព្រមជាមួយសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ("NBC")។

មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ គឺត្រូវបានរៀបរាប់បន្ថែមនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំ គឺឯករាជ្យពីធនាគារ អនុលោមតាមក្រុមប្រឹក្សាស្តង់ដារវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌របស់គណនេយ្យករជំនាញ ("IESBA Code") រួមជាមួយនិងតម្រូវការ ក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើ របាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌

ទាំងនោះ និង IESBA Code។ យើងខ្ញុំ ជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន គឺគ្រប់គ្រាន់ និងសមស្រប ដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវទាំងស្រុងទៅលើការរៀបចំព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ដែលបានផ្តល់ជូនយើងខ្ញុំ មុនកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ ដែលភ្ជាប់ជាមួយនឹងរបាយការណ៍សវនកររបស់យើងខ្ញុំឡើយ។ ព័ត៌មានផ្សេងៗ រួមបញ្ចូលទាំងរបាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងទុកថាបានរៀបចំរួចរាល់ សម្រាប់យើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនោះ។

មតិយោបល់របស់យើងខ្ញុំនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទាំងស្រុងទៅលើព័ត៌មានផ្សេងៗ ហើយយើងខ្ញុំមិនបង្ហាញពីទម្រង់បែបបទនៃការធានាណាមួយ ឬធ្វើសេចក្តីសន្និដ្ឋានណាមួយឡើយ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំ ដែលទទួលបានពីការធ្វើសវនកម្ម ថាតើព័ត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើ យោងតាមការងារដែលយើងបានអនុវត្ត យើងខ្ញុំសន្និដ្ឋានថា បើមានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តណាមួយកើតមានឡើង យើងខ្ញុំត្រូវធ្វើការទាក់ទងជាមួយក្រុមប្រឹក្សាភិបាល និងឆ្លើយតបទៅលើបញ្ហាទាំងនេះដោយអនុលោមតាមការតម្រូវរបស់ CISA ៧២០ (បានធ្វើការកែតម្រូវ)។

ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោមទៅតាម ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះការវាយតម្លៃទៅលើ និរន្តរភាពអាជីវកម្មរបស់ធនាគារ និងធ្វើការលាតត្រដាង (ប្រសិនជាមាន) នូវបញ្ហាទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្ម នៅក្នុងការកត់ត្រាគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំលាយ ឬបញ្ឈប់ប្រតិបត្តិការរបស់ធនាគារ ឬក៏គ្មានជម្រើសជាក់ស្តែងណាមួយក្រៅពីអនុវត្តដូច្នេះ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យទៅលើដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការធ្វើរបាយការណ៍សវនកម្មដែលរួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយ ដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថា ការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលមានឡើយ។

ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គង រៀបចំ និងអនុវត្តនិតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនា ដោយសារតែការក្លែងបន្លំ រួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនិតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារនោះទេ។
- វាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀតដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- សេចក្តីសន្និដ្ឋាន ទៅលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្ម នៅក្នុងប្រព័ន្ធគណនេយ្យដោយគណៈគ្រប់គ្រង និងតាមរយៈភស្តុតាងសវនកម្មដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋានថាតើមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្តទាក់ទងនឹងព្រឹត្តិការណ៍ ឬកាលៈទេសៈទាំងឡាយណាដែលនាំឱ្យមានការសង្ស័យជាសារវន្ត ទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ធនាគារឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំតម្រូវឱ្យទាញចំណាប់អារម្មណ៍ ក្នុងរបាយការណ៍សវនករ លើកំណត់សម្គាល់ពាក់ពន្ធ័នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើ កំណត់សម្គាល់នេះពុំមានលក្ខណៈគ្រប់គ្រាន់ទេនោះ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ។ តែទោះជាយ៉ាងនេះក្តី ព្រឹត្តិការណ៍ ឬកាលៈទេសៈនាពេលអនាគត ក៏អាចបង្កឱ្យធនាគារមិនអាចបន្តនិរន្តរភាពអាជីវកម្មបានផងដែរ។
- វាយតម្លៃការបង្ហាញទូទៅ មាតិកា និងខ្លឹមសារ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងកំណត់សម្គាល់ផ្សេងៗ និងវាយតម្លៃថារបាយការណ៍ហិរញ្ញវត្ថុ តំណាងឱ្យប្រតិបត្តិការ និងព្រឹត្តិការណ៍ដែលជាមូលដ្ឋាន ដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

យើងខ្ញុំទាក់ទងជាមួយអ្នកទទួលបន្ទុកអភិបាលកិច្ចពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងៗ ដូចជា វិសាលភាព និងពេលវេលានៃការធ្វើសវនកម្ម និងការរកឃើញពីសវនកម្ម រួមទាំងកង្វះខាតសំខាន់ៗនៃការត្រួតពិនិត្យផ្ទៃក្នុងដែលបានរកឃើញនៅក្នុងកំឡុងពេលធ្វើសវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំក៏ផ្តល់ជូនក្រុមប្រឹក្សាភិបាល នូវសេចក្តីថ្លែងការណ៍មួយដែលយើងខ្ញុំបានអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ដែលទាក់ទងនឹងឯករាជ្យភាព ហើយយើងខ្ញុំធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលនូវបញ្ហាទាំងអស់ដែលនឹងគិតថាសមហេតុផលទៅលើឯករាជ្យភាពរបស់យើងខ្ញុំ និងការការពារដែលអាចមាន។

GRANT THORNTON (CAMBODIA) LIMITED
Certified Public Accountants
Registered Auditors

Ronald C. Almera
Partner – Audit and assurance

Phnom Penh, Kingdom of Cambodia
25 March 2022

របាយការណ៍
របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល (“អភិបាល”) សូមដាក់ជូននូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ពីមុនត្រូវបានគេស្គាល់ជា ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក) (ហៅកាត់ថា “ធនាគារ”) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទបានបញ្ចប់។

សកម្មភាពចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺការផ្តល់សេវាកម្មហិរញ្ញវត្ថុ និងផលិតផលហិរញ្ញវត្ថុដូចជាប្រាក់បញ្ញើ ឥណទាន រួមទាំងសេវាផ្ទេរប្រាក់ក្នុងស្រុក និងក្រៅប្រទេស សេវាធនាគារចល័ត សេវាទូទាត់ប្រាក់ និងសេវាកម្មម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ដល់ប្រជាជនកម្ពុជា តាមរយៈការិយាល័យកណ្តាល និងសាខារបស់ខ្លួននៅក្នុងរាជធានីភ្នំពេញ និងសាខាតាមបណ្តាខេត្តផ្សេងៗនៅក្នុងប្រទេសកម្ពុជា។

លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ធនាគារសម្រាប់ការិយបរិច្ឆេទបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ គឺត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណូលលម្អិត នៅទំព័រទី១០ ក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលអមមកជាមួយ។

ទុនបម្រុង និងសំវិធានធន

ពុំមានបម្រែបម្រួលជាសារវន្តលើទុនបម្រុង និងសំវិធានធននៅក្នុងអំឡុងការិយបរិច្ឆេទឡើយ លើកលែងតែបម្រែបម្រួលដែលត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ភាគលាភ

មិនមានភាគលាភបានប្រកាស ឬបានបង់នៅក្នុងការិយបរិច្ឆេទនេះទេ (ឆ្នាំ២០២០៖ មិនមាន)។

ដើមទុន

ដើមទុនបានបង់របស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ មានចំនួន ១៧៥.៨៩៥.១០០ ដុល្លារអាមេរិក ឬប្រហែលស្មើនឹង ៧០៣ ពាន់លានរៀល (ឆ្នាំ២០២០៖ ១៧៥.៨៩៥.១០០ ដុល្លារអាមេរិក ឬប្រហែលស្មើនឹង ៧០៣ ពាន់លានរៀល)។

ឥណទានអាក្រក់ និងជាប់សង្ស័យ

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង អភិបាលបានចាត់វិធានការសមស្រប ដើម្បីឈានដល់ការអះអាងថា នីតិវិធីពាក់ព័ន្ធនឹងការលុបចេញពីបញ្ជីនូវឥណទានអាក្រក់ ឬការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យ ត្រូវបានយកមកអនុវត្ត ហើយជឿជាក់ថារាល់ឥណទានអាក្រក់ត្រូវបានលុបចេញពីបញ្ជី និងបានធ្វើសំវិធានធនគ្រប់គ្រាន់ចំពោះឥណទានជាប់សង្ស័យ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកលើការយល់ដឹងច្បាស់លាស់បំផុត អភិបាលមិនបានយល់ដឹងពីស្ថានការណ៍ណាមួយដែលធ្វើឱ្យមានការជម្រះបញ្ជីលើឥណទានអាក្រក់ និងបុរេប្រទាន ព្រមទាំងសំវិធានធននៃសមតុល្យសាច់ប្រាក់របស់បំណុលអាក្រក់ និងឥណទានជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារដែលមានភាពខ្វះខាតជាសារវន្ត។

ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង អភិបាលបានចាត់វិធានការសមស្រប ដើម្បីឈានដល់ការអះអាងថា បណ្ដាទ្រព្យសកម្មដែលទំនងជាមិនអាចទទួលស្គាល់ក្នុងតម្លៃដើមក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដូចដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ត្រូវបានកាត់បន្ថយតម្លៃនៅត្រឹមតម្លៃដែលគេរំពឹងទុកថាអាចលក់យកបាន។

នាកាលបរិច្ឆេទនៃរបាយកាណ៍នេះ អភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលអាច បណ្ដាលឱ្យការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានភាពពុំត្រឹមត្រូវនោះទេ។

វិធីសាស្ត្រកំណត់តម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ អភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង ដែលធ្វើឱ្យប៉ះពាល់ដល់វិធីសាស្ត្រវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះពុំមាន៖

(ក). ការដាក់បន្ទុកលើទ្រព្យសកម្មណាមួយរបស់ធនាគារ លើការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីសម្រាប់កាលបរិច្ឆេទដែលបានបញ្ចប់មក លើកលែងតែបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង

(ខ). បំណុលយថាហេតុណាមួយ បានកើតមានឡើងចំពោះធនាគារតាំងពីចុងការិយបរិច្ឆេទដែលបានបញ្ចប់ ក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារនោះទេ។

ផ្អែកតាមទស្សនៈរបស់អភិបាល យល់ឃើញថាពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗ របស់ធនាគារ ដែលត្រូវបានទាមទារឱ្យសងក្នុងអំឡុងការិយបរិច្ឆេទ ១២ ខែនេះបន្ទាប់ពីបញ្ចប់ការិយបរិច្ឆេទ ថាអាចនឹងមាន ឬអាចមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ដល់លទ្ធភាពរបស់ធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលបំណុលនោះដល់កាលកំណត់សងឡើយ។

ការប្រែប្រួលនៃហេតុការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ អភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ លើកលែងតែហេតុការណ៍ ដែលបានលើកឡើងនៅក្នុងរបាយកាណ៍នេះ ឬក៏របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលនឹងបណ្ដាលឱ្យមានតួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

សមាសធាតុមិនប្រក្រតី

ផ្អែកតាមទស្សនៈរបស់អភិបាល លទ្ធផលនៃប្រតិបត្តិការប្រចាំឆ្នាំរបស់ធនាគារ មិនមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ពីសមាសធាតុណាមួយ ឬប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយមានលក្ខណៈមិនប្រក្រតីនោះទេ។

ផ្អែកតាមទស្សនៈរបស់អភិបាល នៅចន្លោះពេលចាប់ពីការិយបរិច្ឆេទបញ្ចប់ ដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានសមាសធាតុណាមួយ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារ ក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

ព្រឹត្តិការណ៍សំខាន់ៗក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍

នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ ធនាគារបានទទួលការអនុម័តជាផ្លូវការពីធនាគារជាតិនៃកម្ពុជា និងថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ ធនាគារបានទទួលការអនុម័តជាផ្លូវការពីក្រសួងពាណិជ្ជកម្ម ឱ្យធ្វើប្រតិបត្តិការអាជីវកម្មក្រោមឈ្មោះ "ធនាគារ អ៊ូរី (ខេមបូឌា) ម.ក"។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជា និង ក្រសួងពាណិជ្ជកម្ម ក៏អនុម័តក្នុងការផ្ទេរ ១ហ៊ុនពីធនាគារ Woori Bank Korea ទៅឱ្យលោក Hong Ju Kim ដែលជា ជនជាតិកូរ៉េ។ ធនាគារបានប្រកាសជាផ្លូវការ និងបានចាប់ផ្តើមធ្វើប្រតិបត្តិការក្នុងនាមជាធនាគារពាណិជ្ជជាសាធារណៈដោយជោគជ័យនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២។

ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទនៃរបាយការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានព្រឹត្តិការណ៍គួរឱ្យកត់សម្គាល់ណាមួយកើតឡើងបន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍នេះឡើយ មិនមានអ្វីដែលតម្រូវឱ្យមានការកែតម្រូវ ឬបង្ហាញ ក្រៅពីអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលកាន់តំណែងក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចជា៖

ឈ្មោះ	មុខតំណែង	កាលបរិច្ឆេទតែងតាំង ឬកាលបរិច្ឆេទលាឈប់
លោក Hyun Seong Yoon	ប្រធានក្រុមប្រឹក្សាភិបាល	តែងតាំងនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០
លោក Sun Kyu Kim	សមាជិក និងអគ្គនាយកប្រតិបត្តិ	តែងតាំងនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ និងបានលាឈប់នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២២
លោកស្រី Fiona Michelle Whyte	សមាជិក	តែងតាំងនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣
លោក Chang Yeon Kim	សមាជិក	តែងតាំងនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ និងបានលាឈប់នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១
លោក Ky Buntrean	សមាជិក	តែងតាំងនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០
លោក Hong Ju Kim	សមាជិក និងអគ្គនាយកប្រតិបត្តិ	តែងតាំងនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ជាអភិបាល និងតែងតាំងជាអគ្គនាយកប្រតិបត្តិដោយទទួលបានអនុម័តពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ (ដោយមានប្រសិទ្ធភាពពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ តទៅ)

ភាគហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

អភិបាលមួយរូបក្នុងចំណោមក្រុមប្រឹក្សាភិបាល លោក Hong Ju Kim បានកាន់កាប់ភាគហ៊ុន ១ ហ៊ុននៃមូលធនសរុបរបស់ធនាគារ។ ពុំមានការរៀបចំដែលកើតឡើងដោយធនាគារជាភាគីមួយ ក្នុងគោលបំណងធ្វើឱ្យអភិបាលទទួលបានផលប្រយោជន៍នៅក្នុងធនាគារ ឬអង្គភាពសាជីវកម្មឡើយ។

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុង និងនាចុងការិយបរិច្ឆេទនេះ ពុំមានការរៀបចំណាមួយដែលមានធនាគារជាភាគី ក្នុងគោលបំណងជួយដល់សមាជិកអភិបាលធនាគារ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ ដោយមធ្យោបាយទិញយកភាគហ៊ុននោះទេ។

ចាប់តាំងពីចុងកាលបរិច្ឆេទមុន ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិ ទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានទទួលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយធនាគារ ឬដោយធនាគារពាក់ព័ន្ធមួយជាមួយនឹងធនាគារដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយធនាគារដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែមានការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងមានទំនួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលនូវបានបង្ហាញនូវគ្រប់ទិដ្ឋភាពពិតជាសារវន្ត និងត្រឹមត្រូវ អំពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ធនាគារសម្រាប់ចុងការិយបរិច្ឆេទដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ គណៈគ្រប់គ្រងតម្រូវឱ្យ៖

- អនុម័តគោលនយោបាយគណនេយ្យសមស្រប ដោយមានការវិនិច្ឆ័យ និងការប៉ាន់ស្មាន ដោយសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។
- អនុវត្តតាមការតម្រូវនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRSs”) ឬប្រសិនបើមានគម្លាតនៃការអនុវត្តស្តង់ដារ ដែលដើម្បីជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិត និងត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុនោះ គម្លាតទាំងនោះគួរតែត្រូវបានបង្ហាញ ពន្យល់ និងកំណត់បរិមាណ ក្នុងរបាយការណ៍ហិរញ្ញវត្ថុឱ្យបានសមរម្យ។
- រក្សាទុកបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងធានាថាប្រព័ន្ធនៃការគ្រប់គ្រងផ្ទៃក្នុងមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឈរលើមូលដ្ឋាននិរន្តរភាព លើកលែងតែក្នុងករណីដែលធនាគារ មិនអាចបន្តសកម្មភាពអាជីវកម្មរបស់ខ្លួននាពេលអនាគត។
- ត្រួតពិនិត្យ និងដឹកនាំធនាគារ ឱ្យមានប្រសិទ្ធភាព និងចូលរួមរាល់សេចក្តីសម្រេចជាសារវន្ត ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលសូមបញ្ជាក់ថា ធនាគារបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ។

គណៈគ្រប់គ្រងមានទំនួលខុសត្រូវក្នុងការរៀបចំ ហើយក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការអនុម័តចុងក្រោយទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ព្រមទាំងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលគណៈគ្រប់គ្រងបានកំណត់ថាវាសមស្របនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយមិនមានកំហុសឆ្គងជាសារវន្ត មិនថាកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង។

សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

របាយការណ៍ហិរញ្ញវត្ថុដែលអមមកជាមួយ បានបង្ហាញនូវភាពត្រឹមត្រូវគ្រប់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ពីមុនមកត្រូវបានគេស្គាល់ជា ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ព្រះរាជាណាចក្រកម្ពុជា
ធនាគារ អ៊ូរី (ខេមបូឌា) ម.ក
WOORI BANK (CAMBODIA) PLC.
KINGDOM OF CAMBODIA

Mr. Hong Ju Kim
Board Member and Chief Executive Officer

Phnom Penh, Kingdom of Cambodia
Date 25th March 2022

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

អគារលេខ 398 មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង1 ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
www.wooribank.com.kh
info@wooribank.com.kh
(+855) 23 963 333 | 81 331 333